# ព្រះរាជប្រវត្តិពិស្ដារ

និង

# ពាក្យលោកធម៌

របស់

សម្ដេចព្រះសង្ឃរាជ (ជ.ណ. ជោតញ្ញាណោ)

បណ្ណាគារ សុមនសុខផ្លី លេខ ៤២

វិថី កែវ-ជា ក្រុងភ្នំពេញ

បោះពុម្ពចែកផ្សាយជាធម្មទាន

ក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព

នៃសម្ដេចជាអម្ចាស់ព្រះអង្គនោះ

ព.ស. ២៥១៣ = គ.ស. ១៩៧០

# ព្រះរាជប្រវត្តិពិស្តារ និង កាព្យលោកធម៌

របស់

# សម្តេចព្រះសង្ឃរាជ (ជ.ណ ជោតញ្ញាណោ)



(បណ្ឌិតមហា **ឈឹម ស៊ុម** តែង)

រៀបរៀងឡើងវិញ និងបានចុះផ្សាយនៅគេហទំព័រ ស្រុកស្រែ

ព.ស ២៥៥៦ គ.ស ២០១៣

# វាចាអ្នករៀបរៀងឡើងវិញ

កន្លងមក ខ្ញុំ **ស្រុកស្រែ** ធ្លាប់បានរកមើលក្នុងគេហទំព័រនានា ជាខេមរភាសាញឹកញាប់ណាស់ អំពីព្រះរាជប្រវត្តិសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ជាអម្ចាស់។ សូម្បីតែនៅគេហទំព័រក្នុងភូមិវើតប្រេស(WordPress)នេះ ក៏មានញាតិមិត្តយើងខ្លះ បានចុះផ្សាយជាបន្តបន្ទាប់អំពីព្រះរាជប្រវត្តិរបស់ព្រះអង្គ ហូរហែមកហើយដែរ។ តែខ្ញុំអានមើលទៅ គឺមិនសូវពិស្ដារដូចសៀវភៅមួយក្បាល ដែលបានបោះពុម្ពក្នុង ព.ស ២៥១៣ ត្រូវនឹង គ.ស ១៩៧០ មានចំណងជើងថា៖ **ព្រះរាជប្រវត្តិពិស្ដារ និង កាព្យលោកធម៌ របស់សម្ដេចព្រះសង្ឃរាជ** (ជ.ណ **ជោត-ញ្ញាណោ**) និពន្ធដោយលោកសាស្ត្រាចារ្យ **ឈឹម ស៊ុម** ដែលត្រូវជាកូនប្រសារអ្នកឧកញ៉ាសោភ័ណមន្ត្រី **ជួន នុត** (ជាប្អូនប្រុសតែមួយគត់របស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត**) ។

លោកសាស្ត្រាចារ្យ **ឈឹម ស៊ុម** ដែលត្រូវជាក្មួយប្រសាររបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត** បាននិពន្ធ និងបោះពុម្ពផ្សាយសៀវភៅនេះឡើង ដើម្បីចែកជូនជាធម្មទាន ក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពនៃសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ជាអម្ចាស់ ដែលនៅក្នុងអារម្ភកថា និងឧទ្ទិសកថា ដាក់កាលបរិច្ឆេទ ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ១៩៦៩ ហើយសៀវភៅនេះបានសរសេរចប់នៅថ្ងៃទី ១៨ ខែមករា ឆ្នាំ១៩៧០ គឺមុនពីរខែ នៃការធ្វើរដ្ឋប្រហារទំលាក់ **សម្ដេចព្រះនរោត្តម សីហនុ** ដោយក្រុមលោកសេនាប្រមុខ **លន់ នល់**...។

នៅខាងចុងសៀវភៅនេះ មានកំណាព្យមួយក្រោមចំណងជើងថា៖ **កាព្យលោកធម៌** ជាស្នាព្រះហស្ថដំបូងបំផុតរបស់សម្ដេចព្រះសង្ឃរាជជាអម្ចាស់ ដែលទ្រង់បានព្រះរាជទានសិទ្ធិអោយលោក **ឈឹម ស៊ុម** កាន់កាប់ជាព្រះកេរ្តិ៍ ក្នុងគ្រាដែលទ្រង់មានព្រះបន្ទូលតែពីរនាក់គាត់ អំពីរឿងផ្ទាល់ខ្លួន កាលទ្រង់ស្ថិតក្នុងយុវភាពនៅឡើយ...។ កាលណោះ គឺនៅថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩១២ សម្ដេចព្រះមហាសង្ឃរាជ **និល ទៀង** បានតែងតាំងតំឡើងឋានៈព្រះអង្គពី **ព្រះបាឡាត់សាក្យបុត្តីយ៍** ទៅជា **ព្រះគ្រូសង្ឃសត្ថា** ជាហេតុធ្វើអោយព្រះអង្គមានព្រះទ័យរំភើបពីខាងក្នុងខ្លះៗ បានជារាត្រីនោះ ព្រះអង្គទាញគម្ពីរបាលីមកបើកទតត្រង់រឿង **លោកធម៌** ហើយសរសេរប្រែមកជាសម្រាយ ចងក្រងជាពាក្យកាព្យទៀត ដើម្បីសង្កត់នូវសេចក្ដីរំភើបខ្លះដែលមានក្នុងព្រះទ័យ។ តែព្រះរាជស្នាដៃនិពន្ធដំបូងបង្អស់នេះ ត្រូវរង់ចាំរហូតដល់ ៤៣ឆ្នាំក្រោយមក គឺនៅថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៥៥ ទើបសម្ដេចព្រះសង្ឃរាជជាអម្ចាស់ បានសំរេចអនុញ្ញាត្តិអោយលោក **ឈឹម ស៊ុម** បោះពុម្ពផ្សាយជាផ្លូវការ។

កាលពីពេលថ្មីៗនេះ ខ្ញុំបានប្រទះភ្នែកឃើញសៀវភៅ **ព្រះរាជប្រវត្តិពិស្តារ និង កាព្យលោកធម៌ របស់សម្តេចព្រះសង្ឃរាជ (ជ.ណ ជោតញ្ញាណោ)** នេះជាថ្មីម្តងទៀត ដែលត្រូវបានក្រុមចៅទួត ចៅលួត ចៅលា របស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ធ្វើការបោះពុម្ពផ្សាយ និងចែកជាធម្មទានឡើងវិញ...។

ដោយយល់ឃើញថា មានប្រយោជន៍ដល់សាធារណជន ដើម្បីស្វែងយល់បន្ថែមទៀត អំពីព្រះរាជសកម្មភាព និងប្រវត្តិរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ជាអម្ចាស់ ដែលជាអតីតអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនា និងអក្សរសាស្ត្រជាតិរបស់កម្ពុជាយើង, ខ្ញុំបានធ្វើការចុះផ្សាយទាំងស្រុងនូវសៀវភៅ **ព្រះរាជប្រវត្តិពិស្តារ និង កាព្យលោកធម៌ របស់សម្តេចព្រះសង្ឃរាជ (ជ.ណ ជោតញ្ញាណោ)** តាមរយៈគេហទំព័រ *ស្រុកស្រែ* របស់ខ្ញុំ http://sroksrear.com ព្រមទាំងរៀបរៀងឡើងវិញជាសៀវភៅ ដោយមានបញ្ចូលរូបថតបច្ចុប្បន្នភាពថ្មីៗ ដែលខ្ញុំបានទៅថតដោយផ្ទាល់ដល់ទីកន្លែងទាំងឡាយ ដូចមានរៀបរាប់ក្នុងសៀវភៅនេះ។

ចំពោះរូបថតក្នុងសៀវភៅដែលស្រុកស្រែខ្ញុំ បានរៀបរៀងជាថ្មីឡើងវិញនេះ មានបីប្រភេទ៖ ទី១-ប្រភេទរូបថត និងរូបភាពខ្មៅ-ស គឺជារូបភាពក្នុងសៀវភៅច្បាប់ដើម, ទី២-ប្រភេទរូបថតព្រះឆាយាល័ក្ខណ៍ របស់អតីតសម្តេចសង្ឃ និងមន្ត្រីសង្ឃជាន់ខ្ពស់ គឺជារូបព្រះឆាយាល័ក្ខណ៍ ដែលដកស្រង់យកមកពីក្នុងគេហទំព័រព្រះពុទ្ធសាសនាមួយ ឈ្មោះថា៖ **វត្តខេមររតនារាម** ដែលមានអាសយដ្ឋាន http://watkhemararatanaram.org/index.php , និងទី៣-ប្រភេទរូបថតពណ៌ធម្មជាតិ គឺជារូបភាពដែលខ្ញុំបានថតដោយផ្ទាល់ កាលពីចុងឆ្នាំ ២០១២ និងដើមឆ្នាំ២០១៣ នេះ។ នៅមានរូបថតពីរបីសន្លឹកដែរ ដែលខ្ញុំបានទាញយកមកបញ្ចូលក្នុងសៀវភៅនេះ ពីគេហទំព័រនានា ជាភាសាបរទេស...។

សូមអញ្ជើញអស់លោកអ្នក រីករាយ និងធ្វើការស្វែងយល់បន្ថែមទៀត អំពីព្រះរាជប្រវត្តិពិស្តាររបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ជាអម្ចាស់ និពន្ធដោយលោកសាស្ត្រាចារ្យ **ឈឹម ស៊ុម** ដោយខ្ញុំសូមរក្សាទុកនូវរបៀបសរសេរជាលក្ខណៈព្យាង្គតំរួត និងឃ្លាប្រយោគដើមទាំងស្រុង។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមមេត្តាភ័យទោសនូវកំហុសឆ្គងគ្រប់ពាក្យពេជន៍ បែប «រាជស័ព្ទ» និងកំហុសដោយអចេតនាលើអក្ខរាវិរុទ្ធ ដោយសារតែការវាយអត្ថបទឡើងវិញនេះ... ហើយពាក្យ «ខ្ញុំ» នៅក្នុងសៀវភៅនេះ សំដៅទៅលើ **ស្មេរ** គឺលោកសាស្ត្រាចារ្យ **ឈឹម ស៊ុម** មិនមែនខ្ញុំ *ស្រុកស្រែ* ដែលជាអ្នករៀបរៀងឡើងវិញទេ បាទ !...

ខែផល្គុន ឆ្នាំរោង ព.ស ២៥៥៦ ត្រូវនឹងចុងខែមីនា គ.ស ២០១៣

ស្រុកស្រែ

# ព្រះរាជប្រវត្តិពិស្តារ

និង

# កាព្យលោកធម៌

របស់

សម្តេចព្រះសង្ឃរាជ (ជ.ណ. ជោតញ្ញាណោ)

បណ្ណាគារ **សុមនសុខន្ធ** លេខ ៤២
វិថី កែវ-ជា ក្រុងភ្នំពេញ
បោះពុម្ពចែកផ្សាយជាធម្មទាន
ក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព
នៃសម្តេចជាអម្ចាស់ព្រះអង្គនោះ
ព.ស. ២៥១៣ = គ.ស. ១៩៧០

# អារម្ភកថា និង ឧទ្ទិសកថា


លោកសាស្ត្រាចារ្យ ឈឹម ស៊ុម

ក្រោយថ្ងៃដែលសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោ ទ្រង់សោយទីវង្គតទៅ មិនយូរប៉ុន្មាន ខ្ញុំ(**ឈឹម ស៊ុម**) បានទទួលចុតហ្មាយមួយច្បាប់លេខ ៨៣៤៧.ប របស់លោកអគ្គនាយកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ សុំអោយខ្ញុំធ្វើព្រះរាជប្រវត្តិពិស្តារ នៃសម្ដេចព្រះសង្ឃរាជជាអម្ចាស់ ដោយមានប្រាប់គម្រោងការស្រេចមកផង។ ប៉ុន្តែ ក្នុងគម្រោងការនោះ ខ្ញុំទាល់ខ្លះ គឺត្រង់ព្រះគុណសម្បត្តិនៃសម្ដេច, ចរិតលក្ខណៈ, ចរិយាប្រចាំថ្ងៃ និងប្រចាំព្រះអង្គសម្ដេច ដែលជាលក្ខណៈ និងចរិយាប្លែកពីមនុស្សឯទៀត។ ព្រះគុណសម្បត្តិជាដើមនេះ ខ្ញុំក៏ធ្លាប់ឃើញដឹងឮផ្ទាល់ដូចអស់លោកឯទៀតដែរ។ ប៉ុន្តែបើខ្ញុំសរសេរ ទោះបីឥតបំផ្លើសក៏ដោយ ក៏ខ្ញុំនឹកឃើញមុនថា "គង់មានជនជាបរបក្ស រិះគន់ខ្ញុំពុំខាន" ព្រោះខ្ញុំជាក្មួយពីកំណើតហើយជាក្មួយប្រសាបង្កើតផង។ ហេតុដូច្នេះ ខ្ញុំសរសេរដោយពិស្តារតែត្រង់កន្លែងខ្លះដែលគេពុំសូវដឹងហើយនឹងកន្លែងខ្លះ ទោះបីគេដឹងហើយ ប៉ុន្តែគេពុំសរសេរ ឬខ្ញុំខានសរសេរពុំកើត។ ឯត្រង់កន្លែងដែលខ្ញុំថាទាល់នោះ ខ្ញុំសូមអោយព្រះតេជព្រះគុណព្រះមុនីកោសល **សូរ ហាយ** សរសេរអោយខ្ញុំ។


ព្រះឃោសទ្ធម្ម ប៉ុណ្យ សុម្ពាជ

ឯបុព្វប្រវត្តិ និងព្រះរាជប្រវត្តិក្នុងសៀវភៅនេះ ខ្ញុំបានដឹងពីលោកឧកញ៉ាសោភ័ណមន្ត្រី **ជួន នុត** ជាឪពុកក្មេកខ្ញុំផង និងអំពីសម្ដេចព្រះសង្ឃរាជជាអម្ចាស់ផង ដែលលោក-ព្រះអង្គជ្រាបអំពីលោកតា **ព្រហ្ម ជួន** ។ មិនតែប៉ុណ្ណោះ ខ្ញុំបានឃើញឯកសារខ្លះដែលគេប្រាប់ខ្ញុំថា លោកតាបាឡាត់ **មាស** មានស្រុកកំណើតនៅគងពិសី ជាចៅលោកតា **ម៉ុក** បានសរសេរទុកជាង ៧០ឆ្នាំ មកហើយផង, ខ្ញុំដឹងអំពីសម្ដេច **ល្វី ឯម** និងសម្ដេចព្រះសង្ឃនាយកព្រះនាម **ហួត តាត** ខ្លះផង។ ក្រៅពីនេះ ខ្ញុំបានមើលព្រះរាជជីវប្រវត្តិរបស់សម្ដេចជាអម្ចាស់ ដែលព្រះតេជព្រះគុណឃោសទ្ធម្ម **ប៉ុណ្យ សុម្ពាជ** បានរៀបរៀង ហើយខ្ញុំបានបោះពុម្ពដាក់ទស្សនាវដ្ដីអក្សរសាស្ត្រលេខ ១១ ឆ្នាំ ១៩៦៥ ផង។ ព្រះរាជប្រវត្តិដែលខ្ញុំសរសេរនេះ ច្បាស់លាស់ជាងនោះ ព្រោះកាលនោះ សម្ដេចព្រះសង្ឃរាជជាអម្ចាស់ ទ្រង់គង់ព្រះជន្មនៅឡើយ ទ្រង់ពុំព្រមអោយផ្សាយព្រះរាជប្រវត្តិរបស់ព្រះអង្គទេ។ ប៉ុន្តែទាល់នឹងរាជការតម្រូវការ ទើបទ្រង់អនុញ្ញាតអោយព្រះតេជព្រះគុណព្រះឃោសទ្ធម្ម សរសេរសង្ខេបខ្លីៗដើម្បីជូនរាជការប៉ុណ្ណោះ។ ឯសេចក្ដីពិស្តារ ម្ដងទ្រង់ដំណាលពីត្រង់នេះ ម្ដងទ្រង់ដំណាលពីត្រង់នោះ

អោយខ្ញុំស្តាប់។ ខ្ញុំកត់ត្រាទុកច្រើនដងច្រើនគ្រា ផ្សំគ្នាកើតចេញជាព្រះរាជប្រវត្តិពិស្តារនេះឡើង។ កាលបរិច្ឆេទក្នុងព្រះរាជប្រវត្តិនេះ ខ្ញុំពិនិត្យកត់ត្រាដោយហ្មត់ចត់ ឥតអោយភ័ន្តច្រឡំទេ។

ក្រៅពីបុព្វប្រវត្តិ និងព្រះរាជប្រវត្តិ ខ្ញុំបានដាក់ **កាព្យលោកធម៌** បន្តនៅខាងចុងទៀត ព្រោះកាព្យលោកធម៌នេះ ជាព្រះរាជនិពន្ធដំបូងបំផុតនៃសម្តេចព្រះសង្ឃរាជជាអម្ចាស់ ដែលទ្រង់ព្រះរាជទានសិទ្ធិអោយខ្ញុំកាន់កាប់ជាព្រះកេរ្តិ៍ ក្នុងគ្រាដែលទ្រង់មានព្រះបន្ទូលតែពីរនាក់នឹងខ្ញុំ អំពីរឿងផ្ទាល់ព្រះអង្គកាលទ្រង់គង់ក្នុងយុវភាពនៅឡើយ។

លុះខ្ញុំរៀបរៀងសៀវភៅនេះចប់ហើយ ខ្ញុំពុំបានយកទៅជូនលោកអគ្គនាយកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យទេ ព្រោះខ្ញុំដឹងថា «អ្នកនិពន្ធឆើតៗទាំងឡាយ ដែលលោកអគ្គនាយកសុំអោយធ្វើព្រះរាជជីវប្រវត្តិនេះមានច្រើនរូប បើធ្វើបានមួយចប់ម្នាក់ៗ យកទៅប្រជុំគ្នា ប្រាកដជានឹងជម្រុះចោលខ្លះ យកខ្លះទៅបោះពុម្ព នាំអោយអ្នកនិពន្ធខ្លះមានការស្រពោនស្រពាប់», ទើបខ្ញុំនិយាយថា សូមអោយព្រះតេជព្រះគុណព្រះមុនីកោសល ធ្វើតែមួយព្រះអង្គឯងទៅ, ឯរបស់ខ្ញុំ ខ្ញុំនឹងចំណាយប្រាក់ខ្លួនឯងបោះពុម្ពផ្សាយជាមួយក្រុមគ្រួសារខ្ញុំប៉ុណ្ណោះ។

ឥឡូវសៀវភៅរបស់ខ្ញុំនេះបានបោះពុម្ពហើយ ខ្ញុំនឹងប្រគេនចែកជូនពុទ្ធសាសនិកជន ទាំងបុព្វជិតទាំងគ្រហស្ថ ជាមួយនឹងសៀវភៅ អរិយសច្ចកថាសង្ខេប ដើម្បីថ្វាយជាព្រះរាជកុសលចំពោះព្រះអង្គសម្តេចព្រះសង្ឃរាជជាអម្ចាស់ ក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពរបស់ព្រះអង្គ។

បពិត្រសម្តេចព្រះសង្ឃរាជជាអម្ចាស់ ជាឪពុកធំ ជាជីតា! ខ្ញុំព្រះអង្គទាំងឡាយជាព្រះភាគិនេយ្យ (ក្មួយ) ជាព្រះជនត្តា(ចៅ) គ្រប់គ្នា កាលឋិតនៅក្នុងតរុណភាពជាកុមារ-កុមារី មានមាតាបិតាជាអ្នកឃុំគ្រង, កន្លងមក បើមានការក្រ-ងាយ បានសម្តេចជាអម្ចាស់ហាក់ដូចជាបន្ទាយ ហើយជាម្លប់ដ៏ត្រជាក់សែនមហាត្រជាក់! ឥឡូវនេះទ្រង់សោយទីវង្គតបាត់ព្រះភ័ក្ត្រ ទូលព្រះបង្គំគ្រប់គ្នា មានការស្តាយក្រៃលែងស្តាយរកសំដីនិយាយអោយស្មើនឹងចិត្តពុំបាន ព្រោះខានបានស្តាប់ព្រះឱវាទផ្ទាល់ទៀតហើយ!

បពិត្រសម្តេចជាអម្ចាស់! បើសម្តេចទ្រង់ស្តេចយាងទៅកាន់ប្រទេសណា ដែលទូលព្រះបង្គំគ្រប់គ្នាល្មមផ្ញើភ័ស្តុភារបានទៅរ៉ា នឹងផ្ញើទៅថ្វាយផ្ទាល់, ឥឡូវព្រះរាជដំណើររបស់ព្រះអង្គនេះ ទូលព្រះបង្គំដឹងពុំដល់ ស្គាល់ពុំបាន គឺពុំដឹងជាព្រះវិញ្ញាណរបស់ព្រះអង្គទៅគង់នៅក្នុងទីឋានណា, ហេតុដូច្នេះបានជាទូលព្រះបង្គំគ្រប់គ្នា មានក្តីសង្ឃឹមតាមជំនឿថា «មានតែផលនៃធម្មទាន ទើបអាចបញ្ជូនអោយទៅរកព្រះវិញ្ញាណដែលជាអរូបដូចគ្នាបាន» ហើយក៏នាំគ្នាបរិច្ចាគធនធាន បោះពុម្ពសៀវភៅពីមុខគឺ៖ **សៀវភៅ**

**អរិយសច្ចកថាសង្ខេប ១មុខ, សៀវភៅព្រះជីវប្រវត្តិពិស្តារ និងកាព្យលោកធម៌** របស់សម្តេចជាអម្ចាស់ ១មុខ, ចែកប្រគេន-ជូន ចំពោះបុព្វជិត និងគ្រហស្ថ ក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពនៃសម្តេចជាអម្ចាស់។

សូមផលនៃធម្មទាននេះ ជួយទ្រទ្រង់អង្គសម្តេចដែលត្រាច់ទៅចាប់ព្រះជាតិថ្មីក្នុងសុគតិភព!... សូមសម្តេចទ្រង់ទទួលសោយនូវទិព្វសម្បត្តិក្នុងពិភពតុសិត សមដូចព្រះរាជបំណងដែលទ្រង់ប៉ងប្រាថ្នានូវព្រះប្រាជ្ញាសព្វញ្ញុតញ្ញាណ ក្នុងកាលជាអនាគតកុំខានឡើយហោង...។

ថ្ងៃទី ២០-១១- ៦៩

**ក្រុមព្រះញាតិវង្ស**

# ព្រះរាជប្រវត្តិពិស្តារ

# សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ

(បណ្ឌិតមហា **ឈឹម ស៊ុម តែង**)

******************

# បុព្វប្រវត្តិ

ក្នុងកាលកន្លងទៅហើយ ប្រទេសកម្ពុជាយើងមានក្រុងឱដុង្គមានជ័យ ជារាជធានី។ ក្នុងរជ្ជកាលនៃព្រះមហាក្សត្រិយានីអង្គ **ម៉ី** មានអ្នកចម្បាំងបីនាក់ ឈ្មោះ **ម៉ា** ១ **មាស** ១ **ម៉ុក** ១ បងប្អូននឹងគ្នា (ពុំដឹងមានងារការដូចម្តេចទេ)។ មន្ត្រីធំៗឯទៀត និងជនទាំងបីនាក់នេះ ក្តៅក្រហាយនឹងរាជការរបស់ព្រះមហាក្សត្រិយានីអង្គ **ម៉ី** ទើបនាំគ្នាទៅតវ៉ាសុំព្រះអង្គ **ឌួង** ពីប្រទេសសៀមមកសោយរាជ្យ។ ក្រោយមក ព្រះអង្គ **ឌួង** តាំងលោកតា **ម៉ា** ជាឧកញ៉ាមហាទេព, តាំងលោកតា **មាស** ជាឧកញ៉ាចក្រី, តាំងលោកតា **ម៉ុក** ជាឧកញ៉ាយោមរាជ។ មន្ត្រីជាន់ខ្ពស់ទាំងនេះ ជាមនុស្សធ្លាប់ច្បាំង ហើយបើទោះជាលោកមហាទេព មានមុខតំណែងខាងវាំងក្តី លោកយោមរាជ មានមុខតំណែងខាងតុលាការក្តី ក៏នៅតែធ្វើការរួមនឹងលោកចក្រី ខាងសឹកសង្គ្រាមដែរ ពុំព្រមផ្អាកការច្បាំងរាំងជល់សោះ។

កាលដើមឡើយ ពុំប្រាកដជាក្នុងឆ្នាំណា លោកតា **ម៉ា** បានអញ្ជើញប្រក់ព្រំទ័ពនៅខេត្តបាទី, កណ្តាលស្ទឹងនិងគងពិសី បានឃើញដីទំនេរមួយកន្លែងត្រង់ភូមិកម្រៀង[1] នៅប្រទល់ខេត្តកណ្តាលស្ទឹង និងគងពិសី ជាដីអណ្តែត ព្រោះខែវស្សាមានទឹកព័ទ្ធជុំវិញដូចជាកោះ។ (នៅប្រមាត់ស្ទឹងតូចព្រំប្រទល់)

លោកតា **ម៉ា** មានភរិយា ៣, ទី១ ឈ្មោះ **អែម** អ្នករាជធានីឱដុង្គ បានកូនស្រីម្នាក់ឈ្មោះ **អិម**, ទី២ ឈ្មោះ **អ៊ុក** អ្នកភូមិព្រៃកតាអុង (ល្វាឯម) បានកូនស្រីពីរនាក់ ឈ្មោះ **អ៊ុម** និងឈ្មោះ **សារី** ដែលបានឋានៈជាអ្នកម្នាង **សារី** របស់ព្រះបាទសម្តេចព្រះនរោត្តម, និងទី៣ ឈ្មោះ... (ភ្លេច) អ្នកភូមិអង្គ្រងសេដ្ឋី (ខាងលិចបន្ទាយលង្វែក) បានកូនប្រុសស្រីច្រើន (ចាំពុំអស់) កូនប្រុសម្នាក់ឈ្មោះ **ឪម** មានប្រពន្ធពីរ, ប្រពន្ធទីមួយ បានកូនប្រុសឈ្មោះ **សាន** កូនស្រីឈ្មោះ **ភន** នៅភូមិអង្គ្រងសេដ្ឋី។

---

[1] កម្រៀង ជាឈ្មោះដើមស្វាយមួយប្រភេទស្រដៀងនឹងស្វាយព្រៃ ប៉ុន្តែស្លឹកតូចៗ ផ្លែល្អិតៗ ធុំក្លិនដូចស្វាយ បរិភោគពុំកើត ព្រោះសាច់ផ្លែតិចណាស់។

តទៅនេះ នឹងថ្លែងពីភូមិកម្រៀង ត្រង់កន្លែងផ្ទះលោកតាមហាទេព **ម៉ា** ។ ភូមិនេះមានវឌ្ឍនភាពស្តុកស្តម្ភដោយផលដំណាំ ព្រោះភូមិនេះតាំងនៅប្របមាត់ស្ទឹង ជាដីមានជីរជាតិល្អ ហើយជាទីជយភូមិដែលសត្រូវពុំហានមើលងាយផង។ ក្នុងឆ្នាំណាមួយពុំប្រាកដ លោកតាមហាទេព **ម៉ា** បានអោយកូនស្រីឈ្មោះ **អិម** ដែលបានប្តីឈ្មោះ **ព្រហ្ម** ជាអ្នកភូមិពពៃជ្រៃលាស់ ហើយត្រូវជាក្មួយលោកស្រាប់ផងនោះទៅនៅជាម្ចាស់ភូមិកម្រៀង។ មិនតែប៉ុណ្ណោះ មានបងប្អូនលោកតា **ព្រហ្ម** ហើយជាក្មួយៗ លោកតាមហាទេព **ម៉ា** ច្រើនគ្នា បានទៅនៅភូមិជិតគ្នានោះដែរ ខ្លះនៅភូមិរកាកោះ ដូចលោកតា **ម៉ា** ជាញោមលោកគ្រូព្រះពុទ្ធឃោសចារ្យ **ម៉ា ភេត** ជាដើម, ខ្លះនៅភូមិស្វាយ ដូចលោកឧកញ៉ានេត្រឧទ័យ **យស** លោកយាយ **ម៉ែន** ដែលជាបិតាមាតាលោកយាយ **គំ** និងលោកអ្នកឧកញ៉ាមន្រ្តីរាជឫទ្ធិ **យក់** ជាដើម។

ផ្ទះលោកតា **ព្រហ្ម** នៅភូមិកម្រៀង មានដំបូកមួយធំ មានដើមស្វាយត្រសាយត្រសុំដុះលើដំបូកនោះ។ គល់ស្វាយមានរូងធំចំលើកំពូលដំបូក ល្មមលាក់វត្ថុសំខាន់ៗ បាន។ លោកតាមហាទេព **ម៉ា** ក្នុងគ្រាជរា លោកបានយកក្បួនខ្នាត មន្តអាគម យ័ន្តគាថា និងអាវតេជៈ គ្រឿងវត្ថុសក្តិសិទ្ធិ របៀបក្បួនចម្បាំងខ្មែររបស់លោក ទៅទុកក្នុងរូងស្វាយនោះ។ លោកបានផ្តាំលោកតា **ព្រហ្ម** និងលោកយាយ **អិម** ថាកុំអោយរំលាយដំបូកនេះ ត្រូវគោរពទីនេះ នឹងបានសុខចំរើន។ ជាមួយនេះ លោកតាមហាទេព **ម៉ា** បានប្រគល់ដាវពិសិដ្ឋមួយ ដែលធ្លាប់មានជោគជ័យ អោយដល់លោកតា **ព្រហ្ម** ដោយមានបណ្តាំថា រក្សាអោយគង់ គ្រាន់រក្សាទឹកដី។ នៅត្រង់គល់ដាវពិសិដ្ឋនេះ មានសរសេរអក្សរចិនដាក់ថា៖ ***ប្រាក់សុទ្ធ ២តម្លឹង ៣ហ៊ុន*** ។

ភូមិកម្រៀងជំនាន់នោះ ជាទីដែលគេតែងគោរព គឺជនដែលសញ្ចរទៅមកតាមផ្លូវមុខភូមិនោះ តែងបើកមួក ហើយដំបូកនោះ ជាទីធ្វើសក្ការៈនៃអ្នកភូមិ[2] ។

លោកតាមហាទេព **ម៉ា** ទទួលអនិច្ចកម្មទៅ ក្នុងក្រុងឧដុង្គមានជ័យ ក្នុងឆ្នាំណាមិនប្រាកដ។ អង្ឃិជាតុរបស់លោក គឺភរិយា និងបុត្រាបុត្រីព្រមព្រៀងគ្នា នាំយកទៅបញ្ចុះក្នុងចេតិយ ដែលរួមគ្នាកសាងនៅ វត្តសេដ្ឋី ។ ចេតិយនេះ សម្តេចព្រះសង្ឃរាជ **ជួន ណាត** ទ្រង់បានជួសជុលជាថ្មី ហើយសម្តេចទ្រង់សព្វព្រះរាជហឫទ័យ ទ្រង់ទៅបង្សុកូលញឹកៗ... ។

---

[2] កាលឆ្នាំ ១៩០៨ ដែលលោកតាជួន ទៅនៅភ្នំពេញហើយ ឈ្មោះ ឌីក បានដាវភូមិនោះយក។ ឌីក ក៏ជ្រេះដំបូកនោះទាល់តែរលំដើមស្វាយ។ បន្ទាប់គ្នានឹងដើមស្វាយរលំ ព្រទ្យរបស់ ឌីក ក៏រលាយ, កូន ឌីក ឈ្មោះ ម៉ន ឆ្កួត, កូនស្រីម្នាក់ ខ្វាក់ភ្នែកទាំងពីរ, ខ្លួន ឌីក ក៏ស្លាប់បាត់ទៅ។

# ទិដ្ឋភាពវត្តសេដ្ឋី និងចេតីយ៍ នាពេលបច្ចុប្បន្ន ដែលដំកល់អដ្ឋិធាតុលោកមហាទេព ម៉ា



ក្លោងទ្វារវត្តសេដ្ឋី ស្ថិតក្នុងឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ
ខេត្តកំពង់ឆ្នាំង... (រូបថតស្រុកស្រែ-ខែកុម្ភៈ ឆ្នាំ២០១៣)



ទីធ្លា និងព្រះវិហារវត្តសេដ្ឋី...
(រូបថតស្រុកស្រែ-ខែកុម្ភៈ ឆ្នាំ២០១៣)


sroksrear.com
ចេតីយ៍ចំណាស់ ស្ថិតនៅចំខាងកើតព្រះវិហារ
ដែលដំកល់អដ្ឋិធាតុលោកមហាទេព ម៉ា
និងព្រះញាតិរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត...
(រូបថតស្រុកស្រែ-ខែកុម្ភៈ ឆ្នាំ២០១៣)


sroksrear.com


sroksrear.com


ស្រះទឹកធំមួយ ស្ថិតនៅចំខាងកើតព្រះវិហារ...
(រូបថតស្រុកស្រែ-ខែកុម្ភៈ ឆ្នាំ២០១៣)
sroksrear.com



សាលាធាន់... (រូបថតស្រុកស្រែ-ខែកុម្ភះ ឆ្នាំ២០១៣)



កុដិព្រះសង្ឃ... (រូបថតស្រុកស្រែ-ខែកុម្ភះ ឆ្នាំ២០១៣)

ថ្លែងពីលោកតា **ព្រហ្ម** លោកយាយ **អិម** ជាកូនលោកមហាទេព **ម៉ា** នៅភូមិកម្រៀងឯណោះ ជាមនុស្សខ្សត់កូន។ លុះកន្លងកាលដ៏យូរឆ្នាំ មកដល់ឆ្នាំជូត ព.ស ២៣៩៤ ត្រូវនឹង គ.ស ១៨៥១ ត្រូវលើខែបុស្ស ថ្ងៃព្រហស្បតិ៍ ទើបបានកូនប្រុសមួយ អោយឈ្មោះថា **ជួន** ។

លោកតា **ជួន** ជាកូនប្រុសទោលតែមួយ ឥតបងប្អូនជាគម្រប់ពីរទេ។ គ្រាដែលលោកមានជន្មាយុ ២៨ឆ្នាំ ចាកសិក្ខាបទពីភិក្ខុមក ទើបមាតាបិតារៀបអាពាហ៍ពិពាហ៍ ជាមួយញាតិធីតាឈ្មោះ **យក់** នៅភូមិបឹងនរាគជេន្ទ្រ ។


លោកតា ព្រហ្ម ជួន

លោកតា **ព្រហ្ម ជួន** គ្មានបុណ្យសក្តិជាមន្ត្រីទេ។ ប៉ុន្តែកាលជាបព្វជិត ល្បីខាងទេសមហាជាតក ស្មូត្រ សរសេរអក្សរល្អ អានពាក្យច្បាស់ និយាយក្បោះក្បាយ មិនច្រឡំតួអក្សរសិថិល ជាធនិត ។ លុះផ្លាស់ភេទពីបព្វជិតមកជាគ្រហស្ថ ល្បីខាងចេះច្បាប់ អាចធ្វើពាក្យក្តីបាន។

ជាពិសេស លោកតា **ព្រហ្ម ជួន** ជាមនុស្សពូកែសម្តី (វាគ្មិន) ប្រាជ្ញាវៃ អាចសងពាក្យ (ដាក់ផ្លែផ្កា) ចំពោះអ្នករាប់អានស្មោះ ឬអ្នកមើលងាយ បានភ្លាមៗ ។ លោកតា **ព្រហ្ម ជួន** គឺអ្នកស្រុកជិតខាង ចូលចិត្តយកធ្វើមេបា ឬអ្នកមហា ក្នុងពិធីមង្គលការកូនប្រុសស្រីណាស់...។


លោកយាយ យក់

លោកយាយ **យក់** ក្រោយរៀបអាពាហ៍ពិពាហ៍ហើយ៥ឆ្នាំ ក្នុងថ្ងៃពេញបូណ៌មី នៃខែជេស្ឋ ឆ្នាំវក ឆស័ក ព.ស ២៤២៦ គ.ស ១៨៨៣ ក្នុងវេលាបច្ឆិមយាមរាត្រី អរុណរង្សីក្រហមព្រឿងនាទិសបូព៌ បានឃើញសុបិននិមិត្តថា៖ ខ្លួនគាត់កំពុងបែរមុខទៅទិសខាងកើត សម្លឹងមើលពន្លឺអរុណ ស្រាប់តែឃើញមនុស្សស្លៀកពាក់សម្នាក់ ហាក់ដូចជាចេញពីព្រះអាទិត្យ មកស្ថិតនៅចំពោះមុខគាត់ យកចិញ្ចៀនមួយវង់ មកបញ្ចូកម្រាមដៃគាត់។ ឯចិញ្ចៀននោះប្លែកត្រកាលណាស់ មានត្បូងមួយគ្រាប់ធំភ្លឺជាងគេនៅចំកណ្តាល ហើយខ្ពស់ជាងត្បូងឡោមព័ទ្ធជុំវិញដែលមានពន្លឺដែរ សុទ្ធតែ **ពណ៌លឿង** ទាំងអស់[3] ។

ព្រឹកឡើងលោកយាយ **យក់** បានជំរាបលោកតា **ជួន** តាមដំណើរសុបិនដែលបានឃើញ។ លោកតា **ជួន** កាត់សុបិនថា យើងប្រហែលជាបានកូនប្រុស មានអាយុវែង។ ពេលនោះ គេសម្គាល់ថា

[3] សុបិននិមិត្តនេះ ចាស់ៗ ដែលដឹង ធ្លាប់បាននិយាយពាសស្រុក ពាសខែត្រ រហូតមកដល់សព្វថ្ងៃ។ ប៉ុន្តែប្លែកគ្នាខ្លះ ត្រង់អ្នកខ្លះនិយាយថា «បានចិញ្ចៀនដប់ ពាក់គ្រប់ម្រាមទាំងដប់» នេះជាពាក្យក្លាយទេ។

មានទារកចាប់ផ្ទៃ ព្រោះគេចំណាំតាមទំលាប់ចាស់ៗ ដែលធ្លាប់មានផ្ទៃពោះ។ តមក លោកយាយ **យក់** ចង់ពិសារតែផ្លែម្នាស់ទុំ ។

ចំណេរកាលមកជាង ៩ខែ ទារកក្នុងផ្ទៃលោកយាយ **យក់** បានប្រសូត្រមក ក្នុងថ្ងៃអង្គារ៍ ១១រោច ខែផល្គុន ឆ្នាំរកា ឆស័ក ព.ស ២៤២៦ ត្រូវនឹងខែមីនា គ.ស ១៨៨៣ មានលក្ខណៈពេញលេញជាមនុស្សប្រុស បិតាបានអោយឈ្មោះ **ណាត** ។

តមកដល់ឆ្នាំកុរ នព្វស័ក ព.ស ២៤២៩ ត្រូវនឹង គ.ស ១៨៨៦ លោកតា **ជួន** លោកយាយ **យក់** ប្រសូត្របានកូនប្រុសម្នាក់ទៀត អោយឈ្មោះ **នុត** ។

ក្នុងគ្រានោះ ស្រុកខ្មែរកើតកលិយុក គឺចម្បាំងបារាំង-ខ្មែរ មិនទាន់ស្ងប់នៅឡើយ។ ហេតុដូច្នេះ អ្នកគង្វាលគោដែលលោកតា **ជួន** បានជួលមកអោយឃ្វាលគោហ្វូង ខ្លះត្រូវកងទ័ពកេណ្ឌទៅច្បាំង ខ្លះរផោត់ទាំងទៅតាមអំពើចិត្ត ឥតនរណាឃ្វាលគោ ក៏កុមារទាំងពីរនាក់ ម្នាក់មានអាយុ ៨ឆ្នាំ ម្នាក់មានអាយុ ៤ឆ្នាំ នាំគ្នាដេញគោហ្វូងទៅឃ្វាលនៅក្បែរវត្តសុរភី ។ លោកគ្រូចៅអធិការវត្តនេះ ព្រះនាម **ស្វាយ** ចេះក្បួនខ្នាតច្រើន មានចំណេះវិជ្ជាច្រើន បានឃើញកុមារទាំងពីរនាក់ ក៏តែងគន់មើលរាល់ៗ ថ្ងៃ ដោយក្តីសង្ស័យពុំប្រាកដជាកូននរណា ដែលមានអាកប្បកិរិយាប្លែកពីក្មេងឯទៀតគឺ ពេលខ្លះបោចវល្លិវេញខ្សែ, ពេលខ្លះបេះស្លឹកសង្កែរវេចនឹងក្រមា, ពេលខ្លះដើរដកប្រស់ស្វា, ពេលខ្លះបេះស្លឹកថ្នឹង, លោកចង់ដឹង ក៏ទៅឈរសម្លឹងកុមារទាំងពីរកំពុងងូតទឹក ទើបសួរអ្នកជិតខាងថា ក្មេងពីរនាក់នេះ កូនអ្នក **ជួន** ឬ? ឈ្មោះ **សម** បានពិតទូលលោកគ្រូថា កូនលោកបង **ជួន** ។ មួយថ្ងៃក្រោយមក លោកគ្រូ **ស្វាយ** និមន្តទៅផ្ទះលោកតា **ជួន** ឯភូមិកម្រៀង។ លោកសំណេះសំណាលពីនេះពីនោះ ហើយថា កូនអ្នក **ជួន** អាបងនោះ ជាមនុស្សប្លែកពីគេណាស់ កូននេះប្រៃឈាមមួយថ្ងៃ បីដង បុរាណហៅថា "ឈាមក្រោក" កម្រមានណាស់មនុស្សដូច្នេះ។ ប៉ុន្តែយើងជាតិជារាស្ត្រ និយាយតាមក្បួនអោយអស់សេចក្តីពុំបានទេ។


ព្រះគ្រូ ខឹម

កន្លងមួយឆ្នាំ ពីនោះមក លោកតា **ជួន** អោយលោកយាយ **យក់** រៀបចង្ហាន់ពីរផ្នែក រែកទៅវត្តពោលយំ (អានថាៈ ពោ-ល-យំ) បច្ចុប្បន្ន គឺវត្តពោធិព្រឹក្ស ដើម្បីនាំកូនទាំងពីរ អោយនៅរៀនឯវត្តនោះ ក្នុងសំណាក់លោកគ្រូពីរព្រះអង្គ ដោយពុំទាន់កំណត់ថា កូនណាអោយនៅនឹងលោកគ្រូណាទេ។ លុះរែកចង្ហាន់នាំកូនទាំងពីរទៅដល់វត្ត បានចូលទៅកុដិលោកគ្រូសូត្រ **ខឹម** មុន ព្រោះលោកគ្រូជាញាតិ សូមអោយលោករើសយកកូនទាំងពីរណោមួយទុកបង្រៀនចុះ។

លោកគ្រូសូត្រ **ខឹម** ថា រាល់តែគ្រាដែលគេយកកូនមកអោយអាត្មាបង្រៀន អាត្មាតែងយល់សប្តិឃើញមុន, ប៉ុន្តែច្រើនតែយល់សប្តិឃើញបានចាន បានចប បានពូថៅ, ឯល្ងាចមិញនេះ អាត្មាយល់សប្តិឃើញថា បានកែវមួយដុំធំធ្វន់ភ្លឺចិញ្ចាចល្អណាស់ មានផ្កាចម្ប៉ាមួយនៅក្នុងនោះផង, បើតាមសុបិននេះ អាត្មាទទួលយកអា **នុត** ចុះ ព្រោះវាមានសាច់សល្អ ដូចកែវដែលអាត្មាយល់សប្តិឃើញពីល្ងាច។


ព្រះគ្រូ ម៉ម

ឯអា **ណាត** បងឯងយកទៅផ្ញើនឹងលោកគ្រូ **ម៉ម** ចុះព្រោះជិតភ្លឺនេះ អាត្មាយល់សប្តិឃើញមួយផ្នែកទៀតថា៖ លោកគ្រូ **ម៉ម** ដុតភ្លើងជាភ្នក់ៗជុំវិញរបងវត្ត ឆេះឡើងភ្លឺទ្រលោម ហើយដុត ១ភ្នក់ទៀតនៅចំកណ្តាលវត្ត ឆេះឡើងភ្លឺទល់អាកាស ជះពន្លឺភ្លឺជាងភ្នក់ភ្លើងជុំវិញរបងវត្ត ដែលឆេះស្រាប់[4] ។

លោកតា **ជួន** បានផ្ទុកផ្តាក់កុមារ **នុត** អោយនៅនឹងលោកគ្រូសូត្រ **ខឹម** ហើយនាំកុមារ **ណាត** អោយទៅនៅសិក្សាក្នុងសំណាក់លោកគ្រូសូត្រ **ម៉ម** ក្នុងវត្តជាមួយគ្នា និងក្នុងថ្ងៃជាមួយគ្នាទៀត។

កុមារទាំងពីរខំប្រឹងរៀនប្រណាំងគ្នា អស់វេលា ៤ឆ្នាំ មានចំណេះផ្សេងពីគ្នាខ្លះ គឺកុមារ **ណាត** ចេះធម៌អាថ៌ ចេះទេសមហាជាតក ដោយសារលោកគ្រូសូត្រ **ម៉ម** ជាគ្រូដើម ជាអ្នកល្បីល្បាញខាងទេសមហាជាតក មានសិស្សពីខេត្តផ្សេងៗ កាត់មកហាត់ទេសមហាជាតកជាប្រក្រតី ព្រោះលោកគ្រូសូត្រនេះជាសិស្សចម្បងរបស់លោកវិសេស **ជួខ** ។ ពេលលោកគ្រូសូត្រ **ម៉ម** និមន្តទៅទេសក្នុងទីណាៗ តែងយកកុមារ **ណាត** ជាប់ទៅជាមួយផង។ ជួនកាល លោកទេសដល់កណ្ឌចូឡពន មហាពន កុមារបាត់ ដល់ពេលលោកគ្រូឆាន់, លោកគ្រូក៏អោយកុមារ **ណាត** ទេសជួសលោកក៏មាន។

ឯកុមារ **នុត** ចេះសរសេរអក្សរល្អដូចគ្នា ប៉ុន្តែផ្សេងគ្នាត្រង់មិនចេះទេស ចេះតែលេខខ្មែរ លេខចិនពូកែជាង...។

---

[4] សុបិន្តនេះ ចាស់ៗ ច្រើនគ្នាបានដឹង ហើយនិយាយតៗ គ្នាមកដល់ពេលនេះ។ អ្នកខ្លះមកនិយាយប្រាប់ខ្ញុំទៀត អ្នកខ្លះសរសេរមកអោយខ្ញុំផង ដូចលោកម៉ិច ប៊ុន តំណាងរាស្ត្រក្នុងរដ្ឋសភាជាដើមថា ដឹងពីព្រះសព ខឹម ។

# ផ្លូវទៅកាន់វត្តពោធិព្រឹក្ស (អតីតវត្តពោលឿ) នាពេលបច្ចុប្បន្ន









ក្លោងទ្វារចូលវត្តសុភី ស្ថិតក្នុងឃុំរកាកោះ ដែលលោកគ្រូ ស្វាយ គង់នៅ... (រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




ផ្លូវលំក្នុងភូមិរកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ (រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)


sroksrear.com
ក្លោងទ្វារវត្តពោធិព្រឹក្ស មើលពីភូមិរកាកោះ...
ស្ពានថ្មខាងមុខ ជាព្រំប្រទល់ភូមិរកាកោះ និងភូមិកំរៀង
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)


ស្ពានថ្មតូចនេះ ជាព្រំប្រទល់រវាងភូមិកំរៀង(ឆ្វេងដៃ) និងភូមិរកាកោះ(ស្តាំដៃ)...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)
sroksrear.com



ក្លោងទ្វារវត្តពោធិព្រឹក្ស ស្ថិតក្នុងភូមិកំរៀង ឃុំរលាំងកែន...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)



របងវត្តពោធិព្រឹក្ស ស្ថិតក្នុងភូមិកំរៀង ឃុំរលាំងកែន...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)


sroksrear.com
ព្រះវិហារវត្តពោធិព្រឹក្ស មើលពីខាងត្បូង
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)


sroksrear.com
ទីធ្លាវត្តពោធិព្រឹក្ស នាពេលបច្ចុប្បន្ន...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)


ព្រះគ្រូ មា កេត

កុមារ **ណាត** កាលបានអាយុ ១៤ឆ្នាំ បានបួសជាសាមណេរក្នុងថ្ងៃ ១៥កើត ខែពិសាខ ឆ្នាំច សម្រិទ្ធិស័ក ព.ស ២៤៤០ ត្រូវនឹងខែឧសភា គ.ស ១៨៩៧ នៅវត្តពោធិ៍ សព្វថ្ងៃហៅវត្តពោធិព្រឹក្ស សង្កាត់រលាំងកែន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល មានលោកគ្រូ **ម៉ា កេត** ចៅអធិការវត្តនេះ ជាព្រះឧបជ្ឈាយ៍ ហើយសិក្សាបាលីព្រះត្រៃបិដក ក្នុងសំណាក់លោកគ្រូព្រះឧបជ្ឈាយ៍នេះបានពីរឆ្នាំ។

លុះដល់ ព.ស ២៤៤២ គ.ស ១៨៩៩ សាមណេរ **ណាត** និងកុមារ **នុត** បានលាមាតាបិតាមកនៅភ្នំពេញ តែមាតាបានឃាត់។ លោកទាំងពីរក៏ពណ៌នាផលនៃចំណេះវិជ្ជាជូនមាតាស្ដាប់។ មាតាប្រាប់ថា៖ បើកូនទៅជួញប្រែ មួយខែចំណេញមួយពាន់រៀល ក៏ម្ដាយមិនអោយទៅដែរ, ប៉ុន្តែកូនទៅរៀន ម្ដាយមិនហ៊ានឃាត់អោយដាច់អហង្ការទេ។

សាមណេរ **ណាត** បានទទួលសម្ដីប៉ុណ្ណោះ ក៏អោយញោមប្រុសជូនមកភ្នំពេញ។


ព្រះករុណាព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស (១៨៧៥-១៩៤១)

លោកតា **ជួន** ទឹមរទេះគោ ជូនកូនទាំងពីរមកដល់ភ្នំពេញ ចូលទៅផ្ទះលោកគ្រូអាចារ្យ **គឹម ហាស់** (ដែលតមកបានជាឧកញ៉ាសុធម្មមេធា) ជាញាតិទាក់ទងពីភូមិភ្នំបាត-ពពែជ្រៃលាស់។ លោកតាអាចារ្យ **គឹម ហាស់** គិតរកកន្លែងអោយក្មួយទាំងពីររៀន។ លោករកបានកន្លែងនៅកុដិលោកគ្រូព្រះគ្រូ **សោ** ខាងជើងព្រះវិហារ នៃវត្តឧណ្ណាលោម។ លោកគ្រូព្រះគ្រូ **សោ** បង្រៀនកុមារ **នុត** ខាងវិជ្ជាផ្លូវលោក ដើម្បីនឹងអោយធ្វើមន្ត្រី, បានអោយសាមណេរ **ណាត** រៀនប្រែគម្ពីរបាលីក្នុងសំណាក់លោកគ្រូអាចារ្យ **គឹម ហាស់** ។ តមក លោកគ្រូព្រះគ្រូ **សោ** បាននាំយកកុមារ **នុត** ទៅថ្វាយព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ មុនីវង្ស** ដើម្បីទ្រង់ប្រើប្រាស់ផ្ទាល់ព្រះអង្គ ក្នុងព្រះរាជដំណាក់(ជិតវត្តលង្កា)។ កុមារ **នុត** ទទួលភារៈខាងសរសេរថ្វាយ ហើយសូមព្រះរាជឱកាសរៀនអក្សរបារាំងផង។ ក្នុងឆ្នាំ...(អត់ចាំ) ព្រះអង្គម្ចាស់ **មុនីវង្ស** ទ្រង់ស្ដេចទៅស្រុកបារាំង ទុកយុវជន **ជួន នុត** អោយនៅចាំព្រះរាជដំណាក់ ទ្រង់អនុញ្ញាតអោយយកគ្រូបារាំងមកបង្រៀនផង។

ចំណែកខាងសាមណេរ **ជួន ណាត** ខំសិក្សាបាលីព្រះត្រៃបិដក ក្នុងសំណាក់លោកអាចារ្យ **គឹម ហាស់**, លោកអ្នកឧកញ៉ាសុធម្មប្រីជា **គង**, លោកគ្រូអាចារ្យ **វ៉ែត** ។ ដល់បានព្រះជន្មាយុ ២១ឆ្នាំ នៅថ្ងៃ ១៤កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៤៤៧ ត្រូវនឹងខែមិថុនា គ.ស ១៩០៤ លោកបានទៅសូមបំពេញឧបសម្បទាជាភិក្ខុនៅវត្តពោធិព្រឹក្ស ជាវត្តដើម មានព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ **ម៉ា**

**កេត**[5] (សុវណ្ណប្បញ្ញោ) ជាព្រះឧបជ្ឈាយ៍, ព្រះតេជព្រះគុណ **កែ ម៉ម** (មិស្សនាគា) និងព្រះតេជព្រះគុណ **អ៊ិន ខឹម** (តិក្ខប្បញ្ញោ) ជាឧបសម្បទាចារ្យ។ ភិក្ខុ **ជួន ណាត** បានទទួលនាមបញ្ញត្តិថា **ជោតញ្ញាណោ** ។ បានបួសជាភិក្ខុហើយ ត្រឡប់មកគង់នៅវត្តឧណ្ណាលោមវិញ ខំបន្តការសិក្សាគម្ពីរបាលីឥតមានការធុញទ្រាន់ បានសិក្សាមូល(វេយ្យាករណ៍បាលី) ក្នុងសំណាក់លោកអ្នកឧកញ៉ាសុធម្មមេធា **អ៊ុង** ទៀត បានជាអ្នកចេះដឹងគ្រាន់បើ ផ្សំទាំងវោហារការនិយាយស្ដីជាធម្មជាតិមានពីកំណើតស្រាប់ផង ក៏ភិក្ខុ **ជួន ណាត** បានជាទីរាប់អាននៃសហធម្មិក (ភិក្ខុសាមណេរដែលត្រូវការដោយធម៌ជាមួយគ្នា)។ ទាំងឧបាសក ឧបាសិកា ក៏ចូលចិត្តស្ដាប់ធម៌អាថ៌ដែលភិក្ខុ **ជួន ណាត** សម្ដែង។ ឧបាសកជាញាតិខ្លះ ដូចលោកអ្នកឧកញ៉ាមន្ត្រីរាជឫទ្ធិ **យក់** ជាដើម ក៏ទទួលស្គាល់ថាជាអ្នកចេះ ហើយបានរៀបចង្ហាន់ប្រគេនឆាន់ រាល់ថ្ងៃតរៀងមក។

ក្នុងឆ្នាំ ១៩០៦ ភិក្ខុ **ជួន ណាត** មានអាពាធជាទម្ងន់ គឺរោគពិសក្ដៅ ជាហេតុនាំអោយអ្នករាប់អាន ភ័យច្រួលច្របល់។ កាលនោះមានភិក្ខុមួយអង្គព្រះនាម **ខេង** គ្រាន់តែស្គាល់គ្នា ឥតជាប់ជាសាច់សាលោហិតទេ ទទួលខ្លួនទៅជំរាបលោកតា **ជួន** ឯភូមិកម្រៀង ដោយមានពុទ្ធដីកាថា៖ ផ្លូវគេដើរមួយថ្ងៃ ខ្ញុំនឹងដើរតែមួយល្ងាចអោយដល់ បើដាច់ខ្យល់ស្លាប់ ក៏ស្លាប់ខ្ញុំចុះ កុំអោយស្លាប់លោកអាចារ្យ **ណាត** ។

លោកតា **ជួន** ទទួលដំណឹងហើយថា កូនខ្ញុំមិនស្លាប់ទេ។ ព្រឹកឡើង លោកយាយ **យក់** វេចបាយកញ្ចប់ប្រគេនលោកត្រឡប់មកភ្នំពេញវិញ។ លោកគ្រូ **ខេង** ត្រឡប់មកភ្លេចឆាន់បាយកញ្ចប់ អត់ចង្ហាន់មួយព្រឹក រហូតដល់ភ្នំពេញបាននឹកឃើញ។

ប៉ុន្មានថ្ងៃកន្លងមក គ្រាដែលជាចាករោគហើយ ភិក្ខុ **ជួន ណាត** ឆ្លៀតរៀនអក្សរភាសាសៀមអំពីលោកតា **ទើត** ដរាបដល់ចេះសរសេរ ចេះនិយាយដូចសៀមសុទ្ធ ហើយគ្រាក្រោយមក ឆ្លៀតរៀនអក្សរភាសាបារាំងអំពីលោក **ជួន នុត** ជាប្អូនបង្កើតផង[6] ។

តមកព្រះភិក្ខុ **ជួន ណាត** និងព្រះភិក្ខុ **ហួត តាត** បានបន្តវិជ្ជាបារាំងអំពីលោកគ្រូ **ឡាំ អ៊ុម** និងលោក **ប៉ូលិសេ** ជាបារាំងសែស ជាចាងហ្វាងសាលា **ឌូដារដឺឡាគ្រេ** ទៀត។ ឆ្លៀតរៀនសំស្ក្រឹត

[5] ព្រះករុណាព្រះបាទសម្ដេចព្រះមុនីវង្ស ទ្រង់និមន្តព្រះតេជព្រះគុណអង្គនេះ ទៅធ្វើចៅអធិការវត្តវិហារសួគ៌។ ឯវត្តពោធិព្រឹក្សបានលោកគ្រូសូត្រ ម៉ម ជាចៅអធិការតមក។

[6] សម្ដេចព្រះសង្ឃនាយកព្រះនាម ហួត តាត បានថ្លែងបាឋកថាមួយ ក្នុងគ្រាបូជាសពអ្នកឧកញ៉ាសោភ័ណមន្ត្រី ជួន នុត ថា៖ លោកឧកញ៉ា ជួន នុត ជាគ្រូផ្ទាល់របស់អាត្មាក្នុងការសិក្សាអក្សរ ភាសាបារាំង ព្រោះគ្រាដែលលោកធ្វើលេខាធិការក្នុងក្រសួងសាធារណការ ដល់ពេលចេញពីការិយាល័យ លោកតែងចូលមកបង្រៀនសម្ដេចជាបង និងអាត្មានេះផង ដែលក្នុងជំនាន់នោះមានលោកសង្ឃតែពីររូបប៉ុណ្ណោះ រៀនបារាំងមុនគេ (សង្កថានេះ លោក ចាប បិន បានដាក់ក្នុងទស្សនាវដ្ដី កម្ពុជសុរិយា)។

អំពីក្លឹង្គឈ្មោះ **ឧនម្លៃ** ជរាបដល់ចេះសរសេរ អានអក្សរទេវនាគរី ជាហេតុអោយផលដល់អនាគត បានទៅបន្តវិជ្ជានេះឯក្រុងហាណូយទៀត។

ឆ្នាំ១៩០៨ លោកតា **ជួន** លោកយាយ **យក់** តាមកូនទាំងពីរមកនៅភ្នំពេញ, នៅជាមួយលោក **ជួន នុត** អ្នកស្រី **ព្រហ្ម ឪក** ដែលតាំងលំនៅ នៅខាងអគ្នេយ៍វត្តសារាវ៉ន ត្រង់កាច់ជ្រុងវិថីព្រះយុគន្ធរ និងមយវ៉ែន គឺត្រង់គេហដ្ឋានសម្តេចជហ្វា **ប៉ែន នុត** សព្វថ្ងៃ។ តមក លោក **ជួន នុត** អ្នកស្រី **ព្រហ្ម ឪក** បានសង់ផ្ទះថ្មីនៅបឹងរាំងប្របវត្តលង្ការ ក៏នាំគ្នាទាំងអស់ទៅនៅផ្ទះថ្មីនោះជាប់រហូត។



លោកឧកញ៉ាសោភ័ណមន្ត្រី ជួន នុត

មកដល់ថ្ងៃព្រហស្បត៍ ១១កើតខែស្រាពណ៍ ឆ្នាំខាលអដ្ឋស័ក ព.ស ២៤៦៩ ត្រូវនឹងថ្ងៃទី ១៩ ខែសីហា ឆ្នាំ១៩២៦ លោកយាយ **យក់** ទទួលអនិច្ចកម្មទៅក្នុងកំណត់ជន្មាយុ ៧៥ឆ្នាំ។ កន្លងមក ៤ឆ្នាំ គឺនៅថ្ងៃសៅរ៍ ១០កើត ខែជេស្ឋ ឆ្នាំមមីទោស័ក ព.ស ២៤៧៣ ត្រូវនឹងថ្ងៃទី ២១ ខែមិថុនា ឆ្នាំ១៩៣០ លោកតា **ព្រហ្ម ជួន** ទទួលអនិច្ចកម្មទៀត ក្នុងកំណត់ជន្មាយុ ៧៩ឆ្នាំ។ តមក ៤ឆ្នាំបន្ទាប់ទៀត គឺក្នុងឆ្នាំ ១៩៣៤ លោកយាយ **គំ** ម្តាយក្មេកលោក **ជួន នុត** ក៏ទទួលអនិច្ចកម្មទៀត អាយុ ៧៨ឆ្នាំ។ អដ្ឋិធាតុនៃជនទាំងបីរូបនេះ ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** និងលោក **ជួន នុត** បានសាងចេតិយមួយ មានកំពូល៤ ប្របមាត់ស្ទឹង ក្នុងវត្តពោធិព្រឹក្ស បញ្ចុះទុក, បានជាដីប្របមាត់ស្ទឹងនោះ ផ្នែកខាងស្រុកគងពិសី បញ្ចូលមកជាដីវត្តពោធិព្រឹក្សទៀត។ ប្របចេតិយនោះ ម្ខាងជាដីស្រុកកណ្តាលស្ទឹង ម្ខាងទៀតជាដីស្រុកគងពិសី...។




ចេតីយ៍កំពូលបួន នៅវត្តពោធិព្រឹក្ស ដែលដំកល់ អដ្ឋិធាតុមាតាបិតាសម្តេច
ព្រះសង្ឃរាជ ជួនណាត និងព្រះញាតិរបស់ព្រះអង្គ នាពេលបច្ចុប្បន្ន...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)









ដីប្របមាត់ស្ទឹងរាងស្វាបក្តោង ដែលលោកឧកញ៉ាសោភ័ណមន្ត្រី
ជួន នុត ជាវយកមកពង្រីកបរិវេណវត្តពោធិព្រឹក្ស...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)

ឆ្នាំ១៩១០ ភិក្ខុ **ជួន ណាត** កំពុងមានកិត្តិស័ព្ទ និងសេចក្ដីរាប់អានពីសំណាក់ជនច្រើនគ្នា ក៏លោកគ្រូព្រះសក្យវង្ស **នូត** រាជាគណៈត្រី (ទី៣) សព្វព្រះទ័យចង់តម្កុំតម្កើងអោយសមនឹងកិត្តិស័ព្ទ ក៏ប្រាប់ថា ខ្ញុំករុណាសុំលោកជួយធ្វើការខ្ញុំ, ខ្ញុំសូមតាំងលោកជាបាឡាត់សាក្យបុត្តីយ៍ ។

ព្រះបាឡាត់ **សាក្យបុត្តីយ៍ ជួន ណាត** បានឡើងសមណសក្តិតាមឋានានុក្រម ដែលជាកាំជណ្ដើរទីមួយ អាចឡើងទៅជារាជាគណៈបាន។ ក្នុងពេលភ្លាមៗនេះ ក៏ល្បីទូទ័រឡើងដល់អ្នកធម៌អ្នកអាចំច្រើនគ្នា គេក៏ជួយអនុមោទនា។ សូម្បីព្រះសង្ឃសមាទានធុតង្គនៅក្នុងព្រៃ ក៏សព្វព្រះទ័យកាត់មករកជួបដែរ។ ព្រះបាឡាត់ **សាក្យបុត្តីយ៍ ជួន ណាត** សន្ទនាជាមួយនឹងលោកតាធុតង្គមួយព្រះអង្គត្រង់ធម៌សមាធិកម្មដ្ឋាន ក៏មានព្រះទ័យទន់ទៅរកការធុតង្គ ប្រុងប្រៀបព្រះអង្គជាស្រេចថា នឹងទៅគង់នៅក្នុងព្រៃភ្នំជាមួយនឹងលោកតាអង្គនេះ។

ប្រហែលគំនិតនេះ ប្រទាំងគ្នានឹងឧបនិស្ស័យដែលធ្លាប់សន្សំមកទេដឹង បានជាក្នុងបច្ឆិមយាមរាត្រីមួយ ព្រះបាឡាត់សាក្យបុត្តីយ៍ បានឃើញសុបិននិមិត្តថា៖ លោកបានឡើងលើភ្នំមួយខ្ពស់ ទៅដល់ជំនីរភ្នំដែលមានដើមឈើធំៗ ស្លឹកលាស់ត្រសាយត្រសុំ ម្លប់ត្រឈឹងត្រឈៃជីត្រជាក់ ក៏ស្ម័គ្រព្រះទ័យចង់គង់នៅក្នុងទីនោះ។ ស្រាប់តែមានគំនិតមួយទៀតថា ត្រូវឡើងអោយផុតកំពូលភ្នំនេះ។ លោកក៏ខំឡើងរហូតដល់ផុតកំពូលភ្នំ ក្រឡេកមើលទៅទិសជុំវិញទាំងអស់ ឃើញអ្វីៗ ឥតសល់ចន្លោះទេ[7] ។

ព្រឹកឡើង លោកតើនពីសឹង គង់លើសំណឹងរំពឹងសុបិនដែលបានឃើញនោះ យល់សេចក្ដីថា៖ *«មិនគួរផ្ដាកការសិក្សាព្រះត្រៃបិដកទេ, ឯគំនិតដែលគិតទៅធ្វើធុតង្គនោះ ជាការប្រពៃហើយ, ប៉ុន្តែបានត្រជាក់ស្រួលខ្លួនតែម្នាក់ឯង»* ។

តមក ព្រះបាឡាត់ **សាក្យបុត្តីយ៍ ជួន ណាត** សង្វាតសំភីក្នុងការទេតគម្ពីរសោស្ត្រាបាលី យល់សេចក្ដីកាន់តែជ្រៅទៅជាលំដាប់ ដែលសន្មត់ថា ជាអ្នកប្រាជ្ញខាងបាលី និងព្រះពុទ្ធសាសនាបានពេញលក្ខណៈ។

---

[7] គម្ពីរសារត្ថសង្គហបាលីមានចែងសេចក្ដីថា ការយល់សប្តិកើតឡើងដោយហេតុបួនយ៉ាងគឺ៖ ១- ដោយការពុលអាហារ (មិនទៀងទេ), ២- ដោយការកម្រើកធាតុ គឺពុំស្រួលខ្លួន(មិនទៀងទេ), ៣- ដោយទេវតាពន្យល់ ចែកចេញជាពីរយ៉ាង គឺទៀងនិងមិនទៀង។ បើទេវតាស្រឡាញ់ ហើយចង់អោយដឹងផលអនាគត ទើបពន្យល់អោយឃើញការទៀង, បើទេវតាខឹង ស្អប់, ទេវតាពន្យល់បង្វែងគំនិតអោយថ្លោះការ, ៤- ដោយបុព្វនិមិត្ត គឺផលបុណ្យដែលសាងពីអតីតបម្រុងអោយផលនោះ តែងយលសប្តិឃើញមុនជាការពិតប្រាកដណាស់ ដូចព្រះសិទ្ធត្ថជាម្ចាស់ ដែលឃើញបុព្វនិមិត្តមុនពេលបានត្រាស់ដូច្នោះ។ ឯសុបិន្តនិមិត្តរបស់ព្រះតេជព្រះគុណព្រះបាឡាត់សាក្យបុត្តីយ៍ ជួន ណាត នេះ ខ្ញុំយល់ថា ជាបុព្វនិមិត្តពិតប្រាកដ... (ឈឹម ស៊ុម) ។

ក្នុងឆ្នាំ១៩១២ ព្រះបាទឡាត់ **សាក្យបុត្តីយ៍ ជួន ណាត** បានឃើញសុបិននិមិត្តចម្លែកម្តងទៀតថា៖ លោកបានឡើងគាល់សម្តេចព្រះមហាសង្ឃរាជ ព្រះបរមនាម **ទៀង** ។ សម្តេចមានព្រះរាជឱង្ការថា៖ លោកបាឡាត់ **ណាត** ចេះអានបាលីត្រឹមត្រូវណាស់, ភាសាខ្មែរក៏ **ណាត** ចេះនិយាយច្បាស់, ទេសក៏ពិរោះ, តើអណ្តាតលោកយ៉ាងណា? ហាមាត់ឡើង សុំមើលអណ្តាតផង...។ លោកក៏ហាព្រះឱស្ឋឡើង។ សម្តេចព្រះមហាសង្ឃរាជ ទ្រង់ខាកស្តោះដាក់ព្រះឱស្ឋលោក។ លោកខំស្តោះចេញយ៉ាងណា ក៏កំហាកនោះពុំព្រមចេញសោះ ទាល់តែលេបចូលទៅក្នុងពោះបាត់វិញទៅ ដោយកិរិយាខ្ពើមឆ្អើមដ៏ក្រៃលែង[8] ។




បន្ទាប់ពីនោះមក ថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩១២ សម្តេចព្រះមហាសង្ឃរាជ **ទៀង** មានព្រះរាជឱង្ការអោយនិមិន្តព្រះបាទឡាត់សាក្យបុត្តីយ៍ឡើងគាល់។ លោកក៏ឡើងទៅក្រាបបង្គំគាល់សម្តេច ក្នុងចំណោមព្រះរាជាគណៈត្រៀបត្រា។ សម្តេចមានព្រះរាជឱង្ការសរសើរគុណសម្បត្តិរបស់ព្រះបាឡាត់ សាក្យបុត្តីយ៍ ជាអនេកប្រការ ហើយទ្រង់ក៏តាំងជា **ព្រះគ្រូសង្ឃសត្ថា** (ឋានានុក្រមថ្នាក់ទី១ សម្រាប់សម្តេចព្រះមហាសង្ឃរាជ) ជាគូគ្នានឹងព្រះគ្រូ **ហួត តាត** ដែលកាលពី១៥ថ្ងៃមុន ត្រូវបានសម្តេចព្រះមហាសង្ឃរាជ **ទៀង** តាំងជា **ព្រះគ្រូសង្ឃវិជ្ជា** រួចហើយ។

កិត្តិស័ព្ទនេះ ល្បីខ្ចរខ្ចាយសាយភាយពេញទាំងវត្តឧណ្ណាលោម ព្រមទាំងគេហដ្ឋាននៃឧបាសកឧបាសិកាជើងវត្ត។ ហេតុដូច្នេះ បានជាវេលាព្រឹកស្អែកឡើងនោះ មានទាយក ទាយិកាច្រើនគ្នា បានយកចង្ហាន់ទៅថ្វាយសម្តេចព្រះមហាសង្ឃរាជផង ប្រគេនលោកគ្រូព្រះគ្រូសង្ឃសត្ថាផង ដោយមានអំណរចំពោះការតែងតាំង និងការទទួលតំណែងថ្មីនេះ។ គ្រានោះ ពួកចិននៅផ្សារមាត់ទន្លេមកច្រើននាក់ មានឧបាសិកាចិនម្នាក់ឈ្មោះថៃ **ណាយ** បានរ៉ាប់រងប៉ាក់ផ្ចិតឱនមួយ សម្រាប់ងារព្រះគ្រូសង្ឃសត្ថា ហើយបវារណាធ្វើចង្ហាន់ប្រគេនរាល់ព្រឹកតទៅ។ លោកឧកញ៉ាមន្ត្រីរាជឫទ្ធិ **យក់** ដែលកន្លងមកបានជា ឧកញ៉ាជំនះសង្គ្រាម ចៅហ្វាយស្រុក ខេត្តក្រគរ ក៏អញ្ជើញមកថា៖ លោកណាឆាន់ចង្ហាន់ខ្ញុំ លោកនោះបានជាអ្នកប្រាជ្ញ...។ល។

---

[8] ព្រះថេរៈអង្គខ្លះ ដែលទើបបានឮសម្តេចព្រះសង្ឃរាជ ជួន ណាត មានព្រះបន្ទូលពីសុបិននេះ ក៏យល់ថា សម្តេចទើបនឹកឃើញ។ ប៉ុន្តែគ្រួសាររបស់ខ្ញុំ មានម្តាយក្មេកខ្ញុំជាដើមថា សុបិននេះសម្តេចបានឃើញក្នុងគ្រារៀបទទួលងារជាព្រះគ្រូសង្ឃសត្ថា ព្រោះកាលនោះ សម្តេចបានជម្រាបលោកតា ជួន មុនគេ ហើយលោកតា ជួន បានព្យាករណ៍សុបិននោះផង (ឈឹម ស៊ុម)។

ឆ្នាំ១៩១២ ព្រះតេជព្រះគុណ **ព្រះគ្រូសង្ឃសត្ថា ជួន ណាត** បានងារថ្មី បានសេចក្តីរាប់អានច្រើនអំពីក្រុមពុទ្ធសាសនិក ហើយប្រហែលជាមានព្រះទ័យរំភើបដោយលោកធម៌ខ្លះដែរដឹង? បានជាក្នុងគ្រានោះ លោកសរសេរអត្ថបទកំណាព្យមួយ អោយឈ្មោះថា **កាព្យលោកធម៌** ដែលជានិពន្ធដំបូងបំផុតរបស់លោក (មាននៅខាងចុង)។

ខ្ញុំយល់តាមការសង្កេតឃើញផ្ទាល់៖ ព្រះថេរៈអង្គនេះ មិនចេះអួតខ្លួន ព្រមទាំងស្អប់មនុស្សអួតខ្លួនឯងផង, មិនចេះឡើងជោរ ព្រមទាំងស្អប់មនុស្សជោរផង, មិនចេះត្អូញត្អែរពីការខ្វះខាត និងសេចក្តីទុក្ខលំបាក ព្រមទាំងពុំសូវពេញព្រះទ័យនឹងមនុស្សត្អូញច្រើនផង...។ ទោះបីព្រះថេរៈអង្គនេះ មានចរិយាដូច្នេះក៏មែនពិត, ប៉ុន្តែក្នុងគ្រានោះ ប្រហែលជាមានព្រះទ័យរំភើបខាងក្នុងខ្លះ បានជាលោកទាញគម្ពីរបាលីមកបើកទតត្រង់រឿងលោកធម៌ ហើយសរសេរប្រែមកជាសម្រាយចងក្រងជាពាក្យកាព្យទៀត ដើម្បីសង្កត់នូវសេចក្តីរំភើបខ្លះដែលមានក្នុងព្រះទ័យ។




ឆ្នាំ១៩១៣ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ប្រារព្ធអោយចាត់ការប្រឡងអ្នកចេះបាលី ដែលជំនាន់នោះហៅថា «ដេញប្រយោគ» ។ ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា បានចូលជាបេក្ខជនដេញប្រយោគដែរ ដោយប្រែបាលីគម្ពីរ **ធម្មបទ** តាមរបៀបលោតប្រយោគ ព្រមទាំងសួរវេយ្យាករណ៍ឥតទាល់ បានជាប់ជាមហា ៣ប្រយោគ ហើយប្រែគម្ពីរ **មង្គលត្ថទីបនី** ទៀតឥតទាល់ បានជាប់ជាមហា ៤ប្រយោគ ផុតថ្នាក់ត្រឹមប៉ុណ្ណោះក្នុងជំនាន់នោះ។ ក្នុងសម័យប្រឡងនោះ សម្តេចព្រះសង្ឃនាយក **ហួត តាត** បានជាប់ជាមហា ៤ប្រយោគដែរ។ សម្តេចព្រះសព **ល្វី ឯម** ជាបេក្ខជនមួយរូបដែរ ចូលដេញប្រយោគមុនគេ ឈ្មោះនឹងមេប្រយោគពីរឿងបាលី «កថេសិ» មិនព្រមថា «កថៃសិ», គេថា «ពោលហើយ» លោកថា «សម្តែងហើយ» ជាដើម, មិនព្រមចុះសម្រុងគ្នា មិនបានបន្តការដេញប្រយោគតទៅទៀត ព្រោះគេចាត់ជាមនុស្សរបឹង...។

ឆ្នាំ១៩១៥ រាជការព្រះករុណាជាអម្ចាស់ជីវិត និងរាជការអាណាព្យាបាលបារាំង អោយលើកសាលាបាលីពីអង្គរវត្ត ខេត្តសៀមរាប មកតាំងនៅភ្នំពេញវិញ ជាសាលាបាលីជាន់ខ្ពស់ បង្កើនថ្នាក់ចាត់របៀបថ្មី ត្រូវជ្រើសរើសរកសាស្ត្រាចារ្យដោយការប្រឡង។ ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា បានជាបេក្ខជនសាស្ត្រាចារ្យមួយរូបដែរ, បានប្រឡងជាប់លេខ២ មានសេចក្តីសរសើរខ្ពស់បំផុត ខាងមុខប្រែបាលី

ជាខ្មែរ និងប្រែខ្មែរជាបាលីត្រង់រឿងសុវណ្ណសាមជាតក ឥតមានតក់ឆ្គង ហើយឧកញ៉ាកក្តីរាជា **យ៉ាំខ** បាឡាត់ខេត្តគងពិសី ជាប់លេខ១, សម្ដេច **ល្វី ឯម** ជាប់លេខ៣, ឧកញ៉ាសុធម្មប្រីជា **ភខ** រាជបណ្ឌិត (គ្រូសម្ដេច) ជាប់លេខ៤ ។

ឆ្នាំ១៩១៥ ដដែល រាជការព្រះករុណា និងរាជការអាណាព្យាបាលបារាំង បានបង្កើតគណៈកម្មការមួយធ្វើ **វចនានុក្រមខ្មែរ** ដែលមានសម្ដេចចក្រី **ពេជ្រ ប៉ុណ្ណ** សេនាបតីក្រសួងសិក្សាធិការជាប្រធាន។ ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា ត្រូវបានតាំងដោយព្រះរាជប្រកាស អោយធ្វើជាស្មៀន (លេខាធិការ) សម្រាប់កត់ត្រា ព្រមទាំងរៀបចំពាក្យពេចន៍ដែលក្រុមជំនុំបានសម្រេចហើយ។

ឆ្នាំ១៩១៧ ព្រះតេជព្រះគុណព្រះមហាវិមលធម្ម **ថោង** បានចាត់តាមពាក្យសុំនៃលោកអ្នកឧកញ៉ាអធិបតីសេនា **ភេត** អោយព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត**, ព្រះតេជព្រះគុណព្រះគ្រូសង្ឃវិជ្ជា **ហួត តាត**, ព្រះតេជព្រះគុណព្រះគ្រូវិមលប្បញ្ញា **អ៊ុម ស៊ូរ** ធ្វើសៀវភៅ *សាមណេរវិន័យ* ។ ព្រះថេរៈទាំង ៣អង្គបានធ្វើសៀវភៅនេះជាបាលី និងសម្រាយ និយាយអំពីសិក្ខាបទ ១០, ទណ្ឌកម្ម ១០, នាសនង្គៈ ១០ សេក្ខិយវត្ត ៧៥ និង បច្ចវេក្ខណវិធីទាំង ៤ សុទ្ធតែមានអាងគម្ពីរបាលីដើមយ៉ាងជាក់ច្បាស់។ ប៉ុន្តែសៀវភៅនោះកើតឡើងជាទំនាស់នឹងទំនៀមទម្លាប់បព្វជិតខ្មែរដែលកាន់ពុទ្ធសាសនារៀវរោយដោយស្រុកកើតកលយុគយូរឆ្នាំមកហើយ។




ខ្ញុំ(ឈឹម ស៊ុម) បានបួសទាន់សម័យនោះ ខ្ញុំដឹងថា បព្វជិតខាងគណៈមហានិកាយ មានតែលោកភិក្ខុទេ ទើបមានត្រៃចីវរគ្រប់គ្រាន់ ព្រមទាំងចេញក្រៅវត្ត ឃ្លុំចីពរជិតស្មាទាំងសងខាង ជាបរិមណ្ឌលផង។ ប្លែកតែសាមណេរ ដែលគេហៅថា នេនៗ នោះកម្មក្រាស់ណាស់។ វត្តខ្លះគេអោយប្រើតែស្បង់ និងហង្សៈពាក់សំបត់ង្វតលើស្មា, វត្តខ្លះគេអោយមានចីពរដែរ ប៉ុន្តែទៅកាន់ទីណាក៏ដោយ គេអោយគ្រាន់តែគ្រងឆៀងស្មាម្ខាង ហើយឆាន់ចង្ហាន់សល់ពីលោកភិក្ខុ និងក្រោយលោកភិក្ខុទៀត។ សមណេរទាំងនោះកាលបួស ក៏លោកអ្នកបំបួសអោយសមាទានត្រឹមតែសរណគមន៍ ៣ និងសីល ១០ ប៉ុណ្ណោះ។ លុះបួសហើយ លោកគ្រូខំបន្តឹងខាងបច្ចវេក្ខណវិធីឯណោះទៅវិញ គឺតឹងត្រង់អតីតបច្ចវេក្ខណៈដែលជំនាន់នោះហៅថា ចម្រើនអជ្ជៈ ។ លោកគ្រូអោយសូត្របាលីសុទ្ធដល់ទៅ ១០៨ចប់ ក្នុងមួយថ្ងៃៗ, ប៉ុន្តែឥតអោយដឹងសេចក្ដីដូចម្ដេចទេ។

សៀវភៅ ***សាមណេរវិន័យ*** កើតឡើង ជាទំនាស់នឹងទំនៀមនេះច្រើនអន្លើគឺៈ អោយសាមណេរបួសដូចខាងដើមនេះហើយ ត្រូវអោយសុំនិស្ស័យទៀត, ត្រូវអោយរក្សាសិក្ខាបទ ១០, ទណ្ឌកម្ម ១០, នាសនង្គៈ ១០ សេក្ខិយវត្ត ៧៥ ហើយត្រូវចូលវស្សា ត្រូវមានសិទ្ធិទទួលសំពត់ចំណាំវស្សា ដូចលោកភិក្ខុដែរ ត្រូវឃ្លុំចីពរជាបរិមណ្ឌល (ឃ្លុំលើស្មាសងខាង) ក្នុងពេលចេញក្រៅវត្ត ដូចលោកភិក្ខុដែរ។ ឯបច្ចវេក្ខណវិធី មិនមានកំរិតអោយសូត្រដល់ទៅ ១០៨ ចប់ទេ, ប៉ុន្តែមានកម្រិតថា លុះណាតែយល់សេចក្តីនៃធម៌ដែលភាវនានោះ ទើបពេញលក្ខណៈត្រឹមត្រូវ។

សម្តេចព្រះសង្ឃនាយកព្រះនាម **ហួត តាត** ដែលខ្ញុំក្រាបបង្គំទូលសួរ លោកមានព្រះពុទ្ធដិកាថា៖ សៀវភៅសាមណេរវិន័យកើតឡើង នៅជាសរសេរអក្សរដោយដៃ ក៏លោកអ្នកឧកញ៉ាមហាឥស្សរា **កេត** សុំអោយអាត្មាចាត់ការបោះពុម្ព។ អាត្មាប្រគល់ជូនលោក ដើម្បីសុំអនុញ្ញាតអំពីសម្តេចព្រះសង្ឃនាយក។ កាលសម្តេចព្រះសង្ឃនាយកពុំព្រមអនុញ្ញាត, លោកក៏កាន់សៀវភៅនេះ ទៅជម្រាបលោក **ឡឺរ៉េស៊ីដង់ត៍ ស៊ូប៉េរីយើរ** (បារាំងសែស ជាប្រមុខនៃរដ្ឋការបារាំងនៅប្រទេសកម្ពុជា) ហើយលោកយកមកប្រគល់អោយអាត្មាវិញថាៈ សូមចាត់ការបោះពុម្ពចុះ។ អាត្មាអោយបោះពុម្ព ៥០០០ក្បាល ចេញថ្លៃខ្លួនឯង ១០០០ក្បាល, សម្តេចព្រះសង្ឃរាជ **ជួន ណាត** កាលនៅជាព្រះគ្រូសង្ឃសត្ថា យក ១០០០ក្បាល, លោកគ្រូវិមលប្បញ្ញ **អ៊ុំ ស៊ូ** យក ១០០០ក្បាល, លោកមហាឥស្សរា **កេត** ក៏យក ១០០០ក្បាល, សម្តេច **លី ឯម** កាលលោកនៅជាព្រះញាណបវរវិជ្ជា យកប៉ុន្មានរយក្បាល ដើម្បីចែកក្នុងពិធីបុណ្យខ្លះ ចែកមិត្តភក្តិរៀនសូត្រខ្លះ។ លោកគ្រូព្រះញាណបវរវិជ្ជា **លី ឯម** យកទៅថ្វាយព្រះអង្គម្ចាស់ **មុនីវង្ស** ខ្លះ ព្រមទាំងពន្យល់សេចក្តីថ្វាយសព្វគ្រប់ផង។

លោកគ្រូអាចារ្យ **ចាន** នៅវត្តកោះសុទិន និងលោកគ្រូអាចារ្យ **គល់** នៅស្វាយរៀង អោយនេនឃ្លុំផង ជាអ្នកទេសនាផង និយាយផង តាមទំនងសៀវភៅនេះ នាំអោយស្រកៀរគ្រចៀកនៃអ្នកបួសតាមទំនៀមទម្លាប់ ថែមទាំងមានការអោយដៃ ពីភ្នំពេញទៅខ្លះផង ក៏បុព្វជិតខេត្តក្រៅទាំងអស់ស្ទើរគ្រប់វត្តធ្វើពាក្យប្តឹងចោទប្រកាន់ពីលោកទាំង ៣អង្គ អ្នកធ្វើសៀវភៅ ***សាមណេរវិន័យ*** នេះថាៈ

- លោកទាំង ៣អង្គនេះ បដិសេធគម្ពីរសម្រាយខ្មែរបូរាណថា សុទ្ធតែខុសប្រើការពុំបាន, អម្បាលគម្ពីរមហាជាតក ក៏គេបដិសេធថាខុសដែរ។
- លោកទាំង ៣អង្គនេះ ជៀលត្មះអ្នកបួសមុនៗ ថាពុំត្រឹមត្រូវ ព្រោះបួសនេន ឥតសុំនិស្ស័យ។
- លោកទាំង ៣អង្គនេះ ធ្វើអោយលោកនេន និងលោកភិក្ខុ ច្រឡំគ្នាអស់។




កំហុសឆ្គងខាងលើនេះ សូមជំនុំសង្ឃជាន់ខ្ពស់ ត្រូវតែ «**ចាប់ផ្សឹកព្រះថេរៈទាំង ៣អង្គនេះ ដើម្បីបណ្តេញចេញពីវត្ត**...» ។

សម្តេចព្រះសង្ឃនាយក **អ៊ុក**[9] ក្រោយពេលដែលជំនុំសង្ឃ បានប្រជុំព្រមព្រៀងថា ត្រូវអោយបណ្តាញចេញហើយ ក៏ធ្វើដីការអមថ្វាយទៅព្រះករុណាសជាអម្ចាស់ជីវិតព្រះបាទសម្តេចព្រះ **ស៊ីសុវត្ថិ**។ ព្រះករុណាជាអម្ចាស់ជីវិតទ្រង់ឲ្យប្រជុំព្រះសង្ឃច្រើនអង្គក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ។ លោកគ្រូព្រះញាណបវរវិជ្ជា **ល្វី ឯម** អោយក្មេងយកគម្ពីរបាលីដើមបីបួនគម្ពីរទៅទុកនៅថែវវាំងខាងកើត បម្រុងការទុកជាសំអាង។

ព្រះអង្គម្ចាស់ **មុនីវង្ស** ក្រោយពេលដែលទ្រង់ទតសៀវភៅសាមណេរវិន័យនោះសព្វគ្រប់ ទ្រង់ជ្រាបច្បាស់សេចក្តីព្រះវិន័យនោះ ដោយសារលោកគ្រូព្រះញាណបវរវិជ្ជា **ល្វី ឯម** បានយកទៅថ្វាយ បានពន្យល់សេចក្តីអធិប្បាយ ពីគ្រាមុនមកស្រេចហើយនោះ ទ្រង់ឡើងទៅក្រាបបង្គំគាល់ព្រះករុណាជាអម្ចាស់ជីវិត។ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ត្រាស់ព្រះរាជឱង្ការថា៖ *កូនអើយកូន! ឥឡូវគេប្តឹងពីគ្នាហើយ។ ព្រះអង្គម្ចាស់ក្រាបបង្គំទូលសួរថាៈ សូមទ្រង់ព្រះមេត្តាប្រោស! នរណាប្តឹងពីនរណា? នេះនែ៎! អស់លោកនេះណាកូន! ប្តឹងពីលោកអ្នកធ្វើសៀវភៅនេះ។ អស់លោកហ្នឹងដឹងអីលោក! សៀវភៅហ្នឹង ទូលព្រះបង្គំមើលសព្វគ្រប់ហើយ ត្រឹមត្រូវរបស់គេណាស់..!!..*





ពីឆ្វេងទៅស្តាំៈ ព្រះគ្រូសង្ឃសត្ថា ជួន ណាត, ព្រះគ្រូសង្ឃវិជ្ជា ហួត តាត, និងព្រះគ្រូវិមលប្បញ្ញា អ៊ុម ស៊ូរ ដែលបានតាក់តែងសៀវភៅ សាមណេរវិន័យ ធ្វើអោយក្រុមមន្ត្រីសង្ឃអភិរក្សមិនសប្បាយចិត្ត រួចបានជំនុំសង្ឃជាន់ខ្ពស់បំរុងចាប់ផ្សឹកព្រះគ្រូទាំង ៣អង្គនេះ ដើម្បីបណ្តាញចេញពីវត្ត នៅក្នុង គ.ស ១៩១៧...

[9] សម្តេចព្រះសង្ឃរាជ ជួន ណាត ទ្រង់មានព្រះបន្ទូលប្រាប់ខ្ញុំថាៈ សម្តេចព្រះសង្ឃនាយក អ៊ុក មានយោបល់ល្អក្នុងរឿងនេះ ប៉ុន្តែជំនុំសង្ឃសម្រេចដូច្នោះស្រេចទៅហើយ លោកក៏ត្រូវតែធ្វើដីកាអមបញ្ជូន។

លោកអ្នកឧកញ៉ាយោធានរិន្ទ ភូឈួយក្រសួងធម្មការ ដែលគេស្គាល់ថា ជាបរបក្សសោះ ក៏បែរជាកាន់សៀវភៅនេះដែរ ដោយប្រែគំនិតសង្ឃឹមថា នឹងបានជាគ្នាក្នុងអនាគត។

ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ព្រះបុច្ឆា(សួរ) លោកគ្រូសង្ឃសត្ថា **ជួន ណាត** ម្តេចក៏លោកបដិសេធគម្ពីរសាស្ត្រាបូរាណ ថាសុទ្ធតែខុស?... អម្បាលគម្ពីរមហាជាតក ដែលគេចូលចិត្តស្តាប់ម្លឹងៗ ក៏លោកហ៊ានថាខុសដែរ?

«ថ្វាយព្រះពរ... អាត្មាភាពបានថាខុសមែន ព្រោះសម្រាយចេះតែលើសពីបាលី ច្រើនអន្លើ, អាត្មាភាពយល់ថា អ្នកធ្វើសេចក្តីសម្រាយ គ្រាន់តែអោយអ្នកស្តាប់សប្បាយចិត្តប៉ុណ្ណោះទេ ដូចពាក្យថា៖ "*ជូជក មានរូបអន្ធការ ស្តួមខ្ពស់ជ្រដោង ខ្នងកោង លោងស្គាតដំបារ ត្រចៀកយុរយារក្រាស់ដូចឃ្លង់ភ្លើង ជើងកោងដូចសេក ភ្នែកស្រលៀងស្រឡេ សាច់ពកដូចគេធ្វើ វេបិរដុបយុរយារ*" នេះក៏ឥតបាលីដែរ... ឬដូចពាក្យថា "*ជូជក បែកពោះផ្ទុង ដំរីពាំងពាទ័ខ្វារ*" ជាដើម ក៏សុទ្ធតែជាពាក្យលើសពីបាលីដែរ។ អាត្មាភាពមានបដិសេធឯណា គ្រាន់តែប្រាប់គ្នាថា បាលី និងសម្រាយខុសគ្នាប៉ុណ្ណោះទេតើ! សូមថ្វាយព្រះពរ»...។

តមក ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់និមន្តលោកគ្រូសង្ឃសត្ថា អោយទេសគាថាពាន់(មហាជាតក), ទ្រង់បូជាបច្ច័យច្រើនហើយទ្រង់ត្រាស់ព្រះរាជឱង្ការថា៖ *លោកណាចង់កាន់វិន័យត្រឹមត្រូវ ក៏កាន់ទៅ, លោកណាមិនចង់កាន់ ក៏ស្រេចតែលោកចុះ កុំឈ្លោះគ្នា...។*

សម្តេចព្រះធម្មលិខិត **ល្វី ឯម** ធ្លាប់ដំណាលរឿយៗថា៖ កាលនោះ គេយកលោកគ្រូអាចារ្យ **គល់** និងលោកគ្រូអាចារ្យ **ចាន** មកឃុំទុកក្នុងវត្តឧណ្ណាលោម។ ឆាន់[10] បានជានាយកលោកគ្រូអាចារ្យទាំងពីរអង្គនេះ ទៅអោយគង់នៅឯវត្តលង្ការិញ ដោយទទួលខុសត្រូវលើខ្លួន។ លោកអធិបតីសេនា **ភេត** អញ្ជើញទៅវត្តលង្កាប្រាប់ឆាន់ថាៈ ក្រសួងធម្មការ អោយយកខោខ្មៅ អាវខ្មៅ មកទុកស្រេចហើយ ដើម្បីផ្សឹកលោកគ្រូអាចារ្យ **គល់** និងលោកគ្រូអាចារ្យ **ចាន** ធ្វើទោស ព្រោះជាអ្នកនាំបង្កើតចលាចល។ ឆាន់បានដឹងដំណឹងនេះ ក៏ទៅថ្វាយព្រះពរព្រះអង្គម្ចាស់ **មុនីវង្ស** ។ ព្រះអង្គម្ចាស់ទ្រង់ស្តេចយាងទៅព្រះបរមរាជវាំង ក្រាបបង្គំទូលសុំព្រះករុណាជាអម្ចាស់ជីវិត ទារយកសំណុំរឿងមកពិនិត្យផ្ទាល់ព្រះអង្គ។ ព្រះករុណាជាអម្ចាស់ជីវិតទ្រង់យកសំណុំរឿងពីក្រសួងធម្មការ ទ្រង់ពិគ្រោះជាមួយនឹងព្រះអង្គម្ចាស់**មុនីវង្ស** ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ(ចង់) ទ្រង់ព្រះសណ្តាប់មហាជាតក ក៏ទ្រង់និមន្តលោកគ្រូសង្ឃសត្ថា **ណាត** អោយសម្តែង។ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់រីករាយក្នុងព្រះរាជហឫទ័យណាស់ ទ្រង់បូជាដោយ

[10] ស្មើនឹងពាក្យ «ខ្ញុំ» ជាពាក្យសម្រាប់ព្រះថេរៈ និយាយចេញឈ្មោះខ្លួនថា ខ្ញុំ ទៅរកគិក្ខុខ្ញីវស្សា ឬសាមណេរ ។

បច្ច័យទាំងក្រឡាន ទ្រង់បញ្ចប់រឿងនេះ ដោយព្រះរាជឱង្ការថា៖ *លោកណាចង់បតិបត្តិព្រះវិន័យក៏ជាការល្អ, លោកណាចង់បតិបត្តិតាមទំនៀមទម្លាប់ ក៏ស្រេចតែនឹងលោកចុះ... ឈប់ឈ្លោះគ្នាទៅ។*

តពីនោះមក មានមន្ត្រីម្នាក់សម្តែងកិរិយាស្និទ្ធស្នាល សង្ឃឹមថានឹងយកជាគ្នាបានហើយ ក៏និយាយថា ថៅហ្វាយធំរបស់ខ្ញុំ ចង់សុំព្រះតេជព្រះគុណធ្វើជាកូន, បើព្រះតេជព្រះគុណចាកសិក្ខាបទ, នឹងចែកមរត៌កស្មើនឹងកូនបង្កើត ហើយនឹងជ្រោងអោយដល់ឋានៈខ្ពង់ខ្ពស់, ឬបើនៅជាបព្វជិត អោយចេញទៅបួសនៅវត្តឯណោះវិញ, នឹងជ្រោងអោយដល់ឋានៈខ្ពស់បំផុត។ ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា ឆ្លើយថា៖ *អាត្មាបួសតាំងពីក្មេង មកដល់អាយុប៉ុណ្ណេះ មិនមែនដើម្បីទ្រព្យសម្បត្តិ ឬឋានៈខ្ពង់ខ្ពស់អ្វីទេ! មួយទៀត អាត្មាគោរពត្រឹមតែព្រះករុណាជាអម្ចាស់ជីវិត និងច្បាស់របស់រដ្ឋ ព្រមទាំងវិន័យព្រះពុទ្ធប៉ុណ្ណោះ! ឥឡូវអាត្មាចេះមើលវិន័យព្រះពុទ្ធ យល់ច្បាស់ខ្លួនឯងហើយ មិនបាច់រកគ្រូណាបំបួសទៀតទេ...។*

តពីនោះមកទៀត ការសម្តែងកិរិយាខឹងស្អប់ ចេញអំពីប្រភពនៃជនជាបរបក្ស កាន់តែមានប្លែកឡើងៗគឺៈ ជនខ្លះលបចោលដោយដុំឥដ្ឋ ធ្លាយដំបូលកុដិញឹកៗ, ជនខ្លះយកសៀវភៅសាមណេរវិន័យមកច្រៀករហែករហុយ ចងព្យួររតេងរតោងតែពាសតាមផ្លូវក្នុងវត្ត, ជនខ្លះមិនព្រមហៅឈ្មោះ ឬងារទេ គេបង្កើតងារថ្មីអោយថាៈ ពួកធម៌ថ្មី, ពួកធម្មកាយ, ពួកចីពរខ្មៅ, ពួកលោកសង្ឃបារាំង, ពួកលិង្គថេនកៈ[11] ពួកពុករលួយឬសគល់ (ព្រោះបួសមិនត្រឹមត្រូវ), ពួកបំបួសសត្វនាគ (ព្រោះសូត្រញត្តិថា នាគោ)...។

ក្នុងសម័យដែលគេកំពុងតែស្អប់ច្រើនគ្នា ស្រាប់តែមានព្រះរាជប្រកាស ១ច្បាប់ លេខ ៧១ កើតឡើងដោយសេចក្តីព្យាយាមរបស់អ្នកឈ្នានីស។ ព្រះរាជប្រកាសនោះ មានចំណុចមួយថាៈ គណៈមហានិកាយ ត្រូវប្រតិបត្តិតាមទំនៀមទម្លាប់សម្តេចព្រះមហាសង្ឃរាជ **ទៀង**, គណៈធម្មយុត្តិកនិកាយ ត្រូវប្រតិបត្តិតាមទំនៀមទម្លាប់សម្តេចព្រះសុគន្ធាធិបតី **ប៉ាន** ។

ចំណុចនេះ ជាហេតុអោយអ្នកប្រតិបត្តិតាមធម៌វិន័យព្រះពុទ្ធពិតៗ ទាល់ច្រក ម៉្លោះហើយ ក្រសួងព្រះសង្ឃនាយក បានចំណាប់កាន់តែខ្លាំង អោយតែមានពាក្យប្តឹងថា លោកនេះអោយលោកនេនឃ្លុំ អោយនេនសុំនិស្ស័យ ឬសូត្រធម៌វិន័យប្លែកពីទំនៀមទម្លាប់ដើម នោះគឺពឹតតែផ្សឹក ពឹតតែនិរទេសចេញពីស្រុក។ គេនាំគ្នាចាក់រុកគាបសង្កត់ ចោទដាក់កំហុសតែមកលើសាលាបាលីជាន់ខ្ពស់។ ឮថាក្រុមខ្លះបាន

---

[11] ពាក្យថា លិង្គថេនកៈ ជាឈ្មោះនៃអភព្វបុគ្គលជំពូកមួយ ដែលមានទោសធ្ងន់ជាងបារាជិកទៅទៀត ព្រោះថា ភិក្ខុត្រូវអាបត្តិបារាជិកហើយសឹក អាចបួសជាសាមណេរវិញបាន។ ឯបុគ្គលជាលិង្គថេនកៈ កុំថាឡើយដល់បួសជាភិក្ខុ សូម្បីបួសជាសាមណេរក៏ពុំបានដែរ។ បុគ្គលលិង្គថេនកៈនេះ សំដៅទៅលើចោរដែលគេរកចាប់ខ្លួន វេះពួនក្នុងព្រៃ។

ប្រែប្រាក់គ្នា សូកបារាំងអោយលុបសាលាបាលីជាន់ខ្ពស់ផង។ ប៉ុន្តែតមកទៀត ចំណុចនៃព្រះរាជប្រកាសខាងដើមនេះ អោយផលផ្ទុយទៅវិញគឺ នាំអោយអ្នកមានប្រាជ្ញាយល់ថា មានតែលោកសង្ឃសាលាបាលីទេទើបបួសតាមព្រះពុទ្ធ ក្រៅពីនោះ សុទ្ធតែបួសតាមទំនៀមទម្លាប់ ឥតស្តាប់បង្គាប់ព្រះពុទ្ធទេ។

ចំណែកខាងសាលាបាលីជាន់ខ្ពស់ ដោយហេតុតែមានជំនឿ ជឿអានុភាពនៃសាមគ្គី ក៏មូលត្រកូលគ្នាដូចខ្លួនមួយ នៅក្រោមឱវាទព្រះតេជព្រះគុណព្រះមហាវិមលធម្ម **ថោង** ជាចាងហ្វាង។ សព្វថ្ងៃនេះ ទាំងគេទាំងខ្ញុំ អោយតែនឹកដល់រឿងក្នុងសម័យនោះ តែងតែស្ញើបជានិច្ច ហើយយល់ថា «*ធ្វើសង្គ្រាមធម៌លំបាកជាងសង្គ្រាមអាវុធ*» ។ ប៉ុន្តែខាងសាលាបាលី មានជោគជ័យដោយសារៈ

- ព្រះតេជព្រះគុណព្រះមហាវិមលធម្ម **ថោង** ទុកដូចជាសេនាប្រមុខ
- ព្រះតេជព្រះគុណព្រះញាណបវរវិជ្ជា **ល្វី ឯម** ទុកដូចជាឧត្តមសេនីយ
- ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** ទុកដូចជាឧត្តមសេនីយ
- ព្រះតេជព្រះគុណព្រះគ្រូសង្ឃវិជ្ជា **ហួត តាត** ទុកដូចជាឧត្តមសេនីយ
- ព្រះតេជព្រះគុណព្រះគ្រូវិមលប្បញ្ញា **អ៊ុំ ស៊ូរ** ទុកដូចជាឧត្តមសេនីយ

លុះអំណើះតតអំពីព្រះតេជព្រះគុណព្រះមហាវិមលធម្ម **ថោង** ទៅ ព្រះឧត្តមសេនីយ គង់នៅតែ៣ព្រះអង្គ មានកិត្តិស័ព្ទ និងសេចក្តីរាប់អាន ព្រមទាំងមានជោគជ័យបណ្តាច់ដោយធម្មាវុធ គឺសៀវភៅធម៌វិន័យដែលលោកបានធ្វើ ហើយនឹងធម៌ទេសនាដែលលោកបានសម្តែង។


ព្រះបាទ ស៊ីសុវត្ថិ
King Sisowath( 1840-1927 )

ឆ្នាំ១៩១៧ ដដែល ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ និងជាស្មៀនក្រុមជំនុំវចនានុក្រមខ្មែរ មានព្រះនាមល្បីថាពូកែ ចេះធ្វើការតាមមុខក្រសួងឥតអោយខ្ចោះ ចេះទេសពិរោះ ក៏ជាហេតុអោយព្រះករុណាព្រះបាទសម្តេចព្រះ **ស៊ីសុវត្ថិ** សព្វព្រះរាជហឫទ័យ ទ្រង់ព្រះរាជទានផ្ទាល់ព្រះអង្គនូវមេដាយ **មុនីសារាភរណ៍** ក្នុងគ្រាដែល «គេ» កំពុងព្រួតគ្នាធ្វើបាប...។

ឆ្នាំ១៩១៩ ផ្នែកខាងជំនុំវចនានុក្រមខ្មែរ ដែលមានព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា ជាស្មៀន ចេះតែមានការបាត់បង់សមាជិក ម្ល៉ោះហើយសម្តេច **ម៉ុណ្យ** ជាប្រធាន បានសុំតាំងព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** ជាសមាជិកពេញទី

ហើយជាអ្នកជំនាញការផង។

ឆ្នាំ១៩២០ ផ្នែកខាងសាលាបាលី ដែលបង្រៀនតាមរបៀបបូរាណចំពោះមុខវេយ្យាករណ៍ ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា អាចបង្រៀនសិស្សអោយយល់ អោយចេះឆាប់បាន, ប៉ុន្តែនៅមិនទាន់ធួនល្មមតាមកម្មវិធីដែលតម្រូវថាៈ រៀនវេយ្យាករណ៍មួយឆ្នាំអោយចេះស្ទាត់ នោះនៅឡើយ ព្រោះវេយ្យាករណ៍បាលីនេះ ពីដើមរៀងមកលោកបង្រៀនតាមមូលកច្ចាយនៈ ជាបាលីសុទ្ធ, ម្ល៉ោះហើយ សិស្សពុំអាចរៀនជាបាលីអោយយល់ប្រាកដ ក្នុងកំណត់ពេល ១ឆ្នាំបានទេ។ ហេតុដូច្នេះ ទើបលោកផ្ដើមធ្វើវេយ្យាករណ៍បាលីមួយ អោយឈ្មោះថា **កច្ចាយនូបត្ថម្ភកៈ** (មាន ២ភាគ)។

សៀវភៅ **កច្ចាយនូបត្ថម្ភកៈ** នេះ សេចក្ដីព្រាងជាមុនដំបូងពិស្ដារជាអនេក ដែលលោកសរសេរផ្ដិតពុម្ពចាហួយ ចែកសហការីរបស់លោក, លុះមកដល់ឆ្នាំ ១៩២៤ ទើបលោកកែអោយខ្លីបន្តិច។ សៀវភៅនេះជាគ្រឿងគាប់ចិត្ត នៃអ្នកសិក្សាបាលីទូទៅ មិនរើសគណៈ ទោះបីគូបដិបក្ខក៏តែងលាន់មាត់សរសើរដែរ។ សាលាបាលីជាន់ខ្ពស់ និងវត្តលង្កា ជាប្រភពដើមនៃការផ្សាយវិជ្ជាបាលីតាមគម្រូសៀវភៅនេះ។

ជំនាន់នោះ ខ្ញុំបានសិក្សាផ្ទាល់នូវវិជ្ជានេះជាថ្មី អំពីព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** ហើយព្រះតេជព្រះគុណព្រះញាណបវរវិជ្ជា **លី ឯម** ចាត់ខ្ញុំឲ្យបង្រៀនតាមគម្រូនេះក្នុងវត្តលង្កាអស់វេលា៥ឆ្នាំ ខ្ញុំបានបំប្រួញឲ្យខ្លីដើម្បីឲ្យសិស្សងាយទន្ទេញ។ សេចក្ដីបំប្រួញរបស់ខ្ញុំ ខ្ញុំហៅថា «វិធីមូល» គឺវេយ្យាករណ៍បាលីដែលប្រើសព្វថ្ងៃនេះ។ កាលនោះសិស្សវត្តលង្កា បានប្រឡងចូលសាលាបាលីជាន់ខ្ពស់ក្នុង ១ឆ្នាំៗ ជាប់ច្រើនជាងវត្តទាំងអស់ក្នុងក្រុងភ្នំពេញ។ ហេតុដូច្នេះបានជានៅឆ្នាំ ១៩៣២ ព្រះរាជបណ្ណាល័យកម្ពុជា បានចាត់ការបោះពុម្ពផ្សាយសៀវភៅកច្ចាយនូបត្ថម្ភកៈនេះ ហើយព្រះតេជព្រះគុណព្រះសិរីសម្មតិវង្ស **លី ឯម** បានធ្វើសេចក្ដីសរសើរសៀវភៅកច្ចាយនូបត្ថម្ភកៈនេះ បោះពុម្ពជាប់រហូតមកដល់សព្វថ្ងៃ។

ក្នុងសម័យជាន់មុន សេចក្ដីធម៌វិន័យបានកប់នៅក្នុងសាលាបាលី និងពុំសូវចេញរួចពីគម្ពីរបាលីច្បាស់លាស់ទេ បានជាអ្នកនិយាយធម៌វិន័យ ច្រើនតែនិយាយតៗគ្នា យូរៗទៅនាំឲ្យប្រទាំងប្រទាស់គ្នា សូម្បីតែសូត្រធម៌អាចំ លោកនៅវត្តជិតគ្នា សូត្រពុំត្រូវគ្នាផង។ លុះសៀវភៅកច្ចាយនូបត្ថម្ភកៈកើតឡើង ទើបប្រទេសកម្ពុជា ហាក់ដូចជាបានកូនសោរសម្រាប់បើកទ្វារ ធ្វើអោយសេចក្ដីធម៌វិន័យ ដែលពីដើមជាភាសាបាលី បានចេញមកបង្ហាញរូបរាងយ៉ាងច្បាស់លាស់។ មិនត្រឹមតែប្រទេសកម្ពុជាប៉ុណ្ណោះ ទាំងដែនកូសាំងស៊ីន (យៀកណាមខាងត្បូង) ទាំងប្រទេសលាវ ក៏ពួកពុទ្ធសាសនិកមានការភ្លឺស្វាងក្នុងផ្លូវធម៌

វិន័យ ដោយសារសៀវភៅនេះជាដើមហេតុដែរ ព្រោះសៀវភៅនេះ និងវេយ្យាករណ៍បាលី មានគេប្រើព្រោងព្រាតក្នុងប្រទេសទាំងនោះរហូតដល់សព្វថ្ងៃ។

ឆ្នាំ១៩២១ ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា កំពុងជាប់ព្រះទ័យក្នុងការបង្ហាត់បង្រៀនភាសាបាលីតាមមូលកច្ចាយនៈ ព្រមទាំងកែសម្រួលសៀវភៅកច្ចាយនូបត្ថម្ភកៈនោះផង លោកមានសេចក្ដីខ្នះខ្នែងជាទីបំផុតក្នុងការបង្រៀនសិស្សឲ្យឆាប់ចេះ ដើម្បីឲ្យមានទំពាំងស្នងឫស្សីឡើង ព្រោះលោកបានជ្រាបជាមុនថា លោកនឹងត្រូវនិមន្តទៅបន្តវិជ្ជាសំស្រ្កឹតក្នុងពេលខាងមុខឆាប់ៗ ។ លោកតែងឲ្យមហា **អ៊ុំ ម៉ូត** វត្តបទុមវតី បង្រៀនពិសោធន៍មើល ដើម្បីជំនួសលោក ក្នុងគ្រាដែលលោកមិននៅ។



លោក ល្វី ហ្វីណូត
Louis Finot (1864-1935)

ឆ្នាំ១៩២២ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា**ជួន ណាត** និង ព្រះតេជព្រះគុណព្រះគ្រូសង្ឃវិជ្ជា **ហួត តាត** ដែលធ្លាប់សិក្សាសំស្រ្កឹតពីមុនខ្លះមកហើយនោះ បាននិមន្តទៅបំពេញវិជ្ជាសំស្រ្កឹតទៀត និងអក្សរសិលាចារឹកខ្មែរបុរាណ ព្រមទាំងភូមិសាស្ត្រប្រទេសឥណ្ឌាសម័យពុទ្ធកាលប្រៀបធៀបនឹងសម័យបច្ចុប្បន្ន(ជំនាន់នោះ) ក្នុងសំណាក់លោក **ល្វី ហ្វីណូត** (Louis Finot អ្នកប្រាជ្ញបារាំងសែស) ជាចាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស។ ព្រះថេរៈទាំងពីរអង្គនេះ គង់នៅក្រុងហាណូយអស់វេលាពីរឆ្នាំ។ លោកឆ្លៀតឱកាសសន្ទនាគ្នារាល់ៗថ្ងៃ ជាមួយនឹងយួនឈ្មោះ **អាដាច់** អ្នកសម្អាតអាគារសម្នាក់ ដរាបដល់បានចេះភាសាយួនល្មមដោះទាល់បានផង។

ឆ្នាំ១៩២៥ កាលព្រះរាជបណ្ណាល័យកម្ពុជា ដែលសព្វថ្ងៃជាវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ បានឧប្បត្តិឡើងថ្មីៗ ដោយសារស្នាដៃ **ម៉ាដឺម៉ូហ្សែល ស៊ុយសានការប៉ីឡែស** (Suzanne KARPELÉS ជាតិបារាំងសែស) ដែលមានលេខាធិការតែម្នាក់គត់ គឺលោក **ជួន នុត** ជាដៃគូរផងនោះ, ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំពិនិត្យសេចក្ដីខុសត្រូវ នៃសៀវភៅរបស់សាលាបាលីជាន់ខ្ពស់ ដែលវិជ្ជាឋាននេះចាត់ការបោះពុម្ពផ្សាយ។ សៀវភៅរបស់សាលាបាលីជាន់ខ្ពស់ទាំងប៉ុន្មាន សុទ្ធតែត្រូវបានព្រះថេរៈអង្គនេះពិនិត្យទាំងអស់ តាំងពីច្បាប់ដើមរហូតដល់វិញ្ញាសាដែលរោងពុម្ព



លោកស្រី កាប៉ីឡែស
Suzanne KARPELÉS (1890-1969)

បោះពុម្ពតៗ មក។

ក្នុងឆ្នាំ១៩២៥ ដដែលនោះ ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** បានជាវដីពង្រីកវត្តពោធិព្រឹក្ស ពីរកន្លែងគឺ ១កន្លែង ពីត្រឹមជិតខឿនព្រះវិហារ មកខាងត្បូងទល់នឹងមាត់ស្ទឹង, ១កន្លែងទៀត ខាងឥសានព្រះវិហារ ជាដីរាងស្លាបក្ដោង។ បានត្រួសត្រាយព្រៃធ្វើផ្លូវលំមួយបែកពីផ្លូវខេត្តកំពង់ស្ពឺ មកទល់នឹងព្រៃទទឹង គឺបែកត្រង់ស្រែបន្ទាយចូលទៅវត្តពោធិព្រឹក្ស ប្រវែង ៣គ.ម គត់។ ការធ្វើផ្លូវលំនេះ អ្នកស្រុកជិតខាងពុំសូវចូលចិត្តជួយធ្វើទេ ព្រោះព្រះថេរៈអង្គនេះអ្នកស្រុកគេហៅថា លោកធម៌ថ្មី, គេពុំចង់ចូលដៃ ព្រោះខ្លាចឆ្លងធម៌ថ្មី។

សម័យនោះ ក្រៅពីព្រះគ្រូ **កែ ម៉ម** និងព្រះគ្រូ **អ៊ុន ខឹម** ជាគ្រូ និងជាញាតិផ្ទាល់របស់លោក មានតែមេស្រុក **តាំ** ម្នាក់ ជាចៅសង្កាត់រកាកោះនោះ ជួយខ្នះខ្នែងក្នុងការលើកថ្នល់នេះ ព្រោះមេស្រុកនេះក្រោយពីពេលដែលជជែកគ្នាពីរឿងធម៌ថ្មី ធម៌ចាស់ជាមួយនឹងអ្នកស្រុកជិតខាងក្នុងយប់នោះ គាត់យល់សប្ដិឃើញថាៈ គាត់វង្វេងផ្លូវនៅក្នុងព្រៃងងឹតឥតយល់អ្វី ស្រាប់តែឃើញព្រះសង្ឃមួយអង្គ ប្រើស្បង់ចីពរជ្រលក់ក្រាក់ខ្នុរ កាន់ភ្លើងបំភ្លឺផ្លូវអោយគាត់ចេញរួចពីព្រៃងងឹត ដើរតាមផ្លូវថ្នល់ត្រង់ស្អាតរហូតដល់ប្រាសាទអង្គរវត្ត។ គាត់ភ្ញាក់ឡើងនឹកឃើញថា "មានតែលោកធម៌ថ្មីហ្នឹងហើយដែលជ្រលក់ក្រាក់ខ្នុរ" ទើបគាត់សសោះអន្ទងផង ប្រើអំណាចខ្លះផង ឲ្យអ្នកស្រុកជិតខាងខ្លះមានសទ្ធា ជួយធ្វើថ្នល់នេះល្មមបើកបររថយន្តបាន។ អមសងខាងផ្លូវលំនេះ លោកបានដាំដើមត្រាច និងដើមត្នោតរាប់រយដើមសម្រាប់ជាប្រយោជន៍ដល់បច្ឆាជនក្នុងអនាគត ដែលក្នុងជំនាន់នោះឥតនរណានឹកឃើញសោះថា ស្រុកខ្មែរតទៅនឹងខ្វះដើមឈើ។ បន្ទាប់ពីនោះ លោកបានសាងព្រះវិហារ សាលាបាលីរង សាលាក្មេងរៀនតៗរៀងមកទៀត។

ឆ្នាំ១៩២៦ ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** បានផ្ដើមតែងអត្ថបទផ្សេងៗច្រើនបោះពុម្ពបញ្ចូលក្នុងទស្សនាវដ្ដីកម្ពុជសុរិយា រាល់ខែឆ្នាំតៗ មក។

មិនតែប៉ុណ្ណោះ ក្នុងឆ្នាំ១៩២៦ ដដែលនោះ លោក **ម៉ុនចន្ទ មង្គល** ចៅហ្វាយស្រុកកៀនស្វាយបានពឹង **ម៉ាដឺម៉ូហ្សែល ស៊ុយសានការប៉ិឡែស** អ្នកត្រួតត្រាព្រះរាជបណ្ណាល័យកម្ពុជា ឲ្យបោះពុម្ពសៀវភៅ *វិជ័យក្រហស្ថ* ដើម្បីលោកនឹងជាវយកទៅចែកជាធម្មទាន តមស្នងសងគុណមាតាបិតាលោក។ លោកអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យកម្ពុជា ក៏អារាធនាព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** ឲ្យប្រែគម្ពីរបាលីរៀបរៀងសេចក្ដីជាវិន័យឧបាសក ជាមួយនឹងព្រះតេជព្រះគុណព្រះគ្រូ

វិមលប្បញ្ញា **អ៊ុម ស៊ូរ** ។ ព្រះថេរៈទាំងពីរព្រះអង្គ បានធ្វើសៀវភៅនេះហើយ ឲ្យឈ្មោះថា **គិហិបដិបត្តិ** ជូនលោកអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យ ឲ្យសុំអនុញ្ញាតរាជការ ហើយបោះពុម្ពតាមផ្លូវការ។

សៀវភៅនេះ ទោះបីស្របតាមច្បាប់ពុទ្ធចក្រ និងអាណាចក្រក៏ដោយ ក៏នៅតែជាហេតុចម្រូងជម្រះ ដូចសៀវភៅសាមណេរវិន័យដែរ, ប៉ុន្តែពុទ្ធសាសនិកចូលចិត្តសិក្សា ក៏សៀវភៅនេះនាំឲ្យចម្រើនក្នុងព្រះពុទ្ធសាសនា និងបានប្រាក់ជាថវិកាជាតិរាប់ម៉ឺនរៀល ក្នុង ១ឆ្នាំៗ រហូតដល់សព្វថ្ងៃនេះ។

ឆ្នាំ១៩២៦ ដដែល និងឆ្នាំតៗ មកដ៏ច្រើន ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** បានទទួលការតែងតាំងជាមេប្រយោគក្នុងការប្រឡងយកវិញ្ញាបនប័ត្រ បឋមសិក្សាខ្មែរ និងការប្រឡងយកសញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់បារាំង-ខ្មែរ នៅក្រុងភ្នំពេញ...។

ឆ្នាំ១៩២៧-២៨ លោកស្រី **ឡុច** ជាភរិយាលោកអ្នកឧកញ៉ាមហាមន្ត្រី **ប៉ុក ឌុច** បាននិមន្តព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** និងព្រះតេជព្រះគុណព្រះញាណបវរវិជ្ជា **លី ឯម** ឲ្យប្រែរៀបរៀងព្រះវិន័យ ***ចាតិមោក្ខសំវរសីល*** និង ***វ័ដ្ឋការិជ័យ*** (សម្រាប់ភិក្ខុ) ហើយពឹងលោកអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យកម្ពុជា ឲ្យចាត់ការសុំអនុញ្ញាតព្រមទាំងបោះពុម្ព លោកស្រីនឹងជាវយកទៅផ្សាយជាធម្មទាន ដើម្បីជូនកុសលដល់សពលោកអ្នកឧកញ៉ាមហាមន្ត្រី **ប៉ុក ឌុច** ជាស្វាមី។ សៀវភៅនេះកើតឡើង ក៏មានសេចក្តីចម្រើនដូចគិហិបដិបត្តិដែរ ប៉ុន្តែនៅតែមានគេនាំអោយកើតការចម្រូងជម្រះពុំអស់នឹងនិយាយ។

គួរអោយអស់សំណើច វត្តខ្លះភិក្ខុសាមណេរចូលចិត្តរៀន លោកគ្រូចៅអធិការពុំព្រមឲ្យរៀន។ លោកគ្រូទាំងនោះអស់ផ្លូវនិយាយពីរឿងខុសត្រូវ ទៅជានិយាយបំភ័យសិស្សថា៖ អាចារ្យ **ឯម** និងសង្ឃសត្ថា **ណាត** ចេះបាលីណាស់ អាចសូត្របាលីធ្វើអោយមនុស្សឆ្កួតបាន (មេធ្មប់) មើលចុះសៀវភៅដែលអាចារ្យ **ឯម** និងសង្ឃសត្ថា **ណាត** ធ្វើសុទ្ធតែមានបញ្ចុះយ័ន្ត[12] គាថាស្រេច។ វត្តខ្លះមិនត្រឹមហាមតែភិក្ខុសាមណេរទេ ទោះបីសិស្សចាស់ដែលសឹកទៅ មានកូនមានចៅហើយក៏លោកហៅមកប្រាប់មិនឲ្យកាន់សៀវភៅនេះដែរ ខ្លាចត្រូវមន្តវិជ្ជានាំអោយឆ្កួត តពូជ។

ឆ្នាំ១៩៣០ ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះ **មុនីវង្ស** ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** បានទទួលការតែងតាំងក្នុងមុខងារជាចាងហ្វាងរងនៃសាលាបាលី ជាន់ខ្ពស់ ក្រុងភ្នំពេញ ជាមួយ

[12] លោកអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យ ចូលចិត្តឲ្យជាងសរសេរគួរអក្សរផ្គាប់ផ្ងាប្រទាក់គ្នាធ្វើជាក្បាច់ ដើម្បីគ្លីស្បៃបោះពុម្ពដាក់ក្នុងសៀវភៅទាំងនោះជាគ្រឿងលម្អ, ប៉ុន្តែការនោះឲ្យផលទៅជានាំមតិមហាជនឲ្យយតល់ថា ជាយ័ន្តគាថាទៅវិញ។

នឹងព្រះតេជព្រះគុណព្រះសិរីសម្មតិវង្ស **ល្វី ឯម** ដែលបានទទួលការតែងតាំងជាចាងហ្វាងធំ នៃសាលានេះ។

មិនតែប៉ុណ្ណោះ ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា ទទួលបានការតែងតាំងជាសមាជិកជំនួយនៃក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យក្រុងភ្នំពេញទៀត ជាអង្គការរដ្ឋមួយដ៏សំខាន់ ដែលលោកបានផ្ដើមបង្កើតឡើងជាមួយសហការីផ្សេងៗ របស់លោក។

ឆ្នាំ១៩៣១ ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា **ជួន ណាត** និង ព្រះតេជព្រះគុណព្រះគ្រូសង្ឃវិជ្ជា **ហួត តាត** រដ្ឋាភិបាលបានចាត់អោយឲ្យនិមន្តទៅកាន់ក្រុងវៀងចន្ទ និងក្រុងហ្លួងព្រះបាងនៃប្រទេសលាវ ជាតំណាងព្រះសង្ឃប្រទេសកម្ពុជា និងសាលាបាលីជាន់ខ្ពស់ ដើម្បីប្រជុំសម្ភោធពុទ្ធសាសនបណ្ឌិត្យប្រទេសលាវផង ដើម្បីជំនុំពិភាក្សាអំពីការសិក្សាសម្រាប់សាលាបាលីរង នៅប្រទេសលាវផង។

ក្នុងឆ្នាំ១៩៣១ ដដែលនេះ ព្រះករុណាជាអម្ចាស់ជីវិតព្រះបាទសម្ដេចព្រះ **មុនីវង្ស** ទ្រង់ប្រោសព្រះរាជទាននូវសមណស័ក្ដិ ចំពោះព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថាជា **ព្រះសាសនសោភ័ណ** និង ចំពោះព្រះតេជព្រះគុណព្រះគ្រូសង្ឃវិជ្ជាជា **ព្រះវិសុទ្ធិវង្ស** (ទីរាជាគណៈកិត្តិយស)។

ឆ្នាំ១៩៣២ ព្រះតេជព្រះគុណព្រះសាសនសោភ័ណ **ជួន ណាត** បានទទួលឥស្សរិយយស **មេដាយអស្សរិទ្ធិ** នៃប្រទេសកម្ពុជា និង **មេដាយអស្សរិទ្ធិដំរី ១លាន** នៃប្រទេសលាវ, បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំខាងការស្រាវជ្រាវជ្រើសរើស យកពាក្យពេចន៍ក្នុងផ្នែកវិនិពន្ធខ្មែរបុរាណ មកពន្យល់ន័យរបស់ពាក្យនោះៗ ។

ឆ្នាំ១៩៣៣ ព្រះតេជព្រះគុណព្រះសាសនសោភ័ណ **ជួន ណាត** បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំពិនិត្យសៀវភៅ ដែលក្រសួងសិក្សាធិការជាតិបោះពុម្ពផ្សាយ។

ក្នុងឆ្នាំដដែលនេះ រដ្ឋាភិបាលចាត់លោកឲ្យនិមន្តទៅធ្វើទស្សនាចរណ៍ ចំពោះវត្តខ្មែរទាំងឡាយក្នុងដែនកូសាំងស៊ីន ប្រទេសយៀកណាមខាងត្បូង។ ក្នុងឆ្នាំនេះដែរ លោកបាននិពន្ធសៀវភៅមួយក្បាលឲ្យឈ្មោះថា **ជាតោបមាជិកាថា** [13] ។

[13] សៀវភៅនេះតូចស្តើងទេ ប៉ុន្តែអាចបំបាត់ពាក្យចាក់ដោតដែលចោទថា "បំបួសនាគជាសត្វតិរិច្ឆាន" នោះបាន។ ផ្សំគ្នានឹងសៀវភៅ បព្វជ្ជាខន្ធកសង្ខេប របស់សម្ដេច ល្វី ឯម ផងអាចបំបាត់បានរហូតដល់ពាក្យចាក់ដោតថា "ពុករលួយឬសគល់" និងពាក្យថា "លិង្គថេនកៈ" ផងទៀត។

ឆ្នាំ១៩៣៤ លោកបានកសាងសាលាបាលីរងមួយខ្នងប្រក់ក្បឿង គ្រឿងឈើខ្ពស់ពីដី ចែកជា ៣ថ្នាក់ ក្នុងវត្តពោធិព្រឹក្ស។ លោកបានជាវសៀវភៅកថ្វាយនូបត្ថម្ភកៈ របស់លោកច្រើនក្បាល អំពីព្រះរាជបណ្ណាល័យកម្ពុជា យកទៅចែកក្នុងពិធីសម្ពោធឆ្លងបើកសាលារៀននេះ ក្នុងចំណោមឥស្សរជនមន្ត្រីបារាំង-ខ្មែរ ជាច្រើនរូប។

ឆ្នាំ១៩៣៤ ដដែលនេះ ព្រះតេជព្រះគុណព្រះសាសនសោភ័ណ **ជួន ណាត** បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំជ្រើសរើសពាក្យខ្មែរ ប្រៀបធៀបនឹងពាក្យបារាំង សម្រាប់ប្រើក្នុងកិច្ចការរាជការ។

ឆ្នាំ១៩៣៥ ព្រះតេជព្រះគុណព្រះសាសនសោភ័ណ **ជួន ណាត** បានជាវព្រះពុទ្ធរូបថ្មកែវមួយព្រះអង្គពីប្រទេសភូមា ដើម្បីតម្កល់ទុកក្នុងព្រះវិហារបេតុងអារម៉េសុទ្ធ ក្នុងវត្តពោធិព្រឹក្ស ដែលលោកបានកសាងរួចស្រេចក្នុងឆ្នាំនោះ។ គ្រានោះលោកបាននិពន្ធសៀវភៅមួយ ឲ្យឈ្មោះថា **មហាបុរិសលក្ខណៈ** ជូនព្រះរាជបណ្ណាល័យកម្ពុជាចាត់ការបោះពុម្ព ហើយលោកជាវសៀវភៅរបស់លោកនោះទៅចែកក្នុងពិធីបុណ្យអភិសេកព្រះពុទ្ធរូប ព្រមទាំងសម្ពោធឆ្លងព្រះវិហារនោះផង។

តាំងពីលោកបានជាវដីបញ្ចូលជាដីវត្តពោធិព្រឹក្ស ក៏បានចាក់ដីលុបថ្លុកជង្ហុករាបស្មើល្អហើយលោកក៏បានសាងសេនាសនៈផ្សេងៗ និងបានយកពូជរុក្ខជាតិជាច្រើនដែលមានប្រយោជន៍ជាគ្រឿងទព្វសម្ភារៈក៏មាន ជាគ្រឿងលម្អសួនច្បារក៏មាន ជាម្លប់សំរាប់កំសាន្តក៏មាន យកមកដាំក្នុងទីវត្តដូចជាៈ យកពូជឫស្សីដើមធំៗ ពីខេត្តក្រចេះ, យកឫស្សីកែវពណ៌លឿងៗ ពីខេត្តកំពង់ចាម, យកឫស្សីពីងពង់ពីខេត្តកំពង់ឆ្នាំង មកដាំណែនណាន់តាន់តាប់តាមមាត់ស្ទឹង។ យកដើមស្រល់ពីភ្នំដងរែក, យកពូជដកខឹមដើមធំៗ ផ្កាចង្កោមពណ៌ក្រហមពីប្រទេសលាវ និងដើមឈើច្រើនមុខសម្រាប់សួនច្បារ ពីស្រុកផ្សេងៗ មកដាំតែងជាសួនច្បារខាងត្បូងព្រះវិហារ, យកពូជចាមរី ពូជជ្រៃក្រឹមពីរបែបផ្សេងពីគ្នា ដាំក្បែរសាលាបាលីរង និងសាលាក្មេងរៀន ដើម្បីបង្កើតជាម្លប់, យកពូជម៉ាក់ប្រាងពីខេត្តកំពត ពូជម៉ាក់ប្រេងពីខេត្តបាត់ដំបង-សៀមរាប មកដាំឆ្លាស់គ្នានឹងដើមខ្នុរអមសងខាងផ្លូវខាងក្រោយព្រះវិហារ កាត់ទៅខាងជើង ហើយខាងមុខព្រះវិហារក្បែរមាត់ស្រះ តាមផ្លូវកាត់ទៅខាងជើង លោកដាំដើមដូងជាជួរៗ ។

ក្នុងវ័យជាបច្ឆិម ព្រះមហាថេរអង្គនេះ រឹតតែជាប់ព្រះហ្ឫទ័យនឹងរុក្ខជាតិកាន់តែខ្លាំងឡើងៗ ដូចជាកាលនិវត្តពីប្រទេសភូមា យកពូជដើមចំប៉ីសមក, និវត្តពីឥណ្ឌា យកព្រីង និងសាលព្រឹក្សមក, និវត្តពីប្រទេសបារាំង យកពូជប៉ុង (Pin) មក...។ លោកដាំក្នុងវត្តឧណ្ណាលោមផង ក្នុងវត្តពោធិព្រឹក្សផង ហើយចែកអោយដាំពាសវត្តអារាមស្ទើរគ្រប់ស្រុក គ្រប់ខេត្តនៃប្រទេសខ្មែរផងទៀត...។

# ទិដ្ឋភាពទូទៅនៅវត្តពោធិព្រឹក្ស បច្ចុប្បន្ន...




*ព្រះវិហារវត្តពោធិព្រឹក្ស នាពេលបច្ចុប្បន្ន... ព្រះវិហារចាស់ត្រូវបានកំទេចអស់ នៅសល់តែតួខឿនព្រះវិហារដែលមានក្បាច់ដូចខឿនប្រាសាទបុរាណដែរ។ ព្រះវិហារកសាងជាថ្មីឡើងវិញនេះ ឃើញដាក់កាលបរិច្ឆេទ ព.ស ២៥៣៧ គ.ស ១៩៩៣ (សស)*



ព្រះវិហារវត្តពោធិព្រឹក្ស មើលពីខាងត្បូង
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)



ព្រះវិហារវត្តពោធិព្រឹក្ស មើលពីខាងលិច
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




ព្រះវិហារវត្តពោធិព្រឹក្ស មើលពីខាងជើង
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




កុដិព្រះសង្ឃនៅវត្តពោធិព្រឹក្ស នាពេលបច្ចុប្បន្ន...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)



កុដិព្រះសង្ឃនៅវត្តពោធិព្រឹក្ស នាពេលបច្ចុប្បន្ន...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)



កុដិព្រះសង្ឃនៅវត្តពោធិព្រឹក្ស នាពេលបច្ចុប្បន្ន...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




*អតីតព្រះកុដិរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត នៅវត្តពោធិព្រឹក្ស ដែលបានកសាង និងសម្ពោធនៅឆ្នាំ ១៩៣៥ ត្រូវទទួលរង នូវគ្រាប់កាំភ្លើងតាំងពីសម័យសង្គ្រាមឆ្នាំ ១៩៧០-៧៥ ទុកស្នាមរហូតមកដល់បច្ចុប្បន្ននេះ មើលទៅស្រងេះស្រងោចណាស។ ព្រះកុដិនេះ មានរចនាបទ និងរាងរៅស្រដៀងគ្នានឹងសំណង់ទីអារាមព្រះពុទ្ធសាសនា នៅប្រទេសភូមាដែរ។ នៅជាន់ខាងក្រោម និងជាន់ទី១ សម្តេចព្រះសង្ឃរាជបានរៀបចំជាបណ្ណាល័យ និងជាកន្លែងទទួលជួបភ្ញៀវតូចធំ ជិតឆ្ងាយ... រីឯនៅលើដំបូលផុត មានដំកល់ព្រះពុទ្ធបដិមាថ្មកែវមួយអង្គ ដែលព្រះអង្គជាវមកពីប្រទេសភូមា។ អតីតព្រះកុដិនេះ គួរតែត្រូវបានជួសជុលឡើងវិញ ដោយរក្សាទុកនូវទំរង់ដើមទាំងស្រុង សំរាប់អោយក្មេងជំនាន់ក្រោយបានឃើញផង...។ ( ស្រុកស្រែ )*




អតីតកុដិរបស់សម្តេចព្រះសង្ឃរាជ មើលពីខាងត្បូង
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




ក្នុងអតីតកុដិរបស់សម្តេចព្រះសង្ឃរាជ ជាន់ទី១
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




ជណ្ដើរឡើងទៅលើដំបូល នៃអតីតកុដិរបស់សម្ដេចព្រះសង្ឃរាជ
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




ព្រះពុទ្ធរូបថ្មកែវ នាំយកមកពីប្រទេសភូមា
ត្រូវបានដំកល់ទុកនៅលើដំបូលព្រះកុដិនេះ
ដែលបច្ចុប្បន្ននៅសល់តែបល្ល័ង្គបែបនេះ...




សាលាឆាន់វត្តពោធិព្រឹក្ស នាពេលបច្ចុប្បន្ន...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




សាលាឆាន់វត្តពោធិព្រឹក្ស នាពេលបច្ចុប្បន្ន...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




ទីតាំងអតីតសាលាបាលីរង ស្ថិតនៅក្នុងបរិវេណវត្តពោធិព្រឹក្ស...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




ដើមឈើធំនេះ ពេលចេញផ្កា វាមានក្លិនសក្បុសស្អាតណាស់...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




ដើមដកខឹម នាំយកមកពីប្រទេសលាវ... វានឹងចេញផ្កាពណ៌ក្រហមឆេះ នៅរដូវបុណ្យចូលឆ្នាំខ្មែរម្តងៗ... (រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




គុម្ពឬស្សីដែលដុះតាមមាត់ស្ទឹង ខាងលិចវត្តពោធិព្រឹក្ស... (រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)

ក្នុងឆ្នាំ១៩៣៥ ដដែល ព្រះតេជព្រះគុណព្រះសាសនសោភ័ណ **ជួន ណាត** បានទទួលការតែងតាំងជាសាស្ត្រាចារ្យបង្រៀនភាសាបាលី, សំស្រ្កឹត, ខ្មែរ និងលាវ ប្រចាំថ្នាក់ទីបំផុតនៃមធ្យមសិក្សា នៅវិទ្យាល័យព្រះស៊ីសុវត្ថិ។

ឆ្នាំ១៩៣៧ ព្រះតេជព្រះគុណព្រះសាសនសោភ័ណ បានទទួល **មេដាយសេនា** ពីបណ្ឌិតសភា នៃសាធារណរដ្ឋបារាំង។

ឆ្នាំ១៩៣៩ រដ្ឋាភិបាលបានចាត់ ព្រះតេជព្រះគុណព្រះសាសនសោភ័ណ **ជួន ណាត** ឲ្យនិមន្តទៅកាន់ប្រទេសលាវម្តងទៀត ដើម្បីប្រជុំប្រឹក្សាកិច្ចការនៃពុទ្ធសាសនបណ្ឌិត្យប្រទេសលាវ និងការសិក្សាសម្រាប់សាលាបាលីនៅប្រទេសលាវផង ដើម្បីជួយរំលឹកដាស់តឿនប្រជាជនជាតិលាវ នៅក្នុងទីប្រជុំជនក្នុងខេត្តនានា នៃព្រះរាជាណាចក្រលាវ ឲ្យខំប្រឹងយកចិត្តទុកដាក់ក្នុងការសិក្សា និងការប្រតិបត្តិឲ្យបានត្រឹមត្រូវតាមគន្លងព្រះពុទ្ធសាសនាផង។




សម្តេចបានប្រាប់ខ្ញុំញឹកៗថា៖ គ្រាជំនុំអំពីកិច្ចការនៃពុទ្ធសាសនបណ្ឌិត្យក្នុងប្រទេសលាវ ជាតិលាវភាគច្រើន ព្រមទាំងអាណាព្យាបាលបារាំងសែស ចង់អោយបោះពុម្ពព្រះត្រៃបីដកទាំងសម្រាយដូចប្រទេសខ្មែរដែរ, ប៉ុន្តែទាល់ច្រកបោះពុម្ពពុំកើត ព្រោះរដ្ឋាភិបាលលាវ សម្រេចអោយ «លុបអក្សរបុរាណ» របស់លាវអស់ច្រើនតួហួសទៅហើយ ព្រោះផ្អើលតាម **ហ្លួងពិបុលសង្គ្រាម** (សៀម) ដែលគេថា ប្រុង «លុបអក្សរសៀម» ចោលខ្លះដោយគេគ្រាន់តែថា ប៉ុន្តែឥតលុបអក្សរសៀមខ្លះរបស់គេចោលសោះ, ឯលាវខ្លួនឯង បានលុបតួអក្សរខ្លះអស់ទៅ នាំឲ្យបោះពុម្ពព្រះត្រៃបីដកពុំកើត។

ខ្ញុំ(**ឈឹម ស៊ុម**)យល់ថា៖ ប្រទេសលាវ ជាប្រទេសអភ័ព្វក្នុងចំណោមប្រទេសកាន់ព្រះពុទ្ធសាសនា ព្រោះធាប់ផ្អើលឥតពិចារណាទាំងផ្លូវលោក ទាំងផ្លូវធម៌។ សម្តេចទ្រង់ព្រួយ ខ្លាចក្រែងប្រទេសខ្មែរ ដូចលាវដែរ...។

ឆ្នាំ១៩៤០ កាលព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ **ម៉ា កេត** ជាចៅអធិការវត្តវិហារសួគ៌ ទទួលអនិច្ចធម្មទៅ, ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់សព្វព្រះរាជហឫទ័យ តែងតាំងព្រះតេជព្រះគុណព្រះសាសនសោភ័ណ **ជួន ណាត** ក្នុងតំណែងជា **ព្រះពុទ្ធឃោសាចារ្យ** (ទីរាជាគណៈទោ, រំលងពីរ

ថ្នាក់) ព្រោះព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ឈ្វេងយល់ថា ត្រូវតែអោយឡើងសមណសក្តិរំលងថ្នាក់ ដ្បិតលោកនេះចេះដឹងច្រើន ហើយជាសិស្សចម្បងរបស់លោកគ្រូព្រះពុទ្ធឃោសាចារ្យ **ម៉ា កេត** ផង។

ក្នុងឆ្នាំដដែលនេះ ព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ **ជួន ណាត** បានសាងក្លោងទ្វារបេតុងអារម៉េមួយរចនាដោយក្បាច់អង្គរ នៅស្រែបន្ទាយ ត្រង់ដើមផ្លូវបំបែកចូលវត្តពោធិព្រឹក្ស, កសាងសាលាសម្នាក់មួយខ្នងប្រក់ក្បឿង គ្រឿងឈើខ្ពស់ពីដី, ជីកស្រះមួយខាងជើងសាលានោះទំហំ១០០ម បួនជ្រុង។




ឆ្នាំ១៩៤២ ព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ **ជួន ណាត** បានទទួលការតែងតាំងជាចាងហ្វាងនៃសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ តអំពីព្រះតេជព្រះគុណ **លី្វ ឯម** ដែលបារាំងអោយលាឈប់ពីតំណែង ក្នុងគ្រាដែលលោកសង្ឃក្រុមសាលាបាលីនេះ បះបោរទៅតវ៉ានឹងរាជការបារាំងសែស អំពីបារាំងផ្សឹកលោកអាចារ្យ **ហែម ជៀវ** ខុសច្បាប់។

ក្នុងឆ្នាំដដែលនេះ ព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ **ជួន ណាត** បានទទួល **មេដាយអស្សរិទ្ធិ ជីឡាឡេស្យុងដូណើរ** នៃសាធារណរដ្ឋបារាំង។

ឆ្នាំ១៩៤៣ ព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ **ជួន ណាត** បានទទួលនាទីជាសមាជិកឆ្លើយឆ្លងនៃសាលាបារាំងសែស នៅចុងបូព៌ាប្រទេស, ហើយឆ្នាំ ១៩៤៨ លោកបានទទួលនាទីជាសមាជិកកិត្តិយសនៃសាលានេះដរាបមក។

ឆ្នាំ១៩៤៤ ព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ **ជួន ណាត** បានទទួលតំណែងជា **ចៅអធិការវត្តឧណ្ណាលោម** តអំពីព្រះតេជព្រះគុណព្រះមហាវិមលធម្ម **ធន់** ដែលទទួលអនិច្ចធម្មទៅ។ នៅក្នុងឆ្នាំដដែលនេះ ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ទ្រង់ប្រោសព្រះរាជប្រទានសមណសក្តិជា **ព្រះពោធិវ័ង្ស** (រាជាគណៈឯក)។ បន្ទាប់គ្នានេះ លោកទទួលបាន **មេដាយសេនា** នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងឆ្នាំជាមួយគ្នានេះ លោកបានដាវដីមួយកន្លែងតាមផ្លូវលំដែលលោកបានលើកយូរហើយ ត្រង់ផ្លូវបំបែកចូលទៅវត្តសូរភី។ ដាវដីនោះបានហើយ លោកបានសង់សាលាបឋមសិក្សាបំពេញវិជ្ជា មានអាគារសិក្សាគ្រឿងឈើ ប្រក់ក្បឿងខ្លះស្លឹកខ្លះ តាំងពីថ្នាក់កុមារដ្ឋានដល់ឧត្តមដ្ឋាន។ លោកបានជីកស្រះតូចមួយ យកអាចម៍ដីចាក់បំពេញកីឡាដ្ឋានក្នុងបរិវេណសាលានេះ។

ឆ្នាំ១៩៤៥ ព្រះតេជព្រះគុណព្រះពោធិវង្ស **ជួន ណាត** បានទទួលនាទីជាអធិបតីនៃថេរសភា (ក្រុមជំនុំសង្ឃជាន់ខ្ពស់ សម្រាប់វិនិច្ឆ័យអធិករណ៍ និងសង្ឃកិច្ចផ្សេងៗ ក្នុងព្រះរាជាណាចក្រកម្ពុជា)។

ឆ្នាំ១៩៤៧ ព្រះតេជព្រះគុណព្រះពោធិវង្ស **ជួន ណាត** បានទទួលការតាំងជាអនុប្រធានគណៈកម្មការវប្បធម៌ ផ្នែកអក្សរ "ក" ។

ឆ្នាំ១៩៤៨ ព្រះមហាថេរអង្គនេះ បានទទួលការតែងតាំងជាសមាជិកកិត្តិយស នៃសាលាបារាំងសែសនៅចុងបូព៌ាប្រទេស។ ក្នុងឆ្នាំដដែលនេះ លោកបានទទួលនាទីជាប្រធាននៃគណៈកម្មការធម្មវិន័យ ពិនិត្យការផ្សាយសៀវភៅសម្រាប់សាលាធម្មវិន័យ ក្នុងព្រះរាជាណាចក្រកម្ពុជា ជាសាលាដែលលោកបានផ្តួចផ្តើមបង្កើតឡើង។




ក្នុងឆ្នាំ១៩៤៨ ដដែលនេះព្រះតេជព្រះគុណព្រះពោធិវង្ស**ជួន ណាត** បានឡើងសមណសក្តិជាន់ខ្ពស់បំផុតជា **ព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ** តអំពីសម្តេចព្រះសង្ឃនាយក **ហ៊ិន** មក។ ក្នុងឆ្នាំដដែលនេះដែរ ព្រះតេជព្រះគុណព្រះមហាសុមេធាធិបតី សង្ឃនាយក **ជួន ណាត** បានទទួល **មេដាយសេនា ជីឡាឡេស្យុងដូណ្ណើរ** នៃសាធារណរដ្ឋបារាំង។

ឆ្នាំ១៩៥០ ព្រះមហាថេរអង្គនេះ បានទទួលសមណសក្តិជា **សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ** ។ ក្នុងឆ្នាំដដែលនេះ ព្រះរាជរដ្ឋាភិបាលបានតែងតាំងសម្តេចជាប្រធានគណៈប្រតិភូខ្មែរ និមន្តទៅកាន់សន្និសីទជាបឋម ជំនុំព្រមគ្នាបង្កើតពុទ្ធិកសមាគមពិភពលោកនៅក្រុងកោលម្ពូ លង្កាទ្វីប [ក្រុងកូឡុំបូ ប្រទេសស្រីលង្កា] ជាមួយនឹងគណៈប្រតិភូដែលមកពី ៣៨ ប្រទេស។

ឆ្នាំ១៩៥១ សម្តេចបានឧបត្ថម្ភដល់ការកសាង **វត្តជោតារាម** (បឹងកុក) ក្រុងកំពង់ចាម ដោយបាននិមន្តទៅផ្ទាល់ដល់ទីនោះ, បានពិនិត្យការវាស់វែងដីដែលគេប្រគេនស្រេច រួចបានគូរផែនទីផ្តល់ទៅរាជការ លុះត្រាតែបានសេចក្តីសម្រេចច្បាប់វត្តពេញទី ដែលមានព្រះរាជក្រឹត្យលេខ ៦៧ន.ស ចុះថ្ងៃទី ១៤ មីនា ឆ្នាំ១៩៥១ ជាសម្អាង។

ឆ្នាំ១៩៥២ សម្តេចបានបង្កើត **ពុទ្ធិកសមាគមពិភពលោក មជ្ឈមណ្ឌលកម្ពុជរដ្ឋ** ។ នៅក្នុងឆ្នាំដដែលនេះ សម្តេចបានចាត់ពិធីហែ **ព្រះសារីរិកធាតុ និងព្រះអរហន្តធាតុ** ជាមហោឡារិក ក្រោមព្រះបរមរាជូបត្ថម្ភដ៏ខ្ពង់ខ្ពស់នៃព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ។

ព្រះសារីរិកធាតុនៃព្រះ **សក្យមុនីគោតម** និងព្រះអរហន្តធាតុនៃព្រះ **សារីបុត្ត** និងព្រះ **មោគ្គល្លាន** ទាំង ៣ព្រះអង្គនេះ ពុទ្ធិកសមាគមពោធិគយា នៃប្រទេសឥណ្ឌាបានរក្សាទុក។ សម្តេចព្រះមហាសុមេធាធិបតី បានជាប់ព្រះទ័យនឹងព្រះបរមសារីរិកធាតុ និងព្រះអរហន្តធាតុនោះ តាំងពីកាលនិមន្តទៅធ្វើសន្និសីទនៅលង្កាទ្វីបម្ល៉េះ។ កាលដែលសម្តេច បានថ្វាយព្រះពរស្នើនឹងព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ជាអម្ចាស់ជីវិតហើយ ព្រះរាជរដ្ឋាភិបាលបានចាត់ការសុំឲ្យគណៈប្រតិភូពុទ្ធិកសមាគមឥណ្ឌា ដង្ហែព្រះសារីរិកធាតុនោះ មកតាមច្រកអាកាសយានដ្ឋានពោធិចិនតុង ក្រុងភ្នំពេញ។ ចំណែកខាងព្រះរាជរដ្ឋាភិបាលក្រុងភ្នំពេញ បានចាត់ការរៀបចំពិធីទទួលព្រះបរមសារីរិកធាតុនោះ ជាមហោឡារិកអធិកអស្ចារ្យ ដែលខ្ញុំពុំដែលឃើញពិធីបុណ្យក្នុងគ្រាណា សម្បើមអស្ចារ្យដូចបុណ្យនេះឡើយ...។

៧យប់ ៧ថ្ងៃនៃពិធីបុណ្យព្រះបរមសារីរិកធាតុកន្លងទៅ ចូលដល់ថ្ងៃទី ៨ គឺនៅថ្ងៃទី ១១ ខែតុលា ឆ្នាំ១៩៥២ ត្រូវរៀបចំជូនដំណើរព្រះសារីរិកធាតុ ទៅកាន់អាកាសយានដ្ឋានពោធិចិនតុងវិញ របៀបដូចគ្រាទទួលមកដែរ។ នៅវេលាព្រឹកថ្ងៃនោះពោរពេញជាមហាអស្ចារ្យ ដោយសារមនុស្សបានមកពេញវាលអាកាសយានដ្ឋានពោធិចិនតុង ហើយចាល់មនុស្សតាមផ្លូវមកភ្នំពេញចម្ងាយ ១០គ.ម នាំអោយអ្នកភ្នំពេញទៅពោធិចិនតុងពុំរួច។ ជិតដល់ពេលព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ស្តេចយាងចេញទៅពោធិ-ចិនតុងហើយ ក៏នាយស្នងការដ្ឋានក្រុង បើកផ្លូវសម្រាប់ព្រះរាជដំណើរពុំរួច។ លុះសម្តេចព្រះមហាសុមេ-ធាធិបតី និមន្តទៅមុនពុំរួចដែរ លោកគ្រាន់តែមានព្រះពុទ្ធដីកាដោយព្រះវាចាដ៏ផ្អែមត្រជាក់ ក៏រថយន្តបីបួនជួរលើថ្នល់នោះ ស្រាប់តែបែកគ្នាចុះទៅខាងថ្នល់អស់ ហើយមនុស្សសុខចិត្តដើរដោយជើងរហូតដល់ពោធិចិនតុងដោយក្តីរីករាយ។

ឆ្នាំ១៩៥៣ ព្រះរាជរដ្ឋាភិបាល បានតែងតាំងសម្តេចជាប្រធានគណៈប្រតិភូខ្មែរ (តាមសេចក្តីនិមន្តរបស់រដ្ឋាភិបាលនៃប្រទេសភូមា) និមន្តទៅបំពេញបេសកកម្មសុធន្ទៈ ប្រឹក្សាសម្រេចរឿងធ្វើឆដ្ឋ-សង្គាយនា នៅក្រុងរង្គូន សហភាពភូមា។

គ្រាដែលទ្រង់និវត្តពីប្រទេសភូមាវិញ ទ្រង់ឆៀងចូលក្រុងបាងកក ប្រទេសថៃ, ទ្រង់បានទស្សនាឈាបនដ្ឋានរបស់សៀម ទ្រង់សព្វព្រះហ្ឫទ័យក៏និមន្តព្រះសង្ឃសៀមមួយអង្គ ដែលជាអ្នកស្ថាបនាឈាបន

ដ្ឋាននោះ ឲ្យមកធ្វើជាអ្នកបង្ហាប់ការស្ថាបនាឈាបនដ្ឋានក្នុងវត្តឧណ្ណាលោម ក្រុងភ្នំពេញ ជាដំបូងបំផុត។ ឥឡូវនេះ ឈាបនដ្ឋានដែលវត្តឯទៀតៗ បានស្ថាបនាឡើងតាមគម្រូនេះ មានកាន់តែច្រើនឡើងហើយ។

ឆ្នាំ១៩៥៤ ព្រះរាជរដ្ឋាភិបាលបានតែងតាំងសម្តេច ជាប្រធានគណៈប្រតិភូខ្មែរ និមន្តទៅកាន់ក្រុងរង្គូន សហភាពភូមាម្តងទៀត ដើម្បីចូលរួមក្នុងការប្រជុំធ្វើឆដ្ឋសង្គាយនា សម័យប្រជុំដំបូង។ ក្នុងគ្រានោះ រដ្ឋាភិបាលនៃសហភាពភូមា បានថ្វាយប្រគេនព្រះឋានៈសម្តេចជា **ព្រះអគ្គមហាបណ្ឌិត** នៃសហភាពភូមា ។

ក្នុងឆ្នាំដដែលនេះ សម្តេចបាននិពន្ធសៀវភៅមួយឲ្យឈ្មោះថា ***អក្ខរវិធីសង្ខេប*** ។

ឆ្នាំ១៩៥៥ សម្តេចបានកសាង **សត្យមុនីចេតីយ៍** នៅចំខាងមុខស្ថានីយ៍រាជាយស្ម័យយាន ក្រុងភ្នំពេញ ក្រោមព្រះរាជូបត្ថម្ភ នៃព្រះករុណាជាអម្ចាស់ជីវិត (ដោយមានប្រាក់សល់ច្រើនម៉ឺន ពីគ្រាហែព្រះសារីរិកធាតុជាដើមទុន)។ ព្រះសត្យមុនីចេតីយ៍នេះ កសាងឡើងសំរាប់តម្កល់ព្រះបរមសារីរិកធាតុ ដែលនឹងត្រូវប្រោរព្ធពិធីបុណ្យ **ពុទ្ធសតវត្សរ៍ ២៥០០** ឬ**បុណ្យពាក់កណ្តាលសាសនា** (**២៥០០ ព្រះវស្សា**) នាឆ្នាំ១៩៥៧ (ពីរឆ្នាំក្រោយ)។

ក្នុងឆ្នាំដដែលនេះ សម្តេចបានទទួលនាទីជាប្រធានគណៈប្រតិភូខ្មែរ និមន្តទៅកាន់ទីឆដ្ឋសង្គាយនា ក្រុងរង្គូន ប្រទេសភូមាជាលើកទីបី ដើម្បីប្រជុំ ហើយបិទសម័យប្រជុំប្រចាំឆ្នាំ។

ឆ្នាំ១៩៥៦ សម្តេចបានកសាងវិហារថ្មីក្នុងវត្តឧណ្ណាលោម ដែលជាវិហារធំបំផុតជាងវិហារទាំងអស់ក្នុងប្រទេសកម្ពុជា។ វិហារនោះមាន ៣ជាន់, មានមុខ ៤ និងមានកំពូលជាប្រាង្គក្បាច់អង្គរ។ ក្នុងជាន់នីមួយៗ មានសម្ភារៈគ្រប់គ្រាន់គឺ: ជាន់ក្រោមមានតុ កៅអី សម្រាប់ប្រជុំ និងសិក្សា, ជាន់កណ្តាលសម្រាប់ធ្វើសង្ឃកម្ម ព្រមទាំងប្រជុំធ្វើបុណ្យ ស្តាប់ធម៌ទេសនា, ជាន់លើបំផុតសម្រាប់តម្កល់បូជនីយវត្ថុ មានព្រះពុទ្ធរូបបុរាណជាដើម។

ឆ្នាំ១៩៥៦ ដដែល សម្តេចបាននិពន្ធសៀវភៅវិន័យមួយឲ្យឈ្មោះថា **បព្វជ្ជូបសម្បទា** ដើម្បីបោះពុម្ពចែកក្នុងពិធីបុណ្យ **ពុទ្ធសតវត្សរ៍ ២៥០០** ឬ **បុណ្យពាក់កណ្តាលសាសនា** ។

ឆ្នាំ១៩៥៧ សម្តេចបានចាត់ការអស់ពីព្រះទ័យ ក្នុងការរៀបចំពិធីបុណ្យពុទ្ធសតវត្សរ៍ ២៥០០ ឬបុណ្យពាក់កណ្តាលសាសនា ព្រមទាំងបញ្ចុះព្រះសារីរិកធាតុ ឆ្លងព្រះសត្យមុនីចេតីយ៍ ក្នុងពេលនេះតែ

ម្តង។ នេះគឺជាពិធីបុណ្យប្លែក គិតតាំងពីព្រះពុទ្ធបរមគ្រូទ្រង់ចូលបរិនិព្វានកន្លងទៅ ២៥០០ឆ្នាំហើយ ពុំដែលមានប្រទេសណាធ្វើបុណ្យនេះម្តងសោះ។ បុណ្យនេះ ក៏អស្ចារ្យណាស់ដែរ។



ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភ ទ្រង់ទទួលព្រះបរមសារីរិកធាតុពីលោកប្រធានពុទ្ធិកសមាគមពោធិគយា ប្រទេសឥណ្ឌា ដែលដង្ហែចុះពីយន្តហោះ ជាមួយនឹងសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** នៅអាកាសយានដ្ឋានពោធិចិនតុង នាថ្ងៃទី ០៤ ខែតុលា ឆ្នាំ១៩៥២...



សម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** សង្ឃនាយកគណៈមហានិកាយ មានព្រះរាជឱង្ការក្នុងព្រះរាជពិធីទទួល ព្រះបរមសារីរិកធាតុ នៅអាកាសយានដ្ឋានពោធិចិនតុង រាជធានីភ្នំពេញ។ (រូបថតថ្ងៃទី ០៤ ខែតុលា ឆ្នាំ១៩៥២)



អាចារ្យ ៤នាក់គឺ **ម៉ី នាង**, **ទិន ហួត**, ខ្ញុំ (**ឈឹម ស៊ុម**), និង **ញូង សឿន** ចាំគោរពព្រះបរមសារីរិកធាតុ ក្បែររថយន្តបុស្បុក ដែលស្អិតស្អាងសម្រាប់តម្កល់ព្រះបរមសារីរិកធាតុ ដើម្បីដង្ហែចេញពីអាកាសយានដ្ឋានពោធិចិនតុង មកក្រុងភ្នំពេញ ក្នុងគ្រាចប់សេចក្តីស្វាគមន៍នៃសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** សង្ឃនាយកគណៈមហានិកាយ។ (រូបថតថ្ងៃទី ០៤ ខែតុលា ឆ្នាំ១៩៥២)



ក្រោយពេលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រមទាំងព្រះរាជវង្សានុវង្ស និងនាហ្មឺនសព្វមុខមន្ត្រី ដង្ហែព្រះបរមសារីរិកធាតុ ទៅតម្កល់លើរថយន្តបុស្បុក ដែលមានអាចារ្យ ៤នាក់អមព្រះកោដ្ឋ មានលោកវរសេនីយ៍ **ប៉ុក សំអាន** ជានាយបញ្ជាការ ហើយព្រះករុណាទ្រង់រៀបឡើងគង់ព្រះទីនាំងរថយន្តដង្ហែមកក្រុងភ្នំពេញ។ (រូបថតថ្ងៃទី ០៤ ខែតុលា ឆ្នាំ១៩៥២)



សម្ដេចព្រះមហាសុមេធាធិបតី **ជួន ណាត** សង្ឃនាយកគណៈមហានិកាយ កំពុងសន្ទនាដោយក្ដីរីករាយជាមួយនឹងព្រះសង្ឃបរទេស រួមមាន អាល្លឺម៉ង់, ឥណ្ឌា និងលង្កា នៅក្នុងបរិវេណវិហារព្រះកែវមរកត ក្នុងគ្រាដែលតម្កល់ព្រះបរមសារីរិកធាតុ ក្នុងព្រះវិហារនេះហើយ។ (រូបថតថ្ងៃទី ០៤ ខែតុលា ឆ្នាំ១៩៥២)



រថយន្តបុស្បុកតម្កល់ព្រះបរមសារីរិកធាតុ ដង្ហែចេញពីក្រុងភ្នំពេញ ជូនព្រះដំណើរទៅកាន់អាកាសយានដ្ឋានពោធិចិនតុងវិញ មានរបៀបដូចគ្រាទទួលព្រះដំណើរចូលមកដូច្នោះដែរ, ប្លែកតែមនុស្សច្រើនជាងមុន ត្រៀមចាំគោរពពេញវាលពោធិចិនតុង ហើយចាល់កកកុញទញ់តាមផ្លូវចម្ងាយ ១០គ.ម ជាហេតុញ៉ាំងក្បួនហែពីភ្នំពេញ ចេញទៅកាន់អាកាសយានដ្ឋានពោធិចិនតុង បានដោយលំបាក។ (រូបថតថ្ងៃទី ១១ ខែតុលា ឆ្នាំ១៩៥២)



ព្រះបរមសារីរិកធាតុនៃព្រះសត្យមុនីគោតម ក្នុងកញ្ចានុកោដ្ឋនេះ ជាព្រះរាជទ្រព្យសម្តេចព្រះឧបយុវរាជ **នរោត្តម សីហនុ** ដែលជាតង្វាយនៃពុទ្ធសាសនិកអ្នកលង្កាទ្វីប។ គ្រានោះទ្រង់ប្រគេនផ្ទាល់ព្រះហស្តសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** សង្ឃនាយកគណៈមហានិកាយ លើព្រះទីន័ងទេវាវិនិច្ឆ័យ ដើម្បីតម្កល់លើយានបុស្បុក ដង្ហែទៅកាន់សត្យមុនីចេតីយ៍។
(រូបថតថ្ងៃទី ១២ ខែឧសភា ឆ្នាំ១៩៥៧)



សម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** សង្ឃនាយកគណៈមហានិកាយ បានតម្កល់ព្រះបរមសារីរិកធាតុលើព្រះរាជរថបុស្បុក ហើយក្បួនហែជាមហោឡារិក ក៏ចេញពីមុខព្រះបរមរាជវាំង កាត់តាមវិថីនានាក្នុងរាជធានី រហូតដល់ព្រះសត្យមុនីចេតីយ៍ ដែលមានរោងពិធីសុទ្ធតែជាអាគារធើតៗ សណ្ឋានដូចព្រះវិហារល្អៗ គួរអោយកើតសទ្ធា និងសេចក្តីជ្រះថ្លារំភើបក្នុងហឫទ័យនៃទស្សនិកជន។ (រូបថតថ្ងៃទី ១២ ខែឧសភា ឆ្នាំ១៩៥៧)



នៅថ្ងៃបង្ហើយនៃព្រះរាជពិធីបុណ្យ, ឯកឧត្តមមហាមន្ត្រី **ញ៉ឹក នូ** បានរំកិលលើកព្រះកាញ្ចានុកោដ្ឋព្រះបរមសារីរិកធាតុពីបុស្បុកវិចិត្រ ប្រគេនមកសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** ។ សម្តេចទទួលទ្រចុះបាន ១កាំជណ្តើរ បានថ្វាយព្រះកាញ្ចានុកោដ្ឋនោះមក ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សុរាម្រឹត** ។ ព្រះភូមិន្ទទ្រង់ទ្រស្ងួយចុះមក យាងដល់ព្រះសត្យមុនីចេតីយ៍ ទើបព្រះនរបតីប្រគល់ទៅសម្តេចព្រះឧបយុវរាជ **ព្រះនរោត្តម សីហនុ** ។ សម្តេចព្រះឧបយុវរាជ ទ្រង់ទ្រឡើងតាមព្រះអឡ្ឌចណ្ឌ(ជណ្តើរ) ដ៏ខ្ពស់ ទៅតម្កល់ជាស្ថាពរឰដ៏ព្រះថៃនក្នុងកំពូលនៃព្រះសត្យមុនីចេតីយ៍។ (រូបថតថ្ងៃទី ១៨ ខែឧសភា ឆ្នាំ១៩៥៧)

ឆ្នាំ១៩៥៧ ជដែល រដ្ឋាភិបាលនៃសហភាពភូមា បានតម្លើងព្រះឋានៈសម្តេចជា **ព្រះអគ្គមហាបណ្ឌិត** នៃសហភាពភូមា ដែលជាសមណសក្តិដ៏ខ្ពង់ខ្ពស់បំផុតក្នុងសហភាពភូមា។

ឆ្នាំ១៩៥៩ ព្រះរាជរដ្ឋាភិបាលបានតែងតាំងសម្តេច ជាប្រធានគណៈប្រតិភូខ្មែរ និមន្តទៅកាន់ទីក្រុងជះកាតា (ហ្សាការតា) និងក្រុងស៊ីម៉ារាំង (កោះជ្វា) ប្រទេសឥណ្ឌូណេស៊ី ដើម្បីរួបរួមក្នុងពិធីបុណ្យពិសាខបូជា ព.ស ២៥០២ ពិធីបញ្ចុះខណ្ឌសីមា និងពិធីសន្ធត់រោងឧបោសថ ព្រមទាំងជាព្រះឧបជ្ឈាយ៍បំបួសកុលបុត្រអ្នកប្រទេសនោះ ចំនួនបីរូបផង...។

ឆ្នាំ១៩៦១-៦២ សម្តេចបានស្ថាបនាស្ពានបេតុងអារម៉េពីរអន្លើរ ត្រង់ព្រៃវត្តពោធិព្រឹក្ស ហើយបានស្ថាបនាមន្ទីរពេទ្យមួយខ្នង ដោយបេតុងអារម៉េប្រក់ក្បឿង ឲ្យឈ្មោះថា គិលានដ្ឋាន **ចម្រើនសុខភាព** ត្រង់ភូមិស្រែបន្ទាយ សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយមានឈ្មោះ **យ៉ា** ប្រពន្ធឈ្មោះ **ឡូ** បានថ្វាយដី។ អាគារនេះស្តុកស្តម្ភ ប្រកបដោយសម្ភារៈគ្រប់យ៉ាងឥតខ្វះ និងមានកំពែងឥដ្ឋព័ទ្ធជុំវិញ ទទឹង ៥២ម បណ្តោយ ១០០ម ។ កំពែងឥដ្ឋនោះ មានសួនច្បារដាគ្រឿងលម្អនៅខាងមុខ, មានដំណាំគ្រឿងគ្រៅតាំងពីស្លឹកគ្រៃ ជី ម្ទេសជាដើម ដែលដាំជាសង្កាត់ដូចសួនច្បារដែរ នៅខាងក្រោយ, មានរោងដាក់ជីសម្រាប់ដំណាំផ្សេងៗ, មានអណ្តូងទឹក ព្រមទាំងស្នប់បូមគ្រប់គ្រាន់។ ក្នុងអាគារធំខ័ណ្ឌជាកន្លែងសម្រាប់គ្រូពេទ្យ ព្រមទាំងគ្រួសារស្នាក់នៅ មានគ្រែ មានពូក មានតុកៅអី និងទូដាក់ឥវ៉ាន់សម្រាប់គ្រូពេទ្យប្រើប្រាស់។ ខណ្ឌមួយសង្កាត់ទៀត សម្រាប់គ្រូពេទ្យព្យាបាលជម្ងឺ និងមួយសង្កាត់ទៀត សម្រាប់គ្រូពេទ្យពិនិត្យរោគ។ បន្ទប់ទាំងពីរនេះ មានសម្ភារៈសម្រាប់ពេទ្យ សម្រាប់អ្នកជម្ងឺគ្រប់គ្រាន់។ ផ្ទះបាយ មានបាស្សាំងតម្កល់ទឹកភ្លៀងពេលលើដំបូល។ ក្នុងបន្ទប់ចង្ក្រាន មានចង្ក្រានចានឆ្នាំង រហូតដល់កន្ត្រងប្រហុក។

កាលគិលានដ្ឋានចម្រើនសុខភាព នេះហើយស្រេច សម្តេចបានគ្រួសកិនផ្លូវលំចម្ងាយ ៣គ.ម ទល់នឹងស្ពានបេតុងអារម៉េព្រៃវត្តពោធិព្រឹក្ស ទ្រង់បានអោយជីកអណ្តូងមានប្រដាប់យោងទឹក ១៦កន្លែង និងអណ្តូងប្រើស្នប់បូមទឹក ៣កន្លែង រាប់តាំងពីក្នុងមន្ទីរពេទ្យតាមផ្លូវគ្រួសក្រហម រហូតដល់វត្តពោធិព្រឹក្ស ហើយទ្រង់ធ្វើបុណ្យសម្ពោធឆ្លង ១យប់ ១ថ្ងៃ គឺចូលបុណ្យនៅថ្ងៃ ១០កើត ខែមេឃ ឆ្នាំឆ្លូវត្រីស័ក ព.ស ២៥០៤ គ.ស ១៩៦៣ ។

តមកសម្តេចបានស្ថាបនាមន្ទីរពេទ្យធ្មបមួយខ្នងទៀត ទន្ទឹមគ្នានឹងអាគារមុន ហើយបានស្ថាបនាអាគារមួយខ្នងទៀតដោយបេតុងអាម៉េដែរ សម្រាប់ស្ត្រីមានគភ៌សម្នាក់។ បានស្ថាបនាអាគារមួយខ្នងទៀត ខាងជើងស្រះទល់មុខនឹងមន្ទីរពេទ្យនេះ ឲ្យឈ្មោះថា **អាស្រមមនោរម្យ** សម្រាប់បព្វជិតសម្នាក់, បានដាំផលព្រឹក្ស ដែលបានពូជពីស្រុកផ្សេងៗចំនួនច្រើនមុខ ជាប្រយោជន៍ដល់មន្ទីរពេទ្យនេះ។

ក្នុងគ្រាជាមួយគ្នានេះ សម្តេចបានឧបត្ថម្ភលើកផ្លូវលំមួយទៀត តអំពីផ្លូវមុន បែកគ្នាពីត្រឹមព្រំខាងត្បូងនៃវត្តពោធិព្រឹក្ស បត់កាត់មុខវត្តទៅជើង ចម្ងាយ ៣គ.ម ទៀតដល់ស្ទឹងធំ។ ផ្លូវនេះក៏បានចាក់គ្រួសក្រម ដោយអន្លើដែរ។

ឆ្នាំ១៩៦២ ដដែល សម្តេចបានទទួល**មេដាយមហាសិរីវឌ្ឍន៍** នៃព្រះរាជាណាចក្រកម្ពុជា។

ឆ្នាំ១៩៦៣ សម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា ទ្រង់បានប្រោសប្រគេនព្រះឋានៈសម្តេចជា **សម្តេចព្រះសង្ឃរាជថ្នាក់ទី១** ។ នៅក្នុងឆ្នាំនោះ សម្តេចទ្រង់និពន្ធ «ប្រវត្តិនៃវត្តឧណ្ណាលោម» ។

ឆ្នាំ១៩៦៣ ដដែល សមាគមអ្នកនិពន្ធខ្មែរមានលោក **ហ៊ើល ស៊ុំផា** ជាប្រធាន និងក្រសួងឃោសនាការជាតិ បាននិមន្តសម្តេចព្រះសង្ឃរាជជាអម្ចាស់ ទៅធ្វើការសម្ភាសន៍អក្សរសាស្ត្ររាល់ថ្ងៃពុធនៅបន្ទប់វិទ្យុជាតិ ក្រុងភ្នំពេញ ចាប់តាំងពីថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ១៩៦៣ ជាប់រហូតមកដល់ឆ្នាំ១៩៦៩ ជាទីបំផុត ដែលមានអ្នកស្នេហាអក្សរសាស្ត្រជាតិចូលស្តាប់ ចូលក្រាបបង្គំទូលសួរកកកុញជានិច្ច។ ជាពិសេសមានសហជីវិន **គុយ ឡុត** ជាអ្នកបំរើខ្ជាប់ក្នុងមុខការនេះ រហូតដល់អវសានកាល។

ឆ្នាំ១៩៦៤ សមាគមអ្នកនិពន្ធខ្មែរបានថ្វាយព្រះឋានៈ ចំពោះសម្តេចព្រះសង្ឃរាជជា **ព្រះអគ្គនិពន្ធអក្សរសាស្ត្រខ្មែរ** ។ ក្នុងឆ្នាំដដែលនេះ សម្តេចបានប្រែរៀបរៀងសៀវភៅ **ប្រជុំជម៌កិច្ចវត្តព្រឹកល្ងាច** ហើយទ្រង់តែងសៀវភៅ **វប្បសិទ្ធិគាថា** មួយទៀត ជាគាថាប្រសិទ្ធិពរសម្រាប់សូត្រក្នុងវត្តជោតញ្ញាណ ក្រុងព្រះសីហនុ មានសេចក្តីប្រែជាសម្រាយផង។

ឆ្នាំ១៩៦៥ សម្តេចបាននិពន្ធសៀវភៅ **មានគាថា** សៀវភៅ **អនុស្សរណធម៌** និងសៀវភៅ **ឧបស្សយានិសង្ស**, បានឧបត្ថម្ភសាលាសម្នាក់មួយ ដោយបេតុងអារម៉េសុទ្ធ នៅត្រង់ជិតស្ទឹងធំ ចុងផ្លូវលំដែលបែកចូលទៅវត្តពោធិព្រឹក្ស។ សាលានេះ ឯកឧត្តម **ស៊ុម ហៀង** ចំណាយប្រាក់កសាង ព្រមទាំងបានជាវសៀវភៅ **ឧបស្សយានិសង្ស** ដើម្បីចែកជាធម្មទានក្នុងពិធីបុណ្យឆ្លងសាលានេះ។

ឆ្នាំ១៩៦៦ សម្តេចបាននិពន្ធសៀវភៅ **កម្មជារបស់ខ្លួនរាល់ប្រាណ** និងសៀវភៅ **ពិធីច្រូចជីក** ។

ឆ្នាំ១៩៦៧ សម្តេចបាននិពន្ធសៀវភៅ **បឋមកឋិនសិក្ខាបទ** ជាវិន័យប្បញ្ញត្តិខាងការប្រើប្រាស់ស្បង់ចីពរសម្រាប់ពួកភិក្ខុ។

នៅព្រឹកថ្ងៃទី ២៨ ខែឧសភា ឆ្នាំ១៩៦៧ ដដែល ទ្រង់បានទទួលសញ្ញាប័ត្រ **បណ្ឌិតអក្សរសាស្ត្រ** ពេញលក្ខណៈអំពីសម្តេចព្រះប្រមុខរដ្ឋ ក្នុងនាមមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ នៃសកលវិទ្យាល័យភូមិន្ទ ក្រុងភ្នំពេញ។

ក្នុងឆ្នាំដដែលនេះ សម្តេចបានផ្តើមកសាងឧបដ្ឋានសាលាក្នុងវត្តឧណ្ណាលោម សំរាប់ប្រើក្នុងពេលប្រជុំ, ប្រគេនភត្តាហារនាឱកាសបុណ្យទានធំៗ និងភ្ជុំបិណ្ឌ។ ឧបដ្ឋានសាលានេះ គហបតី **លី ស៊ុនខន**, មហាឧបាសិកា **តាន់ ស៊ីមី**, ប្រធានគណៈកម្មការវត្តនេះចេញប្រាក់ ព្រមទាំងចាត់ការសាងដោយខ្លួនឯង។

ឆ្នាំ១៩៦៨ សម្តេចបាននិពន្ធសៀវភៅវិន័យមួយឈ្មោះថា ***ចីវរក្ខន្ធកៈពិស្តារ*** ជាវិន័យចែងយ៉ាងច្បាស់អំពីការកាត់ដេរស្បង់ចីពរ ។

ឆ្នាំ១៩៦៩ សម្តេចបាននិពន្ធសៀវភៅ ***វឌ្ឍកីសូករជាតក*** ជាជាតកមួយ ទាក់ទងនឹងព្រះរាជប្បវេណី **ពិធីធ្វើរាជាភិសេក** ក្នុងព្រះបរមរាជវាំង។ សៀវភៅនេះ ជាស្នាព្រះហស្ថយ៉ាងឯក ដែលទ្រង់ប្រែពីបាលី ព្រាងសេចក្តីពីខ្មែរ ដោយព្រះលាយលក្ខណ៍អក្សរផ្ទាល់ព្រះហស្ថជាតួអក្សរច្រៀង ពេញតួទាំងអស់ ល្អគួរអោយសរសើរ ឥតមានជួសចម្លងជាពីរច្បាប់ទេ។

ក្នុងឆ្នាំនេះ ទ្រង់ចាត់អោយរុះកំពែងចាស់នៃវត្តឧណ្ណាលោម ដើម្បីធ្វើជាថ្មីឡើងវិញ រចនាដោយកង់ធម្មចក្រ និងក្លោងទ្វារគ្រប់ច្រកទាំងអស់ រចនាដោយក្បាច់អង្គរ...។

តាំងពីព្រះអង្គបានទទួលព្រះឋានៈជាសម្តេចព្រះសង្ឃរាជមក ទ្រង់មានព្រះរាជករណីកិច្ចកាន់តែមមាញឹកឡើង គឺព្រះអង្គទ្រង់ប្រឹងខាងការស្ថាបនាសមិទ្ធិផលផ្សេងៗ ជាពិសេសគឺ **មហាស្រះ** ជិតមន្ទីរពេទ្យ ក្នុងសង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

សម្តេចព្រះសង្ឃរាជជាអម្ចាស់ ទ្រង់បានជាវដីមួយមួយកន្លែង ដើម្បីស្ថាបនាមហាស្រះមួយដ៏ធំមានបណ្តោយប្រវែង ៨០០ម ទទឹង ៥០០ម ។ ទ្រង់បានផ្តើមជីកមហាស្រះនេះ តាំងពីឆ្នាំ១៩៦៧ ដោយពឹងផ្អែកលើសាលាខេត្តកំពង់ស្ពឺ រហូតមកដល់ឆ្នាំ១៩៦៩ នេះ ទើបសម្តេចព្រះប្រមុខរដ្ឋ **ព្រះបាទនរោត្តម សីហនុ** ទ្រង់ត្រាស់ព្រះរាជបញ្ជាទៅលោកអនុរដ្ឋលេខាធិការ **ប៉ាវ អ៊ិត** អោយរកគ្រឿងចក្រ

មានត្រាក់ទ័រជាដើម បានចំនួនច្រើនគ្រឿង ទៅជីកបង្ហើយមហាស្រះនោះ។ មិនតែប៉ុណ្ណោះ ឯកឧត្តម **រឿម សុផុន** ក៏បានចាត់លោក **និន នេរុំម** ឲ្យទៅជួយដែរ ទើបមហាស្រះនោះ បានការល្មមតម្កល់ទឹកទុកបានខួបប្រាំងខួបវស្សា។ ក្នុងវស្សានរដូវឆ្នាំ១៩៦៩ កន្លែងដែលជ្រៅជាងគេ មានទឹកជម្រៅ ៥ម, ឯកន្លែងដែលរាក់ជាងគេ មានទឹកជម្រៅពី ២ម-៣ម ។ លោក **ប៉ាវ អ៊ិត** បានចាត់អោយចាក់គ្រួសក្រហមលើខ្នងផ្លូវព័ទ្ធជុំវិញមហាស្រះនោះ ព្រមទាំងនាំពូជឫស្សីដើមធំៗ ពីខេត្តកំពង់ចាម មកដាំជុំវិញមហាស្រះផង, ប៉ុន្តែឫស្សីនេះប្រហែលមិនរស់ទេ ព្រោះដីត្រង់កន្លែងនោះ សម្តេចធ្លាប់យកពូជឫស្សីពីខេត្តក្រចេះ មកដាំពុំរស់ទៅហើយ។

ក្នុងគ្រាសម្តេចទៅគង់ទំនុកបំរុងបាយទឹក ដល់ពួកអ្នកជីកមហាស្រះនោះអស់រយៈពេល ៧ខែ ទ្រង់ចាត់ឲ្យធ្វើអាគារមួយខ្នងជូនរាជការ ជាសាលាសង្កាត់រកាកោះ ហើយមួយខ្នងទៀតជាសាលាសម្នាក់ជិតៗគ្នានឹងសាលាសម្នាក់មុនៗ...។



មហាស្រះសម្តេចព្រះសង្ឃរាជ ស្ថិតក្នុងភូមិរកាកោះ...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




មហាស្រះសម្តេចព្រះសង្ឃរាជ ស្ថិតក្នុងភូមិរកាកោះ...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)




សាលាសំណាក់ កសាងដោយឯកឧត្តម ស៊ុម ហៀង
ស្ថិតក្នុងភូមិកំរៀង ដែលបានសម្ពោធកាលពីឆ្នាំ១៩៦៥...
(រូបថតស្រុកស្រែ-ខែតុលា ឆ្នាំ២០១២)

ឯសមិទ្ធិផ្នែកខាងពុទ្ធសាសនា មិនត្រឹមតែវត្តឧណ្ណាលោមទេ វត្តឯទៀតៗ ក៏សម្តេចខំប្រឹងកសាង ដែរដូចជា៖

- វិហារបេតុងអារម៉េមួយ ក្នុងវត្តកន្សែងសម ស្រុកថ្កង ខេត្តកំពង់ស្ពឺ។
- កសាងបន្ថែមនូវទីសេនាសនៈ ព្រមទាំងតុបតែងលម្អវត្តជោតញ្ញាណ ក្រុងព្រះសីហនុ។
- បានឧបត្ថម្ភក្នុងការកសាងវត្តនារាយណ៍មួយទាំងមូល នៅជិតភ្នំនារាយណ៍ ព្រំប្រទល់ខេត្តតាកែវ និងខេត្តកំពត។
- កសាងវត្តមុនីវង្សី (ហៅវត្តឃ្លាំង) ក្នុងស្រុកស្ទោង ខេត្តកំពង់ធំ។
- កសាងវត្តជោតញ្ញាណ ក្នុងខេត្តកោះកុង។
- វិហារមួយខ្នង នៅក្នុងបរិវេណមន្ទីរពេទ្យព្រះសង្ឃ ដែលមានគហបតី **តាន់ ហុងអាន** ជាអ្នកបរិច្ចាគប្រាក់កសាង។

ផ្នែកខាងធម្មវិន័យ ក៏សម្តេចខំប្រឹងប្រែងណាស់គឺ៖

- ទ្រង់បានដឹកនាំអោយតាំងសាលាធម្មវិន័យ មានថ្នាក់ត្រី ទោ ឯក ស្ទើរគ្រប់វត្ត ក្នុងប្រទេសកម្ពុជា។
- សម្តេចបានបង្កើតការអប់រំកុមារ សិស្សវត្តឧណ្ណាលោម ដោយការឲ្យប្រជុំរាល់សប្តាហ៍ ក្នុងព្រះវិហារថ្នាក់ក្រោមបំផុត។
- អនុសំវច្ឆរមហាសន្និបាត (ការប្រជុំមន្ត្រីសង្ឃនៅរាជធានី និងខេត្តក្រៅមួយឆ្នាំម្តង) ក្នុងវត្តឧណ្ណាលោម ដែលពីដើមធ្លាប់ប្រជុំ ៣ថ្ងៃ ឡើងមក ៥ថ្ងៃ រួចឡើងរហូតដល់ ៧យប់ ៧ថ្ងៃ ដើម្បីទ្រង់បានឪកាសពន្យល់ធម៌វិន័យ ព្រះរាជដំបូន្មាន ព្រមទាំងពន្យល់របៀបធ្វើការមានរបៀបដូចៗគ្នា។ ទាំងថ្ងៃទាំងយប់នៃអនុសំវច្ឆរមហាសន្និបាតម្តងៗ ឮតែព្រះសូរសៀងកកោកតាមឧឃោសនស័ព្ទ ដែលមានព្រះសង្ឃទាំងពាន់ៗ ចាំស្តាប់មិនចេះឆ្អែតឆ្អន់។ ព្រះអង្គឥតធុញទ្រាន់ក្នុងការនេះសោះ ព្រមទាំងឥតត្អូញថា អស់ព្រះកាយពលឡើយ។ ព្រះជន្ម ៨៦ឆ្នាំហើយ ប៉ុន្តែព្រះសូរសៀងនៅក្មេង ច្បាស់ទែងដូចជាស្ថិតក្នុងមជ្ឈិមវ័យ។
- ការនិពន្ធសៀវភៅធម៌វិន័យ សុទ្ធតែទ្រង់សរសេរផ្ទាល់ព្រះហស្តរបស់ព្រះអង្គ បានសៀវភៅច្រើនក្បាលជាងកាលទ្រង់ឋិតនៅក្នុងមជ្ឈិមវ័យទៅទៀត។
- ការពន្យល់អក្សរសាស្ត្រ ក៏ទ្រង់ខំប្រឹងណាស់ ស្តេចទ្រង់និមន្តទៅកាន់វិទ្យុជាតិរាល់ថ្ងៃពុធ ដើម្បីដោះស្រាយអក្សរសាស្ត្រ តាមសំណួរដែលគេសួរដោយផ្ទាល់ក៏មាន គេផ្ញើសំណួរមកសមាគមអ្នកនិពន្ធខ្មែរក៏មាន ទ្រង់អាចដោះស្រាយផ្សាយតាមវិទ្យុជាតិ បំភ្លឺសាធារណជនទូទៅបានភ្លាមៗ ។

- ជាពិសេស សម្តេចព្រះសង្ឃរាជជាអម្ចាស់ ទ្រង់យកព្រះរាជហឫទ័យទុកដាក់ណាស់ចំពោះ **វចនានុក្រមខ្មែរ** ដែលជាស្នាព្រះហស្តពីដើមរបស់ព្រះអង្គ គឺទ្រង់ខំរកពាក្យបំពេញបន្ថែមទៀត ទ្រង់ឆ្លៀតខំធ្វើការនេះទាំងយប់ទាំងថ្ងៃ ពុំសូវមានពេលផ្ទំសោះ ព្រះហស្តមានដងប៉ាកាជាប់ជានិច្ចលើកលែងតែពេលផ្ទំស្តល់ និងពេលសោយព្រះស្ងោយចេញ, ក្រៅពីនេះ ទ្រង់គង់សរសេរលើក្រឡាព្រះបន្ទំទើសៗក្តី ទោះបីមានព្រះរាជដំណើរទៅតាមរថយន្តក្តី លើអាកាសយានក្តី ក៏ទ្រង់សរសេរដែរ គឺថា នឹកឃើញត្រង់ណា សរសេរត្រង់នោះ មិនបាច់មានតុកៅអីទេ ទល់គ្នានឹងថ្ងៃចាប់អាពាធក្នុងទីបំផុត ក៏ទ្រង់អាពាធដោយមានដងប៉ាកកាជាប់នឹងព្រះហស្តដែរ។



សម្តេចព្រះសង្ឃរាជ ជួន ណាត ទ្រង់គង់សរសេរបែបនេះ...

សម្តេចព្រះសង្ឃរាជជាអម្ចាស់ ជាអច្ឆរិយបុរសមួយអង្គកម្ររកបាន, ព្រះអង្គមានការព្យាយាមហួសប្រមាណ ហាក់ដូចជាឥតបានគិតថា ព្រះអង្គមានព្រះជន្ម ៨៦ឆ្នាំ ហើយសោះ, ទ្រង់ធ្វើការទាំងអស់ហាក់ដូចជាទ្រង់ស្មានថា ព្រះអង្គនឹងមានព្រះជន្មពីរបីរយឆ្នាំទៅមុខទៀត។ លុះមកដល់ថ្ងៃអង្គារ៍ ១២កើត ខែភទ្របទ ឆ្នាំរកាឯកស័ក ព.ស ២៥១៣ ត្រូវនឹងថ្ងៃទី ២៣ ខែកញ្ញា គ.ស ១៩៦៩ វេលាម៉ោង ១៥ និង

៤៥នាទី ស្រាប់តែមានរោគចម្លែក គឺចុកព្រះឱរា ក្នុងគ្រាដែលព្រះអង្គមានដងប៉ាកកាជាប់ក្នុងព្រះហស្ត កំពុងទ្រង់សរសេរពាក្យបន្ថែមវចនានុក្រមខ្មែរលើព្រះក្រឡាបន្ទំ។ រោគចម្លែកនេះ ជាធម្មជាតិបានបណ្តាលឲ្យផ្អើលទាំងបព្វជិត ទាំងគ្រហស្ថ ហួតដល់សម្តេចព្រះប្រមុខរដ្ឋ និងសម្តេចព្រះមហាក្សត្រីយានីជាអម្ចាស់ជីវិត ទ្រង់ជ្រាបភ្លាម ទ្រង់បញ្ជាវេជ្ជបណ្ឌិតធំៗ ទាំងខ្មែរទាំងបារាំង ឲ្យមកប្រជុំគ្នាព្យាបាល បានស្រាកស្រាន្តក្នុងវេលាយប់នោះ។

ព្រឹកឡើងថ្ងៃពុធ ខ្ញុំ(**ឈឹម ស៊ុម**) បានយកយាគូទៅថ្វាយ ទ្រង់សោយដោយព្រះរាជហឫទ័យរីករាយ ទ្រង់មានព្រះបន្ទូលអំពីការស្ថាបនាមហាស្រះ និងការជួសជុលកម្រាលបេតុងខឿនព្រះវិហារវត្តពោធិព្រឹក្ស ហើយទ្រង់សួរពីចៅៗ កូនរបស់ខ្ញុំ។ ខ្ញុំក៏ក្រាបបង្គំ លាត្រឡប់ទៅវិញ។




ព្រឹកស្អែកឡើងទៀត ថ្ងៃព្រហស្បតិ ភរិយាខ្ញុំយកយាគូទៅថ្វាយទៀត។ ទ្រង់មានព្រះបន្ទូលថា៖ *អញឆាន់បានតែបបររបស់នាង* ***សៀក*** *ឯងតាំងពីម្សិលមកម្ល៉េះ, ម្ហូបគេពោរពេសអញមិនហ៊ានឆាន់ ព្រោះគ្រូពេទ្យថាឆាន់បបរទើបស្រួល, ថ្ងៃរសៀលនេះ ឬស្អែក ចង់ទៅស្រែ, ទៅមើលមហាស្រះ, បើឯងទៅដែររកដំឡូងជ្រូក ស្ងោរអោយអញឆាន់ កុំដាក់អ្វីឲ្យសោះ ទុកឲ្យនៅរសជាតិកំណើតរបស់វា...* ។

ទ្រង់ផ្ទឹមមានព្រះបន្ទូលហៅកូនតូចរបស់ខ្ញុំ ឲ្យចូលទៅជិត ទ្រង់អង្អែលក្បាលចៅប្រាប់ថា៖ *អាស្រស់ឯងខំរៀន* ។ ភរិយាខ្ញុំត្រឡប់មកផ្ទះ ប្រុងប្រៀបខ្លួននឹងតាមហែព្រះអង្គទៅស្រែ ជាជាតិភូមិ ស្រាប់តែពេលព្រលប់ឮថា **ព្រះអង្គសោយទិវង្គត** ហើយ...។

ថ្ងៃនេះទី ១៨ ខែមករា ឆ្នាំ១៩៧០... បីខែ ម្ភៃប្រាំថ្ងៃកន្លងទៅហើយ ខ្ញុំលើកដៃសរសេររឿងនេះតទៅទៀតពុំរួច, ខ្ញុំសូមបញ្ចប់សេចក្តីនេះត្រឹមប៉ុណ្ណោះ... ៕

# ព្រះគុណសម្បត្តិនៃសម្តេចព្រះសង្ឃរាជ
# ជួន ណាត

ដោយព្រះមុនីកោសល **សូរ ហាយ**




ព្រះគុណសម្បត្តិនៃសម្តេចជាអម្ចាស់ មានច្រើនយ៉ាងណាស់ ប៉ុន្តែខ្ញុំបានពិចារណាដោយហ្មត់ចត់ ហើយសរសេររួបរួមប្រមូលយកចំពោះតែគោលធំៗ ដោយសង្ខេបមាន ៥យ៉ាង ដូចសេចក្តីរៀបរៀងតទៅនេះ៖

- វិរិយភាពក្នុងការសិក្សា
- បដិភាណបញ្ញា (ប្រាជ្ញាវាងវៃ)
- វេសារជ្ជបញ្ញា (ប្រាជ្ញាក្លៀវក្លាអង់អាច)
- ធម្មទេសនាកោសល្យ (ភាពឈ្លាសវៃក្នុងធម្មទេសនា)
- បណីតសកម្មភាព (សកម្មភាពដ៏ប្រសើរ)

## អធិប្បាយពង្រីកសេចក្តី ចំពោះគុណសម្បត្តិនីមួយៗ

### ១. វិរិយភាព

**វិរិយភាព** នៃសម្តេចជាអម្ចាស់ ដែលមនុស្សចាស់ទុំធ្លាប់បានសង្កេតតាំងពីសម្តេចមានព្រះជន្មនៅក្មេង គឺតាំងពីនៅជាសាមណេរដរាបមករហូតដល់សម្តេចមានព្រះជន្មជ្រុលចូល មកបច្ឆិមវ័យហើយ ក៏នៅតែព្យាយាមឥតមានបន្ធូរបន្ថយបញ្ឈប់សេចក្តីព្យាយាមនោះឡើយ សូម្បីព្រះអង្គមានសមណៈស័ក្តិដ៏ខ្ពស់បំផុតទីជាសម្តេចព្រះសង្ឃរាជ ហើយក៏ដោយ។

**វីរិយភាព** នេះប្រែថា សេចក្ដីព្យាយាម ឬថាប្រឹងប្រែង រាប់ថាជាបារមីមួយរបស់ព្រះពោធិសត្វដែលយើងធ្លាប់ចេះដឹងមកហើយ ហៅថា វីរយៈបារមី។ កិច្ចការទាំងឡាយគ្រប់យ៉ាង រមែងប្រកបដោយឧបសគ្គ គឺធម៌ជាគ្រឿងរារាំងបើមិនច្រើនក៏តិច តែថា បើសេចក្ដីព្យាយាម មានកម្លាំងក្លៀវក្លា ក៏អាចពុះពារចំពោះឧបសគ្គនោះបានដោយពិត។ សម្ដេចព្រះសង្ឃរាជទ្រង់មាន វីរយៈធម៌ដ៏រឹងប៉ឹងជាទីបំផុត បានជាព្រះអង្គចេះតែមានជ័យជម្នះសង្កត់ទៅលើឧបសគ្គគ្រប់យ៉ាងបាន ជាដរាប ទោះបីព្រះអង្គហត់នឿយណាស់ ក៏ព្រះអង្គនៅតែប្រឹង ព្រះអង្គមិនចេះត្អូញត្អែរឡើយ។

ករណីកិច្ចណាមួយដែលគេត្រូវធ្វើដោយកាយក្ដី ដោយវាចាក្ដី ដោយចិត្តក្ដីអាចសម្រេចទៅបានដោយកម្លាំងនៃសេចក្ដីព្យាយាមទាំង អស់។ ឥរិយាបទទាំង៤ គឺការដើរ ឈរ អង្គុយ ដេក ដែលនាំឲ្យសម្រេចប្រយោជន៍ទៅបាន ដ៏ដោយគុណានុភាពនៃសេចក្ដីព្យាយាមដែរ។

**សម្ដេចព្រះសង្ឃរាជ** ព្រះអង្គមានវីរិយបារមីដ៏បរិបូណ៌ណាស់ សូម្បីសម្ដេចដែលមានព្រះជន្ម៨៦ឆ្នាំហើយ ក៏នៅបំពេញកិច្ចការរបស់ព្រះអង្គឥតមានបន្ធូរបន្ថយព្រះកាយពលឡើយ។ ដូចយ៉ាងព្រះអង្គចាប់ធ្វើវចនានុក្រមខ្មែរ ទ្រង់ឥតមានសំចៃកម្លាំង និងពេលវេលាទេ។ សម្ដេចយកពេលយប់ធ្វើជាថ្ងៃ យកពេលថ្ងៃធ្វើជាយប់ ខំប្រឹងសរសេររៀបរៀងតាំងពីព្រលប់រហូតដល់ភ្លឺក៏មាន លុះទ្រង់សោយយាគូរួច ចាប់សរសេរតទៅទៀត ទាល់តែដល់ពេលម៉ោង១១ក៏មាន។ ក្នុងរយៈវេលាយប់មួយ ថ្ងៃមួយ សម្ដេចទ្រង់ផ្ទុំបានក្នុងរវាង៤ ឬ ៥ម៉ោងប៉ុណ្ណោះ។

ការប្រព្រឹត្តដោយសេចក្ដីព្យាយាម នៃសម្ដេចព្រះសង្ឃរាជនេះ ជាការកម្រមនុស្សធ្វើបានណាស់។

**<u>២. បដិភាណបញ្ញា</u>** (បញ្ញាវាងវៃ)

ប្រាជ្ញាសំដៅយកការចេះដឹងយល់ទូទៅ ឬការយល់ច្បាស់លាស់ចំពោះហេតុការណ៍ផ្សេងៗតាមធម្មតា។ ដែលលោកហៅថា បដិភាណ-ប្បញ្ញា នោះ សំដៅយកប្រាជ្ញាដែលកើតឡើងភ្លាមៗ ហើយអាចឆ្លើយតបវិញបានភ្លាម មិនបាច់គិតគូរអស់វេលាយូរទេ។ ប្រាជ្ញារបស់សម្ដេចកើតឡើងរហ័សក្នុងពេលដែលគេចោទសួរ ឬនិយាយឲ្យឮភ្លាមក៏អាចដឹងទាន់ចាប់ក្បឹកនឹកឃើញ ឆ្លើយវិញបានភ្លាម ហាក់ដូចជាបានគូសដៅទុកយូរហើយ។ ប្រាជ្ញាស្មារតីរហ័សរាងវៃ ប្រកបដោយសមត្ថភាព ឆាប់យល់ហេតុការណ៍គ្រប់យ៉ាង ដែលអាចដឹងទាន់ភ្លាមៗ ដូចអធិប្បាយដោយសង្ខេបមកនេះ ហៅថា **បដិភាណប្បញ្ញា** ។

**សម្ដេចព្រះសង្ឃរាជ** មានបដិភាណប្បញ្ញានេះបរិបូណ៌ណាស់ ដូចយ៉ាងសម្ដេចដែលបានទ្រង់យាងទៅកាន់ទីប្រជុំណាមួយ ដែលមានសមាជិកជាន់ខ្ពស់ ហើយគេត្រូវនិយាយពិភាក្សាការណ៍ជាចាំបាច់ ដែលទាក់ទងមកលើសម្ដេចភ្លាម ទ្រង់ក៏អាចឆ្លើយដោះស្រាយទាន់បានភ្លាមវិញដែរ។

មួយទៀត ដូចកាលដើមរាជ្យនៃ **ព្រះចាងសម្ដេចព្រះនរោត្តម សីហនុ** ប្រទេសខ្មែរត្រូវការ **បទអង្គរាជ** ។ បារាំងត្រូវក្មេង បានតែងបទនេះជាភាសាបារាំង។ ព្រះបរមរាជវាំងឲ្យពួកកវីខ្មែរប្រែអោយនៅសេចក្ដីដូចដើម ហើយឲ្យត្រូវបទភ្លេងបារាំងទៀត។ គេធ្វើពុំកើត។ សម្ដេចព្រះសង្ឃរាជ អាចធ្វើកើតក្នុងរវាង ១យប់នោះ។

**<u>៣. វេសារជ្ជប្បញ្ញា</u>** (បញ្ញាអង់អាចក្លៀវក្លា)

ភាពនៃប្រាជ្ញាអង់អាចក្លៀវក្លានេះ ជាគុណសម្បត្តិមួយដ៏ប្រសើររបស់មនុស្ស។ ប្រាជ្ញារបស់សម្ដេចព្រះសង្ឃរាជជាអម្ចាស់របស់យើង រាប់ថាជាប្រាជ្ញាមួយដ៏ខ្ពង់ខ្ពស់ អាចពោលបានថា សម្ដេចមានវេសារជ្ជប្បញ្ញាគ្រប់គ្រាន់ ព្រោះព្រះអង្គ បានទទួលព្រះកិត្តិនាមដ៏ខ្ចរខ្ចាយទៅក្នុងប្រទេស និងក្រៅប្រទេស។ ដូចយ៉ាងសម្ដេចទ្រង់យ៉ាងទៅកាន់ទីប្រជុំធំៗក្នុងប្រទេសដទៃ ព្រះអង្គតែងបន្ទឺសីហនាទ ប្រកបដោយប្រាជ្ញាដ៏ក្លៀវក្លា អង់អាចឥតញាប់ញ័រ

តក់ស្លុតចំពោះទីប្រជុំនោះឡើយ។ សម្តេចជាបុរសអាជានេយ្យ រកបានដោយក្រណាស់។ ប្រាជ្ញាដែលក្លៀវក្លាអង់អាច ដូចអធិប្បាយដោយសង្ខេបមកនេះហៅថា **វេសារជ្ជប្បញ្ញា** ។

<u>៤. ធម្មទេសនាកោសល្យ</u> (ការឈ្លាសវៃក្នុងធម្មទេសនា)

**សម្តេចព្រះសង្ឃរាជ** ទ្រង់មានភាពឈ្លាសវៃក្នុងធម្មទេសនា ដោយគ្រប់គ្រាន់។ ធម្មទេសនានៃសម្តេច ប្រកបដោយប្រយោជន៍ទាំងផ្លូវលោក ទាំងផ្លូវធម៌ អាចបំភ្លឺពុទ្ធបរិស័ទ ប្រជាពលរដ្ឋឲ្យយល់ផ្លូវខុស ផ្លូវត្រូវ ឲ្យជឿជាក់ចំពោះជាតិ សាសនា និងព្រះរាជបល្ល័ង្ក។ ព្រះធម្មទេសនា នៃសម្តេចព្រះសង្ឃរាជ ទុកជាជាមូលដ្ឋានមួយដ៏ស្តុកស្តម្ភ អាចបំភ្លឺប្រជាពលរដ្ឋឲ្យមានការព្យាយាមសិក្សា ប្រតិបត្តិធម៌វិន័យឲ្យមាំមួន ឲ្យមានជំហររឹងប៉ឹង ឲ្យប្រឹងប្រែងប្រកបការងារ កុំឲ្យខ្ជិលច្រអូស ឲ្យមានធម៌សាមគ្គី មូលមិត្រជាឯកភាពក្នុងរវាងជាតិ សាសនា និងព្រះរាជបល្ល័ង្ករបស់យើង ដើម្បីឲ្យខ្ពង់ខ្ពស់ថ្កើងរុងរឿងតទៅអនាគត។ ធម្មទេសនានៃសម្តេច ឈ្មោះថាជាធម្មទេសនាទ្រោលបំភ្លឺពុទ្ធបរិស័ទ ប្រជាពលរដ្ឋឲ្យយល់ប្រយោជន៍គ្រប់យ៉ាង គឺទាំងខាងគុណសម្បត្តិ ទាំងខាងគុណវិត្តិ, ជាធម្មទេសនា ប្រកបដោយមធ្យោបាយដ៏ប្រសើរវិសេស អាចដឹកនាំបង្អុលបង្ហាញប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍អនាគត ហៅថា ជាព្រះធម្មទេសនាដាស់ពុទ្ធបរិស័ទ ឲ្យភ្ញាក់ខ្លួនក្រោកឡើងប្រកបការងារ ដើម្បីឲ្យមានជីវភាពខ្ពង់ខ្ពស់ ឲ្យសមគួរដល់កិត្តិយសរបស់យើងរាល់គ្នា ជាប្រជាពលរដ្ឋនៃប្រទេសឯករាជ្យ ឲ្យចេះឈឺឆ្អាលស្រឡាញ់ជាតិ សាសនា និងព្រះរាជបល្ល័ង្ករបស់យើង។

**សម្តេចព្រះសង្ឃរាជ** មានធម្មទេសនាកោសល្យដ៏បរិបូណ៌។ ធម្មទេសនារបស់សម្តេច គួររាប់ថាជាធម្មទេសនាយឺតយោង ស្រោចស្រង់ប្រជាពលរដ្ឋ ឲ្យមានសតិសម្បជញ្ញៈរឹងប៉ឹងបរិបូណ៌ឡើង ទាំងផ្លូវពុទ្ធចក្រ និងផ្លូវអាណាចក្រ ដើម្បីឲ្យចក្រទាំងពីរវិលលឿនទៅស្មើៗ គ្នា។ ធម្មទេសនារបស់សម្តេច គួរលើកថា ជាធម្មទេសនាបើកលោក គឺបើកភ្នែកអ្នកប្រទេសកម្ពុជាទាំងមូល ឲ្យមានប្រាជ្ញាស្មារតីភ្លឺស្វាង រុងរឿងឡើងដោយពិត, ជា

ធម្មទេសនាដែលអាចផ្តល់មធ្យោបាយដ៏ប្រសើរ ឲ្យប្រជាពលរដ្ឋភ្ញាក់ខ្លួនប្រាណ ចេះជួយខ្លួនដោយខ្លួនឯង។

**សម្តេចព្រះសង្ឃរាជ** ជាព្រះធម្មកថិកមួយព្រះអង្គយ៉ាងឯក ពុំមានព្រះធម្មកថិកណាមួយប្រៀបស្មើបានឡើយ។ ធម្មទេសនានៃសម្តេច ប្រកបដោយឧត្តមគតិទាំងពិរោះក្បោះក្បាយ ប្រកបដោយពាក្យពេចន៍ ប្រយោគ ប្រធាន មានរបៀបរៀបរយ មានកម្រងនៃពាក្យសម្តីដ៏ត្រឹមត្រូវឥតឃ្លៀងឃ្លាត ភ្លាំងភ្លាត់ ដូចសេចក្តីអធិប្បាយនេះហៅថា **ធម្មទេសនាកោសល្យ** ។

**៤. <u>បណីតសកម្មភាព</u>** (សកម្មភាពដ៏ប្រសើរ)

ការងាររបស់សម្តេចព្រអសង្ឃរាជ សុទ្ធតែជាការងារមានប្រយោជន៍ដ៏ឧត្តុងឧត្តមចំពោះពុទ្ធបរិស័ទ ពុំមានការងារណាមួយ ដែលឥតប្រយោជន៍នោះទេ។

ទ្រង់បានធ្វើបុណ្យផ្សេងៗ ជាច្រើនដងណាស់ មានកឋិនទានជាដើម ក្នុងឆ្នាំនីមួយៗ បានធ្វើកឋិន២ ឬ៣វត្ត រៀងរាល់ឆ្នាំ ឥតដែលខានឡើយ។ កិច្ចការរបស់សម្តេច សុទ្ធតែមានគោលដៅឆ្ពោះទៅរកសេចក្តីសុខ សេចក្តីចម្រើន ទាំងលោកនេះ ទាំងលោកខាងមុខ ដោយពិតប្រាកដ សឹងមានភស្តុតាងយ៉ាងជាក់លាក់ក្នុងព្រះរាជជីវប្រវត្តិនេះ។

សម្តេចមានព្រហ្មវិហារដ៏ទូលាយ សង្គ្រោះដល់សាធារណជនមិនត្បិតត្បៀតពេកឡើយ។ កិច្ចការដែលចេះតែមាន ចេះតែដើរទៅមុខ មិនចេះឈប់ មិនចេះគាំងនៅ ថែមទាំងមានប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ហៅថា **បណីតសកម្មភាព** ។

**ព្រះមុនីកោសល ស្ទួរ ហាយ**

# ចរិតលក្ខណៈ និងកម្មវិធីប្រចាំថ្ងៃរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត

ការប្រព្រឹត្តជាប់ដោយកាយវាចាចិត្ត គ្រប់ពេលវេលាយូរៗទៅ អាចជាប់ទៅជាទម្លាប់ ហៅថា **ចរិតប្រក្រតី** ដូចយ៉ាង៖

- សម្តីគ្រោតគ្រាត ដែលធ្លាប់និយាយជាប់ជាទំនៀម ហៅថា ចរិតគ្រោតគ្រាត ។
- ការនិយាយកុហកលេងចំពោះមិត្តសំឡាញ់ យូរៗទៅក៏អាចធ្លាប់មាត់ជាទំនៀម នេះហៅថា ចរិតកុហក ។
- ការជក់បារី ដើមដំបូងឃើញគេជក់ ក៏ជក់លេងតាមគេ យូរៗទៅក៏អាចជាប់ជាទំនៀមជក់បារី ។
- ការដេកថ្ងៃ ដើមដំបូងឃើញគេដេកថ្ងៃ ក៏ដេកតាមគេ លុះដេកថ្ងៃយូរៗទៅក៏អាចក្លាយជាទំនៀម នេះហៅថា ចរិតដេកថ្ងៃ ។ការប្រព្រឹត្តិទាល់តែជាប់ប្រយោគ ដែលអាចលះចេញបានដោយកម្រ ដូច្នេះហៅថា ចរិតប្រក្រតី ។
- មនុស្សខ្លះមានចរិតប្រក្រតីជាប់ជោកធ្ងន់ណាស់ ដូចយ៉ាងចរិតប្រក្រតីផឹកស្រា ទាល់តែកឹកជាប់ ដែលអាចលះបង់ចេញបាន។ ចរិតប្រក្រតីបែបនេះ ឈ្មោះថា ជាចរិតនាំឲ្យខូចខាតទាំងជីវិតខ្លួនផង ទាំងទ្រព្យសម្បត្តិរបស់ខ្លួនផង។
- ការជក់អាភៀន ក៏អាចនាំឲ្យជាប់ញៀន លះចេញបានដោយកម្រណាស់។ ការញៀនអាភៀននេះ ហៅថា ចរិតប្រក្រតីជក់អាភៀន។ មនុស្សអ្នកមានចរិតបែបនេះ ឈ្មោះថាជាចរិតតឹង ចរិតធ្ងន់ ព្រោះនាំឲ្យខូចខាតទាំងជីវិត ទាំងទ្រព្យសម្បត្តិ ជាងចរិតអ្នកផឹកសុរា ដែលជាចរិតតឹងធ្ងន់ដែរនោះ ច្រើនណាស់ទៅទៀត។

## ចរិតប្រក្រតីនៃសម្តេចព្រះសង្ឃរាជ

**សម្តេចព្រះសង្ឃរាជ** ព្រះអង្គក៏មានចរិតប្រក្រតីដែរ ប៉ុន្តែចរិតរបស់សម្តេច ជាចរិតធូរស្រាល ពុំមែននាំឲ្យខូចខាតពេលវេលា ខូចខាតប្រយោជន៍នោះឡើយ។

- សម្តេចទ្រង់សោយស្លាម្ល ជាញឹកញយក្នុងថ្ងៃនីមួយៗ ទ្រង់មិនសោយបារីទេ។ ប៉ុន្តែលោកអ្នកធ្លាប់ដឹង-ឃើញ និយាយថា សម្តេចព្រះសង្ឃរាជ កាលពីវាងព្រះជន្ម ២០ឆ្នាំ រហូតដល់ព្រះជន្មជាង

៣០ឆ្នាំ ទ្រង់សោយបារីដែរ ប៉ុន្តែសោយរង្វើលៗ មិនញឹកញាប់ទេ, លុះដល់មកព្រះជន្មវាង៤០ឆ្នាំ ទើបសម្តេចសោយស្លាម្លូ កាន់តែញឹកញាយឡើងដរាបមក។

❖ សម្តេច កាលបើមានរោគផ្តាសាយ ដែលនាំឲ្យតឹងច្រមុះ និងក្អកដោយរោគផ្តាសាយនោះ អ្នកផង ច្រើនតែឃើញទ្រង់សោយថ្នាំចិនញាត់ខ្សៀ ហើយសម្តេចមានបន្ទូលថា រោគផ្តាសាយបានតែដក់ ថ្នាំចិនទើបធាប់ជាសះស្បើយ, ថ្នាំចិននេះនាំឲ្យជាឫសដូងច្រមុះទៀតផង។

❖ សម្តេចមានចរិតប្រក្រតី ក្នុងការសោយភត្តាហារ ច្រើនតែសព្វព្រះទ័យនឹងសម្លស្រឡក់ស្លឹកច្រេស, ប្រហើរក្តិបត្រឡាច-រពៅ, កកូរបន្លែឆ្នោត និងសម្លស្លឹកល្ងៀង, ពុំសូវសោយសាច់ឈាមទេ។ ម្ហូប ប៉ុន្មានមុខខាងលើនេះ ច្រើនតែឲ្យគេស្លនឹងត្រីឆ្អើរ, បើពុំមានម្ហូបនោះទេ ច្រើនសព្វព្រះទ័យម្ហូប ក្រៀមក្រោះ មានបុកត្រីឆ្អើរម្ទេះក្រសាំង ឬផ្លែម្កាក់ជាដើម។ សម្តេចពុំសូវសោយបង្អែមច្រើនទេ សោយតែបន្តិចបន្តួច, មិនសូវសោយកាហ្វេ ទឹកក្រូច(លីម៉ូណាត់) ញឹកញាយទេ សោយតែទឹក តែ និងស្ករស។

❖ សម្តេចសព្វព្រះរាជហឫទ័យនឹងកូនឈើផ្សេងៗ ដែលមានមែកច្រើន ដូចយ៉ាងដើមច្រកែងទួយ រទាំងជាដើម យកមកដាំដាក់ក្នុងផើងជាច្រើន ចំនួនជាង ១០០ផើង ទុកនៅវត្តឧណ្ណាលោម។

❖ ដើមឈើឯទៀតៗ ជាឈើធំណាំស្រុកក្តី ឈើក្នុងព្រៃក្តី ក៏សម្តេចរឹតតែសព្វព្រះរាជហឫទ័យដាំច្រើន ណាស់ទៅទៀត ដូចឈើក្នុងរបងឈាបនដ្ឋានវត្តឧណ្ណាលោម និងឈើឯវត្តពោធិព្រឹក្ស និងក្នុង មន្ទីរពេទ្យជាដើម។

# កម្មវិធីប្រចាំថ្ងៃរបស់សម្តេច

កម្មវិធីរបស់សម្តេចទៀងទាត់ចំពោះត្រង់តែសោយព្រះស្ងោយពេលថ្ងៃត្រង់ ហើយនឹងពេលដែលធ្វើការប៉ុណ្ណោះ ដូចយ៉ាងសរសេរដកស្រង់ធម៌អាថ៌រៀបចំធ្វើសៀវភៅផ្សេងៗ មានវចនានុក្រមខ្មែរជាដើមនេះ ទៀងទាត់រៀងរាល់ថ្ងៃរាល់យប់ទាល់ៗតែភ្លឺរវាងម៉ោង៦កន្លះ ទើបសោយយាគូ ថ្ងៃខ្លះពុំបានទាំងសោយយាគូថែមទៀត, ឃើញថាពេលយាគូពុំសូវទៀងទាត់ទេ។ លុះសោយព្រះស្ងោយថ្ងៃត្រង់ហើយ ទើបផ្ទំ...។

ពេលដែលសម្តេចកំពុងជាប់ព្រះហស្តសរសេរ ហើយមានភ្ញៀវចូលមកថ្វាយបង្គំគាល់ សម្តេចក៏បែរមកធ្វើបដិសណ្ឋារៈភ្លាមៗ ហើយមិនឲ្យនៅយូរទេ ព្រោះមានកិច្ចការច្រើនណាស់។ បើថ្ងៃណាមួយដែលសម្តេចទំនេរមិនមានកិច្ចការ ហើយមានភ្ញៀវ បព្វជិត ឬគ្រហស្ថចូលមកថ្វាយបង្គំគាល់ នោះសម្តេចសព្វព្រះរាជហឫទ័យប្រាស្រ័យទាក់ទង ដោយព្រះរាជឱង្ការសាកសួរពីនេះពីនោះ ហើយទ្រង់ដឹកនាំបំភ្លឺអំពីផ្លូវសាសនាយ៉ាងពិស្តារវែងឆ្ងាយណាស់ អស់៤-៥ម៉ោងក៏មាន ទាល់តែភ្លឺក៏មាន មិនចេះត្អូញថាងងុយសឹងថាចុករួយស្រពន់ទេ ឲ្យតែភ្ញៀវនោះទ្រាំអង្គុយចូលចិត្តស្តាប់ចុះ (ការណ៍នេះ ចំពោះតែពេលណាមួយដែលសម្តេចមានព្រះសុខភាពរាងកាយស្រួលល្អ)។

សម្តេចស្ទាត់បំផុតខាងការផ្ទំ ពុំមាននរណាមួយយកតម្រាប់តាមបានឡើយ។ វេលាផ្ទំមិនមានកំណត់ពេលណាមួយអោយប្រាកដប្រជាទេ គឺស្រេចតែមានឱកាស, បើព្រះអង្គមានឱកាសពេលណា ក៏ផ្ទំពេលនោះភ្លាម លក់ភ្លាម រវាង ១ម៉ោង ឬកន្លះម៉ោងទ្រង់តើនឡើងភ្លាម។ ទីកន្លែងដែលសម្តេចត្រូវផ្ទំនោះមិនរើសទេ ទោះបីទីណាមួយមានសំឡេងអ៊ូអរ ឬសំឡេងគេធ្វើការវាយដំឮក្តុងក្តាំងក៏ដោយ សម្តេចផ្ទំចេះតែលក់ស្រួលទាំងអស់ គឺថាងាយក្នុងការផ្ទំ ក្នុងការលក់ ក្នុងការតើនឡើងវិញពេកណាស់ គឺថាត្រង់ណាក៏ផ្ទំបាន ត្រង់ណាក៏លក់បាន កំណត់ប៉ុន្មានម៉ោងក៏អាចតើនឡើងបានតាមកំណត់មិនបាច់ដាស់។

ការផ្ទំលង់លក់របស់សម្តេចមិនយូរទេ ដូចយ៉ាងលើរថយន្ត លើកប៉ាល់ទឹក ឬលើយន្តហោះក៏អាចផ្ទំលក់បានភ្លាមៗ ។ សម្តេចមានមនោមយិទ្ធិមួយត្រង់ផ្ទំនេះប្រសប់បំផុត គ្មានអ្នកណាមួយរៀនយកតម្រាប់តាមបានឡើយ។

**ឈឹម ស៊ុម**

* * * * * * * * * * * * * * * * * * * * * * * * * * *

មកដល់ចុងបញ្ចប់នេះ ខ្ញុំស្រុកស្រែ បាននឹកឃើញដល់ប្រសាសន៍របស់ព្រឹទ្ធាចារ្យមួយរូប ដែលជាអតីតសិស្សសាលាបាលី និងជាអ្នកនៅបំរើទឹកក្តៅ ទឹកត្រជាក់ជូនសម្តេចព្រះសង្ឃរាជ នៅវត្តឧណ្ណាលោម បានរំលឹកប្រាប់ខ្ញុំពីអនុស្សាវរីយ៍មួយ រវាងគាត់ និងសម្តេចព្រះសង្ឃរាជជាអម្ចាស់ កាលក្នុងអំឡុងពេលទ័ពជប៉ុនចូលស្រុក...។

មានថ្ងៃមួយ កងទ័ពជប៉ុនមួយក្រុមបានចូលមកក្នុងទីអារាមវត្តឧណ្ណាលោម ហើយទាំងលោកនេនតូចៗ ទាំងភិក្ខុសង្ឃមិនដឹងថា កងទ័ពទាំងនោះមកក្នុងវត្តមានការស្អីទេ ក៏នាំពួកគេ អោយមកជួបព្រះតេជព្រះគុណ **ជួន ណាត** ។ ពេលនោះព្រះអង្គបានមានសង្ឃដីកាជាភាសាជប៉ុន បែបធម្មតាជាមួយកងទ័ពជប៉ុនទាំងនោះ ធ្វើអោយអ្នកនៅជុំវិញព្រះអង្គ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ កងទ័ពជប៉ុនទាំងនោះឆ្ងល់ ព្រមទាំងសួរទៅព្រះអង្គថា៖ តើព្រះអង្គចេះភាសាជប៉ុនតាំងពីអង្កាល? ហើយគ្រូណាបង្រៀនព្រះអង្គ?...

សម្តេចព្រះសង្ឃរាជ បានមានពុទ្ធដីកាប្រាប់ទៅកងទ័ពជប៉ុនវិញ ព្រមទាំងចង្អុលទៅ **វិទ្យុ** នៅក្បែរព្រះកាយព្រះអង្គ៖ **នេះ គ្រូអាត្មា**!...

មានរឿងដោយឡែកមួយទៀត ទាក់ទងនឹងកាយសម្បទាពីកំណើតរបស់សម្តេចព្រះសង្ឃរាជជាអម្ចាស់ ដែលខ្ញុំឆ្ងល់ថា: ហេតុអ្វីបានជាព្រះអង្គ ពូកែខាងសំនួនវោហារខ្លាំងម្ល៉េះ?... លោកព្រឹទ្ធាចារ្យខាងលើបានប្រាប់ខ្ញុំថា៖ នរណាដែលមានរង្វះមាត់ធំ អ្នកនោះនឹងពូកែខាងវោហារ..!!.. ព្រះឱស្ឋ(មាត់) របស់សម្តេចព្រះសង្ឃរាជ មើលទៅឃើញធម្មតា, តែបើព្រះអង្គហាព្រះឱស្ឋឡើងគឺ **អាចក្តាប់ដៃលូកចូលក្នុងមាត់ចុះ**... ហើយបុគ្គលដែលមានកាយសម្បទាពូកែខាងវោហារដូចសម្តេចព្រះសង្ឃរាជបែបនេះ នាពេលបច្ចុប្បន្ន គឺមានតែម្នាក់គត់... នោះគឺ៖ **សម្តេចតេជោ ហ៊ុន សែន**..!!..

ស្រុកស្រែ

# កាព្យលោកធម៌

( *ព្រះរាជនិពន្ធដំបូងបំផុតរបស់សម្តេចព្រះសង្ឃរាជ* **ជួន ណាត** )

ខ្ញុំឈ្មោះអក្សរ **ណ** ផ្សំស្រះ **អា** ដាក់ **ត** មុខជាតួបង្ហើយ
ជាតួប្រកបពុំអានឡើយ ឲ្យដល់ស្រះចុងដូចបាលី ។

មានកាលយប់មួយឥតកង្វល់ ខ្វល់ខ្វាយអំពីរឿងហេតុអ្វី
មានកិច្ចតែខាងមើលបាលី ដែលព្រះជិនស្រីទ្រង់ទេសនា ។

ខ្ញុំមើលត្រង់លោកធម្មសូត្រ រហូតដល់ចប់ព្រះគាថា
មើលបណ្តើរគិតបណ្តើរដោយចិន្តា គិតថានឹងប្រែជាសម្រាយ ។

ជាប្រយោជន៍នៃជនអ្នកត្រូវការ ចង់ចេះធម៌អាថ៌តាមអភិប្រាយ
អ្នកដែលមិនចេះខាងប្រែស្រាយ បើពាក្យសម្រាយច្រើនចូលចិត្ត ។

ខ្ញុំបានផ្តើមតែងជាពាក្យកាព្យ តាមសភាពប្រាជ្ញាខ្ញុំរិះគិត
តម្រូវជាធម៌ដែលមានពិត ប្រឌិដ្ឋប្រដូចឲ្យងាយយល់ ។

ខ្ញុំតែងជាកាព្យចម្រុះពាក្យ ប្រាំពីរប្រាំបីតាមយោយល់
ឃ្លាខ្លះមានកើនរហូតដល់ ប្រាំបួនពាក្យផ្តល់តាមសេចក្តី ។

ខ្ញុំសូមសម្តែងថែងពីធម៌ ដ៏បវរសម្រាប់ជនប្រុសស្រី
ឈ្មោះហៅលោកធម៌មានប្រាំបី ជាសង្ខេបខ្លីតាមគាថា ។

ធម៌ទាំងប្រាំបីប្រការនោះ មានឈ្មោះតាមបាលីភាសា
**លាភោ** មានលាភផងនានា ទោះស្រែចម្ការទោះមាសប្រាក់ ។

**អលាភោ** ឥតលាភឬខាតបង់
ខុសចំណង់ឃ្លាងចំណុចទាស់ទើសទាក់
មុខស្រពោនខ្លួនស្រពន់ចិត្តអន់អាក់
គំនិតរាក់ប្រាជ្ញាវល់ពុំយល់ធ្លាយ ។

**យសោ** មានយសស័ក្តិថ្កើងថ្កាន
បានអ្វីក៏បានមកដោយងាយ
តេជះតបះក៏ផ្សព្វផ្សាយ
ជនទាំងឡាយធំតូចសឹងរាប់អាន ។

**អយសោ** ឥតយសឬថ្លស់យស
ខ្ពស់ចុះជាទាបមិនសមប្រាណ
ថយអំណាចតេជះមិនក្លាហាន
បានអ្វីក៏បានដោយលំបាក ។

**និន្ទា** អ្នកផងគេតិះដៀល
ចាក់ឆ្កៀលដោយលំពែងគឺមាត់ពាក្យ
ទ្រគោះបោះបោកបោកខ្ទោកខ្ទាក
ជ្រោកជ្រាករិះគន់ពោលបង្កាច់ ។

**បសំសា** វាចាគេសរសើរ
បង្ហើរសម្ដីដោយបួរបាច់
ឆ្ពោះមុខឬកំបាំងគេថាស្រេច
នឹងខ្លួនហើយដាច់គេទាំងអស់ ។

**សុខំ** សុខកាយសុខទាំងចិត្ត
ឥតមានក្ដីទុកមកទើសទាល់
នេះនោះទាំងគ្រប់ស្រួលទាំងអស់
ខ្ពង់ខ្ពស់ថ្លៃថ្លាពេញបំណង ។

**ទុក្ខំ** គឺក្ដីទុក្ខក្ដៅក្ដួល
រំជួលជ្រួលច្រាល់មិនសមប៉ង
នាំកាយនិងចិត្តឲ្យសៅហ្មង
ឲ្យអ្នកផងគេព្រួយតែរាល់ប្រាណ ។

ធម៌នេះរាប់រាយមានប្រាំបី
បើផ្គួឲ្យខ្លីជាគូបាន
ត្រឹមតែបួនគូគត់តាមឋាន
កើតបានតែមួយមួយឈប់កើត ។

ផ្លាស់ប្ដូរជាវេនវេនតាមគូ
វិញ្ញូអ្នកប្រាជ្ញដែលចេះធើត
កំណត់សម្គាល់ស្គាល់កំណើត
ទោះធម៌ណាកើតក៏អាចដឹង ។

ព្រះពុទ្ធទ្រង់ត្រាស់សម្ដែងថា
អោយអស់បណ្ដាជនផងប្រឹង
យកចិត្តទុកដាក់គិតជញ្ជឹង
រំពឹកនឹកដល់ការប្រែប្រួល ។

ប្រយ័ត្នគំនិតប្រុងស្មារតី ទោះបីសុខទុក្ខស្រួលពុំស្រួល
កើតហើយបាត់ទៅតាមដំណួល ត្រូវគិតសម្រួលតាមការណ៍ពិត ។

សត្វលោកតែងស្នោកព្រោះលោកធម៌ បានអរបង់អន់ស្រពន់ចិត្ត
មានយសខ្ពង់ខ្ពស់រីករាយផត មានគំនិតគិតដល់ថ្លស់យសឡើយ ។

កាលបើបានឮពាក្យគេនិន្ទា ឆ្ពោះអាត្មាឪរាក្តៅមិនស្បើយ
បើបានឮគេសរសើរហើយ ចិត្តពុំកន្តើយអរផើតៗ ។

បានសុខភ្លេចនឹកដល់ទុក្ខំ កើតកម្លាំងក្លាខ្លាំងផតញញើត
ញញឹមញញយៗអរពព្រើត រកកល់គេទើតទាស់ពុំបាន ។

លុះដល់អស់វេនសេចក្តីសុខ ធ្លាក់វេនក្តីទុក្ខមកដល់ប្រាណ
ស្រាប់តែព្រួយរកគេឲ្យជួយប្រោន ទុក្ខនោះឲ្យក្សាន្តពីអត្តភាព ។

សុខក្តីទុក្ខក្តីរបស់សត្វ ខ្វាត់ទៅមកវិញតាមសភាព
បុណ្យបាបដែលធ្វើមករៀងរាប ស្វាបៗអោយផលដល់អាត្មា ។

ព្រះសម្ពុទ្ធជាមកុដនៃត្រៃភព ទ្រង់ប្រារព្ធធម៌នេះហើយត្រាស់ថា
ឲ្យសត្វរិះគិតដោយប្រាជ្ញា កុំសាវ៉ាតាមចិត្តដែលប្រទះ ។

បានលាភត្រូវនឹកដល់ការបង់ បានយសស័ក្តិរុងរឿងតេជះ
កុំកក្អិលក្អេងក្អាយដោយមានះ ត្រូវនឹកខ្លះកុំភ្លេចការប្រែប្រួល ។

បើឮអ្នកផងគេនិន្ទា ដល់អាត្មាត្រូវតាំងចិត្តសម្រួល
សម្រាកក្តីក្រោធកុំរំជួល បើទុកជាក្តៅក្តួលត្រូវខំអត់ ។

គប្បីគិតភ្លាមថានិន្ទា នេះជាគ្នានឹងសរសើរជាប្រាកដ
បើអញតាំងចិត្តជាអំណត់ រាល់មាត់គេនឹងសរសើរអញ ។

ថានេះហៅពេញជាចេះអត់
ធ្វើអ្នកស្អប់ឲ្យត្រឡប់ជាស្រឡាញ់
ចេះសង្កត់កំហឹងដែលចេះខ្នាញ់
បានសុខព្រោះផ្ចាញ់សេចក្តីក្រោធ ។

មួយទៀតមានពាក្យសុភាសិត
ថាកាលបើមានសេចក្តីក្រោធ
អ្នកប្រាជ្ញប្រឱជ្ឈជាចំណោទ
កុំច្រឡោតត្រូវរាប់អក្សរសិន ។

រាប់អក្សរតាំងពី **ក** ដល់ **ឡ អ័ខ**
ត្មេរគ្នាន់រកហេតុរកផលសិន
រួចសំកាំងគំនិតគិតដង្វិន
បើប្រសិនក្រោធល្មមនឹងបានស្រាក ។

ពុំនោះលោកថាអោយរាប់លេខ
ទ្រឹងមួយស្របក់នឹងបានស្រាក
ពី **៦ក** ដល់ **១ស** ឈប់សម្រាក
ឃ្លាតចាកកំហឹងដ៏ឃោរឃៅ ។

បើបានប្រកបដោយក្តីសុខ
កុំអាលអរអេកត្រេកសំដៅ
ឃ្លាតចេញពីទុក្ខសោកហ្មងសៅ
ដូចកង្កែបខែក្តៅត្រូវភ្លៀងធំ ។

គប្បីតាំងចិត្តគិតទៅមុខ
មុខជាថ្ងៃណាមួយនឹងរលំ
ថាឥឡូវមានសុខមកអប់រំ
ទុក្ខតូចឬធំមកពុំខាន ។

អ្នកណាបានសុខធំទូលាយ
នឹងមានទុក្ខធំពន់ប្រមាណ
ដល់វេនទុក្ខផ្សាយមកដល់ប្រាណ
តាមលំអានស្នាមសុខដែលកើតមុន ។

ហេតុនេះគួរអស់សាធុជន
ក្នុងលោកធម៌ណាដែលកើតមុន
កុំទម្រន់គំនិតឲ្យលង់ស៊ុន
ទោះស្រាលទោះធ្ងន់ក្តីសុខទុក្ខ ។

ទោះលាភទោះយសទោះខាតបង់
ទោះសរសើរទោះនិន្ទាថាកំព្រុក
ទោះលិចលង់ថ្លស់យសមិនពេញមុខ
ត្រូវតែតាំងចិត្តជាមជ្ឈម ។

លុះបានតាំងចិត្តទុកដូច្នេះ
ដោយហេតុមិនផ្ញុំចិត្តឲ្យងំ
ទើបរបេះឃ្លាតខ្លះពីទុក្ខធំ
ឲ្យរង្គំនៅក្នុងកន្លែងមួយ ។

បើមានប្រាជ្ញាប្រយោគដល់
ទើបចិត្តនឹងអាចឃ្លាតចាកព្រួយ
ហេតុនិងផលដែលមានជាតម្រួយ
បើទុកជាព្រួយក៏គ្រាន់ទ្រាំ ។

ពីព្រោះបានដឹងច្បាស់ការណ៍ពិត
ដឹងថាលោកធម៌កើតជោគជាំ
ដោយគំនិតត្រិះរិះដ៏មួនមាំ
ស៊ាំទាំនៅក្នុងសន្តានសត្វ ។

កើតមានមិននឹងតែមួយៗ
ហើយមានឡើងវិញមិនទៀងទាត់
ជួនព្រួយជួនអរមានបាត់ៗ
មួយកើតមួយបាត់ផ្លាស់ប្តូរគ្នា ។

បើដឹងដូច្នេះហើយគួរខំ
គួរគិតគួរគ្នេរពិចារណា
អប់រំប្រាជ្ញាឲ្យភ្លៀវភ្លា
សិក្សារៀនសូត្រកុំធុញទ្រាន់ ។

គួរប្រឹងសង្កេតធម៌បរមត្ថ
ប្រាប់ផ្លូវមគ្គផលមិនមានភ័ន្ត
មានអត្ថជ្រាលជ្រៅជាអនន្ត
មានថ្នាក់មានជាន់តាមលំដាប់ ។

សត្វដែលនឹងបានរួចចាកទុក្ខ
មានគំនិតដូចសត្វទទាជាប់
ព្រោះធុញដូរមុខនឹងកើតស្លាប់
ក្នុងទ្រុងមិនគាប់ក្តីប្រាថ្នា ។

ចេះតែស្ទុះប្រាស់ប្រាលជាលចឹកទ្រុង
ស្ទុះចេញឲ្យរួចហើយនឹងលា
ចង់អោយរលុងនឹងម្ចីម្នា
ត្រដាងស្លាបវាហើយហើរទៅ ។

អ្នកដែលធុញទ្រាន់នឹងកើតស្លាប់
គឺវដ្តសង្សារនេះហើយទៅ
ចង់ប្រញាប់ចាកចេញចោលលំនៅ
កាន់លំនៅដែលទុក្ខរលត់បង់ ។

មគ្គផលនឹងមានព្រោះអាស្រ័យ
ហើយស្មុគ្រនឹងដើរតាមផ្លូវត្រង់
ចិត្តដាច់អាល័យពីចំណង់
ប្រកបដោយអង្គប្រាំបីយ៉ាង ។

ហៅថា **អដ្ឋង្គិកមគ្គ**
ស្រួលដើរបំផុតដល់អ្នកសាង
ឥតអ្វីទើសទាក់ឥតរៀចរាង
មានសំណាងដូចយ៉ាងព្រះសុគត ។

ផ្លូវនេះជាហេតុជាឧបាយ ឲ្យសត្វទាំងឡាយបានរលត់
ភ្លើងទុក្ខហើយលែងមានរន្ធត់ ព្រោះលោកធម៌ទាំងប្រាំបី ។

ឈ្មោះហៅថាបានព្រះនិព្វាន ជានិរោធដ្ឋានគ្មានទុក្ខភ័យ
សុខក្រៃលែងសុខឥតទុក្ខអ្វី មកប៉ះមកពាល់ដល់តិចឡើយ ។

ជាឋានគ្មានចាស់គ្មានឈឺចាប់ គ្មានកើតគ្មានស្លាប់សុខកន្តើយ
ព្រះពុទ្ធទ្រង់ត្រាស់ហៅថាត្រើយ អ្នកទៅដល់ហើយលែងមកវិញ ។

ជាទីឥតកិច្ចការគ្រប់យ៉ាង ឥតសង់ឥតសាងឥតលក់ទិញ
មានតែសុខមួយយ៉ាងជាចំណេញ ឈ្មោះថាចេញចាកទុក្ខស្រឡះហោង ។

សេចក្តីនេះពិតជាពាក្យកាព្យ តែមិនមែនកំណាព្យពាក្យផ្តាំផ្តង
ជាសាច់ធម៌មែនឥតមោះហ្មង គ្រាន់តែក្រងជាពាក្យមានឃ្លោងឃ្លា ។

សូមអស់អ្នកប្រាជ្ញរាជកវី កុំបីបន្ទោសដៀលនិន្ទា
ពាក្យនេះខ្ញុំតែងតាមមាត្រា សម្ពួស្សវាចាមិនមានល្បៀង ។

តាមច្បាប់មេកាព្យវិលាសិនី វិធីអ្នកប្រាជ្ញលោករៀបរៀង
ជាច្បាប់សម្រាប់គ្រាន់ផ្ទឹមផ្ទៀង ឲ្យទៀងតាមបែបខ្យល់អក្សរ ។

**ឥតិ ឯវំ មេ ភាវេា** **បរិបុណ្ណោ** តាមសាច់ធម៌
**សុខិតាហោន្តុ** សត្តនិករ ចូរបានអំណរសុខគ្រប់គ្នា...៕

*ថ្ងៃទី ០៦ តុលា ព.ស ២៤៩៨ គ.ស ១៩៥៥*

*បានអនុញ្ញាតឲ្យអ្នកមហា* ***ឈឹម ស៊ុម*** *បោះពុម្ពផ្សាយចុះ*

**សម្តេចព្រះមហាសុមេធាធិបតី**

**(ជ.ណ ជោតញ្ញាណោ) សង្ឃនាយក**

# ព្រះរាជប្រវត្តិពិស្តារ

និង

# កាព្យលោកធម៌

របស់

សម្ដេចព្រះសង្ឃរាជ (ជ.ណ. ជោតញ្ញាណោ)

បណ្ណាគារ **សុមនសុវត្ថិ** លេខ ៤២
វិថី កែវ-ជា ក្រុងភ្នំពេញ

បោះពុម្ពចែកផ្សាយជាធម្មទាន
ក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព
នៃសម្ដេចជាអម្ចាស់ព្រះអង្គនោះ

ព.ស. ២៥១៣ = គ.ស. ១៩៧០